# ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩

## យល់ដឹងផ្នែកច្បាប់៖ បទញុះញង់អនីតិជនឱ្យសុំទាន

http://www.freshnewsasia.com/index.php/en/localnews/ 2019-06-02

**(ភ្នំពេញ)៖** នាពេលបច្ចុប្បន្ន យើងសង្កេតឃើញថាមានវត្តមានកុមារជាអនីតិជនជាច្រើន ដែលតែងតែដើរសុំទាននៅតាមទីសាធារណៈ ឬទីប្រជុំជនមានដូចជា តាមដងផ្លូវ តាមស្តុបសាធារណៈ វត្តអារាម ភោជនីយដ្ឋាន និងតាមតំបន់រមនីយដ្ឋាននានា មិនថាពេលថ្ងៃ ឬពេលយប់ឡើយ។ ភាគច្រើន មូលហេតុចម្បងដែលជម្រុញឱ្យកុមារទាំងនេះដើរសុំទាន គឺអាចបណ្តាលមកពីបញ្ហាជីវភាព និងមួយចំណែកទៀតអាចកើតចេញពីសមាជិកគ្រួសារក្មេងនោះ ឬជនខិលខូចមួយចំនួនជួយសម្របសម្រួល និងញុះញង់ ក៏ដូចជាធ្វើការគំរាមកំហែងឱ្យកុមារទាំងនោះ យកការសុំទានមកធ្វើជាមុខរបរដើម្បីរកប្រាក់ចិញ្ចឹមពួកគេ។

ដូច្នេះ ដើម្បីឲ្យជ្រាបកាន់តែច្បាស់ យើងត្រូវដឹងថា តើអំពើ និងសកម្មភាពបែបណា ដែលត្រូវបានចាត់ទុកថាជាការញុះញង់អនីតិជនឱ្យសុំទាន? ហើយជនដែលប្រព្រឹត្តអំពើនេះ ត្រូវទទួលទោសតាមច្បាប់កម្រិតណា? **ដើម្បីជួយស្រាយចម្ងល់ និងបំភ្លឺអំពីបញ្ហាខាងលើជូនបងប្អូនប្រជាពលរដ្ឋ សិស្ស និស្សិតទាំងអស់ កម្មវិធីយល់ដឹងផ្នែកច្បាប់របស់អង្គភាពព័ត៌មាន Fresh News សហការជាមួយ ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ សូមលើកយកប្រធានបទស្តីពី «បទញុះញង់អនីតិជនឱ្យសុំទាន» មកបកស្រាយ និងចែករំលែក ដូចតទៅ៖**

អនីតិជន គឺសំដៅទៅលើជនទាំងឡាយណាដែលមិនទាន់គ្រប់អាយុតាមច្បាប់កំណត់ ឬ មានអាយុក្រោម ១៨ ឆ្នាំ។ កាលណាអត្រានៃអនីតិជនដែលដើរសុំទានមានកាន់តែច្រើន នោះផលប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់ពួកគេក៏កើតមានច្រើនដូចគ្នា ដែលផលប៉ះពាល់ទាំងនោះរួមមាន ការកេងប្រវ័ញ្ចលើកម្លាំងពលកម្មកុមារ ការបង្កឱ្យមានភាពឥតសណ្តាប់ធ្នាប់នៅតាមទីសាធារណៈ ហានិភ័យនៃការទទួលរងគ្រោះថ្នាក់ផ្សេងៗ (ឧទាហរណ៍. គ្រោះថ្នាក់ចរាចរណ៍) និង អាចធ្វើឱ្យកុមារទាំងនោះបាត់បង់ឱកាសក្នុងការរៀនសូត្រផងដែរ។

យ៉ាងណាមិញ នៅពីក្រោយការសុំទានរបស់អនីតិជន យើងឃើញថាមានជនខិលខូចមួយចំនួនដែលមានភាពខ្ជិលច្រអូស និងគេចវេសពីការប្រកបរបរចិញ្ចឹមជីវិតដោយខ្លួនឯង បានរិះរកវិធីសាស្ត្រទុច្ចរិត និងរៀបចំផែនការគ្រប់មធ្យោបាយ ដើម្បីកេងចំណេញ ឬទាញយកផលប្រយោជន៍ពីកុមារដែលខ្សត់ខ្សោយទាំងនោះ។ បើផ្អែកតាមការសិក្សាស្រាវជ្រាវលើបញ្ហានេះកន្លងមក មធ្យោបាយដែលមេខ្លោងទាំងនោះយកមកប្រើប្រាស់មានដូចជា ការសម្របសម្រួលដោយរកទីតាំងសម្រាប់ឱ្យកុមារជាអនីតិជនទាំងនោះសុំទាន ហើយផ្តល់ដំណឹងឱ្យកុមារទាំងនោះគេចខ្លួនរាល់ពេលដែលមានមន្ត្រីមានសមត្ថកិច្ចចុះមកត្រួតពិនិត្យជាដើម។ បន្ទាប់មកកុមារជាអនីតិជន ត្រូវប្រគល់ប្រាក់មួយចំនួនដែលខ្លួនសុំបានទៅឱ្យមេខ្លោង ដើម្បីជាថ្នូរក្នុងការផ្តល់ដំណឹង។

ក្រៅពីមធ្យោបាយខាងលើ មានជនទុច្ចរិតមួយចំនួនទៀត បានធ្វើការញុះញង់ឱ្យកុមារដើរសុំទានតាមទីសាធារណៈ រួចប្រគល់ប្រាក់ទាំងអស់មកឱ្យខ្លួន ដើម្បីដូរយកអាហារ ក៏ដូចជាទីជម្រកផងដែរ។ ក្នុងករណីដែលមិនអាចសុំទានបានគ្រប់តាមចំនួនណាមួយដែលមេខ្លោងបានកម្រិត កុមារដែលជា អនីតិជនទាំងនោះ អាចត្រូវទទួលរងនូវការគំរាមកំហែង បង្អត់អាហារ និងដេញចេញពីកន្លែងស្នាក់អាស្រ័យទៀតផង។

ដោយហេតុដូចបានរៀបរាប់ខាងលើនេះ ទើបក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានដាក់បន្ទុកទៅលើជនខិលខូចទាំងអស់នោះ ដោយបញ្ញត្តត្រង់មាត្រា ៣៤៤ ថា៖ **«អំពើញុះញង់អនីតិជនដោយផ្ទាល់អោយសុំទាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន)រៀល»** ។ សរុបមកវិញ ជនទាំងឡាយណាដែលបានប្រព្រឹត្តិអំពើញុះញង់អនីតិជនឱ្យសុំទាន ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ហើយអនីតិជនដែលមិនទាន់គ្រប់អាយុទាំងអស់ គួរគប្បីទទួល

បានការគាំពារថែរក្សា ដោយទទួលបាននូវការសិក្សាអប់រំរៀនសូត្រ និងតាមរយៈការបំបាត់នូវរាល់សកម្មភាពរំលោភបំពានសិទ្ធិនានាទៅលើពួកគេ។

**រៀបរៀងដោយ៖** លោកមេធាវី ឡាន ស៊ីនីត និងកញ្ញា គន្ធ រិដិតា ជាសមាជិកក្រុមការងាររៀបចំ និងផ្សព្វផ្សាយអត្ថបទច្បាប់ នៃ ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ មានអាសយដ្ឋាននៅអគារលេខ ៤៥៣៥ ផ្លូវលេខ ១០០៣ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរស័ព្ទទំនាក់ទំនងលេខ ០២៣ ៩៨៦ ២៤៥/០៧៨ ២៧២ ៧៨៥, អ៊ីម៉ែល៖ president@ciclg.com គេហទំព័រ៖ www.ciclg.com, ហ្វេសបុកផេក៖ ក្រុមមេធាវី កម្ពុជា សហប្រតិបត្តិការអន្តរជាតិ / Cambodia International Cooperation Law Group៕

## កម្ពុជាត្រូវអង្គការសហប្រជាជាតិដាក់ជាប្រទេសដែលបានចូលរួមលុបបំបាត់ហិង្សាលើកុមារ

http://bayontv.com.kh/ 01/06/2019

ភ្នំពេញ ៖ នៅក្នុងឱកាសកម្ពុជាប្រារព្ធខួបលើកទី៧០ ទិវាកុមារអន្តរជាតិ ១ មិថុនា ឆ្នាំ២០១៩ បណ្តាអង្គការសង្គមស៊ីវិលដែលធ្វើការងារដើម្បីកុមារ បានអបអរសាទរចំពោះស្នាដៃដឹកនាំដោយប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដែលកាលពីពេលថ្មីៗនេះ ត្រូវបានអង្គការសហប្រជាជាតិ(UN) ចុះឈ្មោះព្រះរាជាណាចក្រកម្ពុជាចូលជាប្រទេសទី២៦ លើការងារលប់បំបាត់អំពើហិង្សាគ្រប់ទម្រង់ លើកុមារនៅកម្ពុជា។

នាយកប្រតិបត្តិអង្គការសម្ព័ន្ធសិទ្ធកុមារកម្ពុជា លោក សុន ពេញ បានថ្លែងឱ្យដឹងថា ការដាក់បញ្ចូលប្រទេសកម្ពុជា ជាប្រទេសទី២៦ របស់UN លើការងារលប់បំបាត់អំពើហិង្សានេះ បានន័យថា កម្ពុជាគឺជាប្រទេសឈានមុខគេនៅក្នុងចំណោមប្រទេសជាច្រើននៅលើពិភពលោក លើការងារលុបបំបាត់អំពើហិង្សាលើកុមារ ពិសេសកុមារនៅតាមសាលារៀន កុមារនៅតាមខ្ទងផ្ទះ និងនៅតាមទីសាធារណៈជាដើម។ លោក បន្តថា ការដាក់បញ្ចូលកម្ពុជាជាសមាជិកក្នុងចំណោមប្រទេសចំនួន២៦ របស់UNនេះ ដោយសារUN គេវាយតំលៃថា កម្ពុជា មានច្បាប់ មានផែនការ មានគោលនយោបាយច្បាស់លាស់ ក្នុងការប្រយុទ្ធប្រឆាំងអំពើហិង្សាលើកុមារ។ សម្រាប់ការដាក់បញ្ចូលកម្ពុជាជាប្រទេសទី២៦ របស់UN នេះដែរ លោក សុន ពេញ ក៏បានស្នើអោយអាណាព្យាបាលគ្រប់រូប ជីដូន អ្នកមើលថែកុមារ និងលោកគ្រូអ្នកគ្រូ សូមបញ្ឈប់ជាបន្ទាន់លើការប្រើប្រាស់អំពើហិង្សា ដោយគិតចាប់ពីការជេរប្រមាថកុមារឡើងទៅ ធ្វើជាមធ្យោបាយសម្រាប់អប់រំកុមារ និងប្រដៅទូន្មានកុមារ។

កន្លងមកឯកឧត្តម តូច ចន្ទី អគ្គនាយកបច្ចេកទេសនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានថ្លែងថា នៅក្នុងដំណាក់កាលនៃការប្តេជ្ញាចិត្តលប់បំបាត់អំពើហិង្សាលើកុមារនៅកម្ពុជា គឺយើងមិនអាចលុបបំបាត់អស់នោះទេ ពោលគឺយើងបានត្រឹមតែទប់ស្កាត់ និងកាត់បន្ថយវា ខណៈអាណាព្យាបាលមួយចំនួននៅតែមានផ្នត់គំនិតប្រើប្រាស់អំពើហិង្សាតាមបែបប្រពៃណីធ្វើជាមធ្យោបាយសម្រាប់អប់រំកុមារជាដដែល៕

## អង្គការ APLE និងនគរបាល រួមគ្នាបង្កើតបន្ទប់សម្រាប់សម្ភាសកុមាររងគ្រោះ

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 03 June 2019 | 10:32 ICT

**ភ្នំពេញៈ** អង្គការសកម្មភាពដើម្បីកុមារ (APLE) ដាក់ឲ្យប្រើប្រាស់បន្ទប់សម្ភាសន៍តាមបែបកុមារមេត្រីនៅការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជននៃស្នងការដ្ឋាននគរបាលខេត្តកំពត ដើម្បីជួយសម្រួលដំណើរការនៃការសម្ភាសជាមួយនឹងកុមារដែលអាចទទួលរងគ្រោះពីអំពើរំលោភ បំពាន និងកេងប្រវ័ញ្ចផ្លូវភេទផ្សេងៗ

យោងតាមសេចក្ដីប្រកាសរបស់អង្គការនេះចេញផ្សាយកាលពីថ្ងៃសុក្រ។ សេចក្ដីប្រកាសព័ត៌មានដដែលនេះបានដឹងថា ការបង្កើតបន្ទប់នេះឡើង នឹងធ្វើឲ្យកុមារមានភាពល្អប្រសើរឡើងវិញ ចៀសវាងការប៉ះទង្គិចផ្លូវចិត្តជាថ្មីនៅពេលពួកគេចូលដល់បន្ទប់បែបបច្ចេកទេសនេះផងដែរ។ សេចក្ដីប្រកាសនេះបានឲ្យដឹងថា៖ «បន្ទប់កុមារមេត្រីនេះគឺជាគំនិតផ្តួចផ្តើមដែលត្រូវបានបង្កើតឡើងនៅតាមបណ្តាខេត្តនានាមួយចំនួនរួចមកហើយ ដែលវាជាចំណែកមួយនៃ

កម្មវិធីអភិវឌ្ឍន៍ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដែលបានធ្វើការយ៉ាងជិតស្និទ្ធជាមួយ អាជ្ញាធរប៉ូលិសជាតិក្នុងការលើកកម្ពស់ ការអនុវត្ត ជិតស្និទ្ធ ដែលមានស្តង់ដា ក្នុងអំឡុងពេលស៊ើបអង្កេត»។

លោក ខឹម វ៉ាន់ដូ អ្នកឯកទេស ការពារកុមារ នៃអង្គការ APLE បានប្រាប់ភ្នំពេញប៉ុស្តិ៍ពីម្សិលមិញថា កន្លងទៅអង្គការ បានបង្កើតបន្ទប់សម្ភាសន៍បែបកុមារមេត្រីនេះចំនួន ៣ រួចមកហើយ គឺទី១ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជននៃអគ្គស្នងការនគរបាលជាតិ និងទី២ នៅការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៅខេត្តសៀមរាប និងខេត្តកណ្តាល។ ការបង្កើតបន្ទប់កុមារមេត្រីបន្ថែមទៀតនេះ គឺជាមធ្យោបាយផ្តល់ភាពងាយស្រួល ដល់អាជ្ញាធរខេត្តនេះ ជាពិសេស ផ្តល់ការជឿទុកចិត្តដល់កុមាររងគ្រោះបន្ថែមទៀត។ លោក ខឹម វ៉ាន់ដូ ថ្លែងថា៖ «តាមបទពិសោធដែលយើងធ្វើការជាមួយនគរបាលកន្លងមក គាត់មិនមានបន្ទប់សម្ភាសន៍បែបកុមារមេត្រីទេ ប៉ុន្តែនគរបាលមួយចំនួន បានអនុវត្តតាមនីតិវិធីដែលគាត់ផ្តោតទៅលើភាពឯកជនរបស់កុមារដែរ។ ប៉ុន្តែជាការពិតបន្ទប់បែបកុមារមេត្រីគឺយើងគិតគូរខ្ពស់បំផុត ទៅដល់ឧត្តមប្រយោជន៍របស់កុមារ ហើយយើងរៀបចំនេះ គឺទៅតាមស្តង់ដាតាមបែបអ្នកជំនាញ»។ លោកថ្លែងថា ជារួមបន្ទប់សម្ភាសន៍តាមបែបកុមារមេត្រី គឺជាបន្ទប់មួយដាច់ដោយឡែក សម្រាប់តែកុមារដែលរងគ្រោះតែប៉ុណ្ណោះ ហើយវាមានបំពាក់ឧបករណ៍នានាមួយចំនួន ដោយធានាថា ការនិយាយរបស់កុមារ គឺត្រូវទុកជាការសម្ងាត់ ហើយមិនមានការរំខានពីភាគីដទៃនៅពេលកុមាររងគ្រោះ នៅក្នុងបន្ទប់នេះ។

លោក ម៉ៅ ចាន់ម៉ាធុរិទ្ធ ស្នងការនគរបាលខេត្តកំពត បានអះអាងថាបន្ទប់សម្ភាសន៍បែបកុមារមេត្រីនេះដែរថា វាពិតជាបានចូលរួមចំណែកយ៉ាងច្រើនដល់អាជ្ញាធរមានសមត្ថកិច្ច ក្នុងការពន្លឿននីតិវិធីនៃការស៊ើបអង្កេត ហើយក៏ចូលរួមជួយដល់ជនរងគ្រោះផងដែរ។ លោកបញ្ជាក់ថា៖ «យើងរៀបចំនេះ មានសារៈសំខាន់ល្អ ព្រោះកុមារ (រងគ្រោះ) ពេលដែលយើងយកគាត់មកដល់បន្ទប់នេះ ធ្វើឲ្យគាត់បានសម្រួលអារម្មណ៍ ដែលងាយស្រួលក្នុងការទទួលបានព័ត៌មានអីផ្សេងៗពីកុមារ» ។ លោក វ៉ាន់ដូ ថ្លែងថា បន្ទប់បែបនេះនឹងធ្វើបន្តនៅខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ចាមជាដើម៕

## ពលរដ្ឋខ្មែរ នឹងបាត់បង់ការងារដោយសារគ្មានជំនាញច្បាស់លាស់ ព្រមទាំងការរីកចម្រើនរបស់ពិភពលោក

http://bayontv.com.kh/ 03/06/2019

ភ្នំពេញ ៖ មន្ត្រីជាន់ខ្ពស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានថ្លែងថា នៅឆ្នាំបន្តបន្ទាប់ខាងមុខ បណ្តាពលករ និងកម្មករខ្មែរមួយចំនួននឹងរងការបាត់បាត់ការងារធ្វើរបស់ខ្លួន ប្រសិនបើពលករ និងកម្មករដែលកំពុងមានការងារធ្វើទាំងនោះ មិនខិតខំស្វះស្វែងរកការសិក្សាជំនាញមួយអោយបានច្បាស់ ចាប់ពីពេលនេះ តទៅនោះទេ។

ថ្លែងនៅថ្ងៃទី៣១ ខែឧសភា នាចុងសប្តាហ៍ កន្លងមកនេះ ឯកឧត្តម ពេជ្រ សោភ័ណ្ឌ រដ្ឋលេខាធិការប្រចាំការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឱ្យដឹងថា គ្រប់យុវជន និងកម្មករខ្មែរនៅពេលបច្ចុប្បន្ននេះប្រសិនបើមិនខិតខំស្វះស្វែងរកការសិក្សារៀនសូត្រអោយមានជំនាញមួយពិតប្រាកដ នៅក្នុងខ្លួនទេ នៅថ្ងៃអនាគត គេនឹងមិនអាចរកការងារល្អៗធ្វើបាននោះទេ ហើយគេក៏មិនអាចស្វែងរកការងារធ្វើនៅក្រៅប្រទេសបាននោះដែរ ហើយអ្នកដែលប្រឈមនឹងការអត់ការងារធ្វើខ្លាំងជាងគេ គឺជាអ្នកដែលទទួលបានការសិក្សាតិចជាងគេ។ ប្រសាសន៍ឯកឧត្តម ពេជ្រ សោភ័ណ្ឌ បានធ្វើឡើង ខណៈរបាយការណ៍របស់អង្គការពលកម្មអន្តរជាតិ ILO កាលពីពេលថ្មីៗនេះបានចេញផ្សាយថា កម្ពុជាស្ថិតក្នុងចំណោមប្រទេសចំនួន៥ រួមមាន ៖ កម្ពុជាខ្លួនឯង, វៀតណាម ថៃ ឥណ្ឌូនេស៊ី និងប្រទេសហ្វីលីពីន សរុបប្រជាជនប្រមាណ១៣៧ លាននាក់ នឹងប្រឈមការបាត់បង់ការងារ ឬគ្មានការងារធ្វើ ដោយសារនៅក្នុងសម័យបដិវត្តឧស្សាហកម្ម៤.០ បណ្តាសង្វាក់ផលិតកម្មការងារនៅក្នុងរោងចក្រមួយចំនួនធំ នឹងងាកទៅរកការប្រើប្រាស់

បញ្ញាសិប្បនិម្មិត ដែលដើរដោយកម្លាំងម៉ាស៊ីនជំនួសអោយកំលាំងមនុស្ស។ ឯកឧត្តម ពេជ្រ សោភ័ណ្ឌ បន្តថា នៅពេលបច្ចុប្បន្ននេះ ជាបណ្តើរៗគ្រប់យុវជនមិនទាន់បានសិក្សាជំនាញ ឬ គ្រប់កម្មករដែលកំពុងធ្វើការងារដោយកម្លាំងនៅតាមការដ្ឋាន រោងចក្រសហគ្រាសនានា គួរខិតខំស្វះស្វែងរកឱកាសការសិក្សាជំនាញ ដើម្បីបង្កើនប្រាក់ខែខ្ពស់ផង និងស្ថេរភាពអនាគតការងារផងដែរ។

ប្រធានគម្រោងមូលនិធិអភិវឌ្ឍន៍ជំនាញ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លោក ជា កុកហេង បានថ្លែងថា ដើម្បីរួមចំណែកអភិវឌ្ឍន៍ជំនាញដល់យុវជនខ្មែរ នៅក្នុងឆ្នាំ២០១៩នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រកាសរួមចំណែកផ្តល់មូលនិធិទៅដល់បណ្តាសាលា និងក្រុមហ៊ុនរោងចក្រសហគ្រាសនានា សំដៅផ្តល់ឱកាសបុគ្គលិក កម្មករកំពុងបំរើការងារដោយមិនមានជំនាញអោយគេបានសិក្សារៀនសូត្រដើម្បីទទួលបានជំនាញមួយនៅក្នុងខ្លួន។ លោក ជា កុក ហេង បន្តថា មកដល់ពេលនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់មូលនិធិអភិវឌ្ឍន៍ជូន បណ្តាក្រុមហ៊ុន និងសាលាបណ្តុះបណ្តាលជំនាញរដ្ឋ និងឯកជនបានមួយជំនាន់រួចហើយ ដែលមានយុវជន បុគ្គលិក កម្មករនិយោជិត ប្រមាណជាង៥០០នាក់ បានទទួលការបណ្តុះបណ្តាលជំនាញមួយច្បាស់លាស់៕

## ថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ០៧នាក់ ឲ្យមកកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI May 31 at 5:03 PM

កោះកុង៖ កម្លាំងនគរបាលប៉ុស្តិ៍ប្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៦និង៤៥នាទី ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃ ចំនួន ០៧នាក់។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ថៃចាប់ឪពុកចុងខ្មែរវ៉ៃកូនចុងអាយុ០៦ឆ្នាំឡើងបែកឈាម

*https://prakpheaktra.blogspot.com/ 02-06-2019*

យោងតាមរបាយការណ៍របស់សមត្ថកិច្ចខេត្តឈុនបុរីប្រទេសថៃ បានអោយដឹង កម្លាំងសមត្ថកិច្ចថៃ បានធ្វើការឃាត់ខ្លួន បុរសជនជាតិខ្មែរម្នាក់ ទី០១ ឈ្មោះ សូត ស្មី អាយុ ២៦ឆ្នាំសញ្ជាតិ ខ្មែរ ត្រូវជាឪពុកចុង និងទី០២ ឈ្មោះ នាង វ៉ាន់ នីសា អាយុ ២៤ឆ្នាំ សញ្ជាតិ ថៃ រស់នៅក្នុងសង្កាត់បាងសាយ ស្រុកមឿង ខេត្តឈុនបុរី ។ បន្ទាប់សមត្ថកិច្ចទទួលបានពាក្យបណ្តឹងពីប្រជាពលរដ្ឋថៃប្តឹងករណីនាងវ៉ាន់នីសានិងប្តីចុងវាយធ្វើបាបកូនរបស់ខ្លួនឈ្មោះ តូ ភេទប្រុស អាយុ ០៦ឆ្នាំ ត្រូវជាកូនចុងបណ្តាលឲ្យមានស្លាកស្នាមបែកឈាមជាំពេញខ្លួនប្រាណ បន្ទាប់មកត្រូវបានអ្នកជិតខាងនាំយកទៅព្យាបាលនៅមន្ទីរពេទ្យខេត្តឈុនបុរី។

តាមការអះអាងរបស់ម្តាយកុមាររងគ្រោះគឺនាង វ៉ាន់នីសា បានប្រាប់ឲ្យដឹង នាងបានទៅពិនិត្យឈាមនៅមន្ទីរពេទ្យមួយកន្លែង ដោយដឹងមានមានផ្ទុកមេរោគអេដស៍ (HIV) នាងបានបន្តថា កូនប្រុសរបស់នាងតែងតែឌឺ ហើយនាងវ៉ៃកូនរហូតជាំខ្លួនប្រាណពេលខ្លះ ហើយប្តីចុងនាងក៏ធ្លាប់វ៉ៃបានបួនដងបន្ទាប់មកនាងក៏ហាមប្តីមិនអោយវ៉ៃ ព្រោះអាណិតកូន ហើយនាងក៏មិនដឹងថាវ៉ៃកូនព្រោះមូលហេតុអ្វីដែលដែរ។ បច្ចុប្បន្នកុមាររងគ្រោះត្រូវបានអង្គការ OSCC ខេត្តឈុនបុរី ទទួលយកទៅព្យាបាលនិងមើលថែបណ្តោះអាសន្ន ចំណែកឯម្តាយនិងឪពុកចុងត្រូវបានស្នងការតម្រួតខេត្តឈុនបុរីកំពុងធ្វើការសាកសួរលើហេតុការណ៍ហឹង្សានេះ។

## អាជ្ញាធរថៃចាប់ពលរដ្ឋខ្មែរសុំទាន ០៦នាក់

*https://prakpheaktra.blogspot.com/ 02-06-2019*

ប្រទេសថៃ: ស្ត្រីវ័យចំណាស់ និងក្មេងតូចចំនួន០៦នាក់ ត្រូវបានកម្លាំងអាជ្ញាធរថៃចាប់ខ្លួនបន្ទាប់ពីចំណាកស្រុកខុសច្បាប់ទៅអង្គុយសុំទាននៅក្នុងប្រទេសថៃ។ យោងតាមការរបាយការណ៍បានអោយដឹងថាពលរដ្ឋខ្មែរទាំង

អស់ នៅវេលាម៉ោង០៥ល្ងាច ថ្ងៃអាទិត្យទី០២ ខែមិថុនា ឆ្នាំ២០១៩ កម្លាំងអាជ្ញាធរសង្កាត់បាងខុនធៀន ទីក្រុងបាងកក ប្រទេសថៃបានចុះធ្វើការឃាត់ខ្លួនពលរដ្ឋខ្មែរចំនួន០៦នាក់ខណៈពេលកំពុងអង្គុយសុំទានជាមួយ និងក្មេងតូចនៅចិញ្ចើមផ្លូវ និងតាមស្ពានឆ្លងផ្លូវនានាក្នុងសង្កាត់បាងខុនធៀន។ តាមការបញ្ជាក់របស់សមត្ថកិច្ចថៃពលរដ្ឋខ្មែរទាំងអស់ជាជនអន្តោប្រវេសន៍ចំណាកស្រុកខុសច្បាប់ចូលប្រទេសថៃ តាមរយៈច្រកអន្តរជាតិខ្លងឡឹកស្រុកអារញ្ញប្រាថេតខេត្តស្រះកែវ បច្ចុប្បន្នសមត្ថកិច្ចកំពុងកសាងសំណុំរឿងដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## ឃាត់ខ្លួនពលករចំណាកស្រុកខុសច្បាប់ ជិត៣០នាក់

*https://prakpheaktra.blogspot.com/* *01-06-2019*

ខេត្តឈុនបុរីៈកាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ កន្លងទៅ កម្លាំងសមត្ថកិច្ចចម្រុះថៃប្រចាំ ខេត្តឈុនបុរី ប្រទេសថៃ បើកកិច្ចប្រតិបត្តិការចុះត្រួតពិនិត្យពលករខុសច្បាប់នៅតំបន់ណាគៀ ស្រុកបាងឡាម៉ុង ក្នុងខេត្តឈុនបុរី បន្ទាប់ពីមានពលរដ្ឋថៃ រាយការណ៍អំពីពលករបរទេសដណ្តើមមុខរបររកស៊ីរបស់ពលរដ្ឋថៃនៅក្នុងខេត្តឈុនបុរី ។ ក្នុងប្រតិបត្តិការចុះត្រួតពិនិត្យទីតាំងសង្ស័យមួយចំនួននៅក្នុងខេត្តឈុនបុរី កម្លាំងសមត្ថកិច្ចបានរកឃើញពលករបរទេសសរុបចំនួន២៣៥នាក់ ក្នុងនោះមានពលករខុសច្បាប់ចំនួន ២៣នាក់ ធ្វើការដោយគ្មានច្បច្បាប់អនុញ្ញាតចំនួន០២នាក់ ពលករខុសច្បាប់ត្រូវបានកម្លាំងសមត្ថកិច្ចអន្តោប្រវេសន៍ថៃនាំខ្លួនយកទៅធ្វើការសួរដើម្បីកសាងសំណុំរឿងចាត់វិធានការណ៍តាមផ្លូវច្បាប់។

## សមកិច្ចថៃបានធ្វើការចុះបង្ក្រាបចាប់សំបុកមេខ្យល់បញ្ជូនពលករខុសច្បាប់

https://www.facebook.com/ ព័ត៌មាន ពលករ ឆ្លងដែន 02-06-2019 11:28 AM •

សមកិច្ចថៃបានធ្វើការចុះបង្ក្រាបចាប់សំបុកមេខ្យល់បញ្ជូនពលករខុសច្បាប់ទុកនៅក្នុងផ្ទះជួលមួយកន្លែង នៅក្នុងតំបន់ខេតផ្លូវចូលលេខ265 ផះតង់ ស្រុកហាត់យ៉ៃ ខេត្តសុងក្លា នៅប្រទេសថៃ ក្នុងការចុះត្រួតពិនិត្យរបស់សមកិច្ចថៃនេះដែរបានឲ្យឃើញថាសមកិច្ចថៃចាប់បានពលរដ្ឋជនជាតិភូមានៅប្រទេសថៃខុសច្បាប់ចំនួន47នាក់ ។

## ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩

## ពលករខ្មែរ ក្នុងប្រទេសកូរ៉េ មកធ្វើការនៅទីនេះ មិនមែនមកយកតែលុយទេ ត្រូវរៀនសូត្រ ពង្រឹងវិជ្ជាជីវៈ យកចំណេះ ជំនាញទាំងនេះ ត្រឡប់ទៅកម្ពុជាវិញ

http://www.cen.com.kh/archives/ June 4, 2019

កូរ៉េ ៖ ប្រធានរាជបណ្ឌិត្យសភាកម្ពុជា បានធ្វើបទបង្ហាញ ដល់បងប្អូនពលករខ្មែរ ក្នុងប្រទេសកូរ៉េខាងត្បូង ថា យើងមកធ្វើការនៅទីនេះ គឺមិនមែនមកយក តែលុយតែមួយមុខនោះទេ ប៉ុន្តែត្រូវរៀនសូត្រ ពង្រឹងវិជ្ជាជីវៈ ដើម្បីយើងអាចយកចំណេះ ជំនាញទាំងនេះ ត្រឡប់ទៅកម្ពុជាវិញ ស្របពេលបច្ចុប្បន្ននេះ មានពលករខ្មែរសរុបជាង៦ម៉ឺននាក់ កំពុងធ្វើការនៅកូរ៉េនេះ ដែលបាននាំសាច់ប្រាក់ ចូលកម្ពុជាវិញ មានប្រមាណជា ៦០០លានដុល្លារអាម៉េរិក ក្នុងមួយឆ្នាំៗ។

ក្រោមកិច្ចសហការរបស់ លោកឡុងឌី ម៉ង់ ឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសកូរ៉េ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈថេគូ លោកបណ្ឌិត្យសភាចារ្យ សុខ ទូច បានធ្វើបទបង្ហាញស្តីពី «ដំណើរប្រព្រឹត្តទៅរបស់រាជរដ្ឋាភិបាលមុននឹងក្រោយការបោះឆ្នោតអាណត្តទី៦» នៅខេត្ត ថេគូ ប្រទេសកូរ៉េ។ នៅក្នុងកិច្ចចាប់ផ្តើម លោកឯកអគ្គរាជទូត បានលើកឡើងអំពីតួនាទី ដែលពលករមកធ្វើការនៅទីនេះ ត្រូវយកចិត្តទុកដាក់ និងត្រូវសហការជាមួយស្ថានទូត ហើយក្រោយពេលចប់អាណត្តិ ត្រូវរូតរះវិលត្រឡប់ទៅកម្ពុជាវិញ ម្យ៉ាងវិញទៀតក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែននាយករដ្ឋមន្ត្រី លោកតែងយកចិត្តទុកដាក់ដល់ សុខទុក្ខបងប្អូនពល

ករខ្មែរដែល ធ្វើការនៅក្រៅប្រទេស ជាងនេះទៅទៀត រដ្ឋាភិបាលកម្ពុជាបានធ្វើការ យ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាលកូរ៉េ ដើម្បីបង្កើនកូតាសម្រាប់ពលករខ្មែរយើង។ ជាក់ស្តែងនាពេលបច្ចុប្បន្ននេះ មានពលករខ្មែរសរុបជាង៦ម៉ឺន នាក់កំពុងធ្វើការនៅកូរ៉េនេះ ហើយស្ត្រីខ្មែរដែលមានស្វាមី ជាជនជាតិកូរ៉េ មានចំនួនចន្លោះពី៧ ទៅ៨ពាន់នាក់។ ក្នុងមួយឆ្នាំៗ មានពលករខ្មែរជាង៨ពាន់នាក់ ត្រូវមកធ្វើការនៅកូរ៉េ ដែលបាននាំសាច់ប្រាក់ ចូលកម្ពុជាវិញ មានប្រមាណជា៦០០លានដុល្លារអាមេរិកក្នុងមួយឆ្នាំៗ។

នៅក្នុងបទបង្ហាញនោះ លោកបណ្ឌិតសភាចារ្យ លើកឡើងពីការផ្តើមទំនាក់ទំនងឡើងវិញរវាងកម្ពុជា កូរ៉េនៅឆ្នាំ១៩៩៦ ដោយការខិតខំប្រឹប្រែងរបស់សម្តេច បើទោះជាស្ថានភាពពេលនោះកម្ពុជាមានទំនាក់ទំនងល្អជាមួយកូរ៉េខាងជើងក្តី សម្តេចតេជោហ៊ុន សែនបានពង្រឹងទំនាក់ទំនងនេះ បន្តិចម្តងៗរហូតដល់មាន ការឯកភាពគ្នាផ្តល់ភាពងាយស្រួល ដល់បងប្អូនមកធ្វើការនៅកូរ៉េនេះ។ ចំពោះ ស្ថានភាពនយោបាយបច្ចុប្បន្ននៅកម្ពុជា លោកបណ្ឌិតសភាចារ្យ បានគូសបញ្ជាក់ផងដែរថា «កម្ពុជាកំពុងតែដើរនៅ លើផ្លូវមួយដ៏ត្រឹមត្រូវ តាមគន្លងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ព្រោះនាអាណត្តិទី៦នេះ មានគណបក្សជាច្រើន បានចូលរួមប្រកួតប្រជែងបោះឆ្នោត។ កម្ពុជា បានគោរពតាមរដ្ឋធម្មនុញ្ញរបស់ខ្លួន។ រីឯស្ថានភាពសេដ្ឋកិច្ចក៏មានភាពរីកចម្រើនផងដែរ ក្នុងរង្វង់ប្រមានជា៧%ក្នុងមួយឆ្នាំ។» រដ្ឋាភិបាលអាណត្តិទី៦ ប្រើប្រាស់គោលនយោបាយ បើកចំហជើងមេឃ យ៉ាងទូលាយ ព្រោះថាកម្ពុជារឹតចមណងមិត្តភាពជាមួយប្រទេសទាំងអស់ ជាមិត្តមិនថា អាម៉េរិក ចិន ជប៉ុន កូរ៉េ ឬអឺរ៉ុបនោះទេ សំខាន់ឱ្យតែប្រទេសទាំងនោះ ផ្តល់នូវផលប្រយោជន៍ជូនដល់កម្ពុជា។ » លោកបណ្ឌិតសភាចារ្យបានបន្ថែម។ មុននឹងបិទបញ្ចប់បាឋកថា លោកបណ្ឌិតសភាចារ្យ បានផ្តល់ជាគំនិតដល់ពលករខ្មែរថា «យើងមកធ្វើការនៅទីនេះ គឺមិនមែនមកយកតែលុយតែមួយមុខនោះទេ ប៉ុន្តែត្រូវរៀនសូត្រ ពង្រឹងវិជ្ជាជីវៈ ដើម្បីយើងអាចយកចំណេះ ជំនាញទាំងនេះ ត្រឡប់ទៅកម្ពុជាវិញ ជាជាងយកតែទស្សនៈនយោបាយចូលស្រុក ឬជឿស្លុងទៅលើការឃោសនា របស់ក្រុមមួយចំនួន។»

សូមជម្រាបជូនថា លោកបណ្ឌិត្យសភាចារ្យ សុខ ទូច ដឹកនាំប្រតិភូរាជបណ្ឌិត្យសភាកម្ពុជា ទៅចូលរួមក្នុងវេទិកា កោះជេជូ ស្តីពី«គោលនយោបាយ សម្លឹងមកទិសខាងត្បូងរបស់កូរ៉េ» និងបំពេញទស្សនកិច្ចស្រាវជ្រាវ នៅតាមគ្រឹស្ថានរដ្ឋនិងឯកជនមួយចំនួន ក្នុងសាធារណរដ្ឋកូរ៉េ ចំនួន៩ថ្ងៃ ពីថ្ងៃទី២៨ខែឧសភា ដល់ថ្ងៃទី៥ខែមិថុនា ឆ្នាំ២០១៩៕ ដោយៈកូឡាប

## ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩

### ចូលរួមទប់ស្កាត់ សកម្មភាព បទល្មើសនានាៗតាមតំបន់ព្រំដែន និងសកម្មភាពឆ្លងដែន ខុសច្បាប់

http://nokorwatnews.com/archives/ 04-06-2019

ភ្នំពេញ៖ ក្នុងកិច្ចប្រជុំបូកសរុប ការងារខែ ឧសភា និងលើកទិស ដៅបន្ត ប្រចាំខែមិថុនា ឆ្នាំ ២០១៩ របស់ក្រសួងការពារជាតិដែ លប្រព្រឹត្តទៅ កាលពីថ្ងៃទី អង្គារ ២ កើត ខែ ជេស្ឋ ឆ្នាំកុរ ឯក ស័ក ព.ស ២៥ ៦៣ ត្រូវថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៩ ពិធីនេះប្រព្រឹត្តទៅក្រោមអធិបតីភាព នាយឧត្តមសេនីយ៍ នាង ផាត រដ្ឋលេខាធិការ ក្រសួងការពារជាតិ ព្រមទាំងវត្តមាននាយទា ហានមកពីស្ថាប័នកងឯកភាពនានាចំណុះក្រសួង អគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ (ខ. ភ.ម)អនុវត្តតាមកម្មវិធីនយោបាយ យុទ្ធសាស្ត្រចតុ កោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល កម្មវីធីការងារ ផែនការកែទម្រង់ (ខ.ភ.ម) រយៈពេល៥ឆ្នាំ (២០១៥ -២០១ ៩) ក្រសួងការពារជាតិ ដាក់ចេញទិសដៅការងារដូចខាងក្រោម: បន្តកសាងពង្រឹងប្រៀបការពារជាតិ លើគ្រប់វិស័យ ដើម្បីការពារអធិបតេយ្យបូរណភាពទឹកដី សុខសន្តិភាព ជូនសង្គមជាតិ ព្រមទាំងចូលរួមទប់ស្កាត់សកម្មភាពបទល្មើសនានាៗតាមតំបន់ព្រំដែន និងសកម្មភាពឆ្លងដែនខុសច្បាប់ ។ ទន្ទឹមនិងនេះ បន្តកិច្ចសហ ប្រតិបត្តិការល្អ ថែមទៀតជាមួយប្រទេសជិតខាង និងដោះស្រាយបញ្ហាផ្សេងៗដែលកើតឡើង ដោយសន្តិវិធី ។

ក្នុងរបាយការណ៍ខែ ឧសភា បានដាក់ចេញទិសដៅ ខែ មិថុនា ឆ្នាំ ២០១៩ របស់ក្រសួងការពារជាតិអាន ដោយលោកឧត្តម សេនីយ៍ឯក ចាន់ សារាង អគ្គលេខាធិការរង អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ និងជានាយក នាយកដ្ឋានសរុប លើកឡើងពីចំណុចខ្លាំង ខ្សោយ និងវិធានការរបស់ក្រសួងលើការដឹកនាំបញ្ជា ទទួលលទ្ធផលគាប់ ប្រសើរ ត្រូវបានថ្នាក់ដឹកនាំ ស្ថាប័នពាក់ពាន់កោតសរសើរស្មាដៃនេះ និងតម្រង់ទិសតាម អ្វីដែលផ្តល់ផល ប្រយោជន៍ ដល់សង្គម ។ ទប់ស្កាត់និងបង្ក្រាប ឲ្យបានដាច់ខាត សកម្មភាព ភេរវកម្មធានា មិនឱ្យមានបដិវត្តន៍ ពណ៌កើតឡើង ក្នុងប្រទេសកម្ពុជា ជាដាច់ខាត ទោះក្នុងតម្លៃណាក៏ដោយ ។

ក្នុងកិច្ចប្រជុំនោះ នាយឧត្តមសេនីយ៍ នាង ផាត បន្តថា: សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការ ពារជាតិ លើកឡើងក្នុងកិច្ចប្រជុំកិច្ចប្រជុំកំពូលសន្តិសុខ អាស៊ីលើកទី១៨ នៅសណ្ឋាគារសាំងហ្គ្រីឡា ប្រទេសសឹង្ហបុរីក៏ដូចជាលើកមុនៗដែរ បណ្តារដ្ឋមន្ត្រីការពារជាតិអាស៊ាន ប្រមូលផ្តុំទស្សនៈផ្ទាល់ខ្លួន ពីអ្វីដែលកំពុងប្រឈម និងដោះស្រាយព្រម ទាំងមានកិច្ចប្រជុំ ដោយឡែកៗក ជាមួយភាគីពាក់ព័ន្ធនិងឯកភាព បញ្ចូលអាស៊ាន ជាមជ្ឈមណ្ឌលមានកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ ។ ដោយឡែកការកែទម្រង់ឋានន្តរសក្តិ ក្នុង (ខ.ភ. ម)មានផែនការណ៍យុទ្ធសាស្ត្រយូរ អង្វែងជាជំហានៗ ដើម្បីកសាងកងទ័ព មួយមាន គុណភាព និង ប្រសិទ្ធភាព ដឹក នាំបញ្ជាឲ្យស្របតាមការវិវឌ្ឍ នៃសភាពការណ៍ជាតិ និងអន្តរជាតិ ។

បន្ទាប់ពីស្ថាប័ន កងឯកភាព មានចំណាប់អារម្មណ៍ លើចំណុចសេសសល់ និងបំពេញ បន្ថែមក្នុងរបាយ ការណ៍រួចមក គណៈអធិបតី បានវាយតម្លៃពីសភាពការរួម ព្រមទាំងដាក់ចេញវិធានការនានាសំដៅពង្រឹងប្រៀបការពារជាតិ ឲ្យកាន់តែប្រសើរទ្វេឡើងថែមមួយកម្រិតទៀតផងដែរ ៕ សុខដុម

## របាយការណ៍បង្ហាញថា របរពេស្យាចារ រីកចម្រើនខ្លាំងតាមបណ្តាញអ៊ីនធើណែត

http://km.rfi.fr/society-culture/ ដោយ ម៉ម ពិសី 04/06/2019

អង្គការក្រៅរដ្ឋាភិបាលបារាំងមួយ ដែលធ្វើការទាក់ទិនសកម្មភាពពេស្យាចារ ការជួញដូរផ្លូវភេទ បានចេញរបាយការណ៍មួយ ដែលបង្ហាញថា មុខរបរពេស្យាចារ កំពុងតែរីកចម្រើនយ៉ាងខ្លាំង តាមរយៈបណ្តាញអ៊ីនធើណែត បណ្តាញសង្គម និងកម្មវិធីឆ្លើយឆ្លងគ្នា លើទូរសព្ទ័។ របាយការណ៍នេះ បានទាញសញ្ញាអាសន្ន ឲ្យអាជ្ញាធរគ្រប់ប្រទេសទាំងអស់ ត្រូវរកវិធីទប់ស្កាត់ ការប្រើប្រាស់បណ្តាញអ៊ីនធើណែត ធ្វើជាទីផ្សារ ទាក់ទាញជនរងគ្រោះជាស្ត្រី និងអតិថិជនដែលស្វែងរកសេវាផ្លូវភេទ។

កម្មវិធីឆ្លើយឆ្លងលើទូរសព្ទ័ បណ្តាញសង្គម កម្មវិធីផ្ញើសារ ចែកចាយរូបថត ទាំងអស់នេះ កំពុងតែក្លាយទៅជាមធ្យោបាយ ក្នុងការធ្វើសកម្មភាពរកស៊ីផ្លូវភេទ ពេស្យាចារ យ៉ាព្រោងព្រាត នឹងដោយសុវត្ថិភាពបំផុត។ របាយការណ៍របស់ មូលនិធិ Scelles (**Fondation Scelles**) - **Système Prostitutionnel : Nouveaux défis, nouvelles réponses** ដែលស្រាវជ្រាវទៅលើប្រទេសចំនួន៣៥ បានលើកឡើងថា អំពើពេស្យាចារ និងការជួញដូរផ្លូវភេទ កំពុងតែក្លាយជាឧស្សាហកម្មយ៉ាងសំបូរបែប និងរីកចម្រើន នៅលើបណ្តាញ អ៊ីនធើណែត។

យោងតាមរបាយការណ៍ កម្រាស់៥០០ទំព័រនេះ អំពើពេស្យាចារដោយប្រើប្រាស់បណ្តាញអ៊ីនធើណែត មានស្មើនឹង២ភាគ៣ នៃសកម្មភាពពេស្យាចារជារួម។ លោក Yves Charpenel ចៅក្រមបារាំង និងជាប្រធានមូលនិធិScelles បានលើកឡើងថា ការរកស៊ីផ្លូវភេទតាមអ៊ីនធើណែត បានត្របាក់យកទីផ្សារនៃរបរពេស្យាចារនៅតាមផ្លូវ។ លោកបន្ថែមថា បណ្តាញអ៊ីនធើណែត បានបង្កភាពងាយស្រួល រហ័ស ស្ងាត់អាថិកំបាំង ហើយអាចពង្រីកវិសាលភាពនៃសកម្មភាពជួញដូរផ្លូវភេទ បានយ៉ាងងាយ។ មិនត្រឹមតែប៉ុណ្ណោះ មេខ្យល់ ឬអ្នកម៉ៅការ អាចប្រើប្រាស់បណ្តាញអ៊ីនធើណែត ដើម្បីទាក់ទាញស្ត្រីរងគ្រោះ ឲ្យធ្លាក់អន្ទាក់ ក្លាយជាស្ត្រីរកស៊ីផ្លូវភេទ និងអាចលាងសំអាតប្រាក់ចំណូល ដែលបានមកពី

សកម្មភាពខុសច្បាប់នេះ។ Facebook WhatsApp Instagram Snapchat ទាំងអស់នេះ សុទ្ធតែជាប្រព័ន្ធកម្មវិធីទូរស័ព្ទ ដែលក្រុមឈ្មួញប្រើប្រាស់ ដើម្បីធ្វើសកម្មភាពរើសមនុស្ស និងទាក់ទាញអតិថិជន ដែលស្វែងរកសេវាកម្មផ្លូវភេទ។ នៅអ៊ីស្រាអែលកម្មវិធី Tinder បានក្លាយជាកម្មវិធីទូរស័ព្ទ ដ៏ពេញនិយមជាងគេ ដើម្បីស្វែងរកសេវាកម្មផ្លូវភេទ។

របាយការណ៍ បានរំលឹកខ្លះៗ ពីករណីបង្ក្រាបបណ្តាញជួញដូរផ្លូវភេទ តាមអ៊ីនធើនែត ដូចជា ករណីបង្ក្រាបបណ្តាញដ៏ធំនៅអេស្ប៉ាញ នៅឆ្នាំ២០១៧ ដែលឈ្មួញទុច្ចរិត រកស៊ីនៅលើប្រព័ន្ធ WhatsApp។ មេខ្យល់ជាស្ត្រីជនជាតិរុស្ស៊ីម្នាក់ ត្រូវបានចាប់ឃាត់ខ្លួន ដែលតាមការសង្ស័យ គឺជាស្ត្រីរូបនេះ បានទាក់ទាញស្ត្រីរងគ្រោះជាច្រើននាក់ នៅតំបន់ដើមបូព៌ា ឲ្យធ្វើជាស្ត្រីបំរើផ្លូវភេទ។ នៅឆ្នាំ២០១៧ដែរ អាជ្ញាធរថៃ បានបង្ក្រាបបណ្តាញជួញដូរផ្លូវភេទមួយដ៏ធំ ដែលប្រើប្រាស់ប្រព័ន្ធFacebook ជាមធ្យោបាយរកស៊ី។ ក្នុងនោះមានមេជួញដូរមនុស្ស ចំនួន៩នាក់។ នៅបារាំងកាលពីខែកក្កដាឆ្នាំ២០១៨ មនុស្សចំនួន១២នាក់ ត្រូវបានតុលាការផ្តន្ទាទោស ពីបទធ្វើសកម្មភាពពេស្យាចារ និងជួញដូរផ្លូវភេទលើស្ត្រីវ័យក្មេង ដោយប្រើប្រាស់ បណ្តាញ Instagram និងSnapchat៕

## ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩

## លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញជាអធិបតីភាពបើកវគ្គបណ្តុះបណ្តាលគោលការណ៍ណែនាំស្តីពីបែបបទនីតិវិធីនៃការកំណត់សញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស

https://www.facebook.com/ Cambodia Migrant Labour Group - CMLG **June 3 at 3:14 PM** •

(សាលាខេត្តត្បូងឃ្មុំ)៖ ថ្ងៃពុធ ១១រោច ខែពិសាខ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ នៅសាលប្រជុំសាលាខេត្ត លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធានអចិន្ត្រៃយ៍បានអញ្ជើញជាអធិបតីភាពបើកវគ្គបណ្តុះបណ្តាលគោលការណ៍ណែនាំស្តីពីបែបបទនីតិវិធីនៃការកំណត់សញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប និងមានវត្តមានជាគណៈអធិបតីក្នុងកម្មវិធី មានលោកជំទាវឧត្តមសេនីយ៍ឯក អគ្គលេខាធិការគ.ជ.ប.ជ ព្រះរាជអាជ្ញារងខេត្ត លោកស្រីអភិបាលរង តំណាងអង្គការយូអិនវូមិន (UN Woman) ។ សមាសភាពសិក្ខាកាមអញ្ជើញចូលរួមក្នុងវគ្គនេះ មានមន្ត្រីរដ្ឋបាលសាលាខេត្ត សមាជិកគ.ខ.ប.ជ ស្នងការរង មេបញ្ជាការរងខេត្ត ប្រធាន/អនុប្រធាន មន្ទីរដែលពាក់ព័ន្ធក្រុមការងារជំនាញអន្តរក្រសួង អភិបាល/អភិបាលរងស្រុកជុំវិញខេត្ត សមាជិកគ.ស.ក.សក្រុង/ស្រុក អង្គការដៃគូអនុវត្តការងារ សរុបប្រមាណ៥០នាក់។

វគ្គបណ្តុះបណ្តាលនេះធ្វើឡើងក្នុងគោលបំណង ពង្រឹងសមត្ថភាពដល់មន្ត្រីដែលពាក់ព័ន្ធ និងផ្សព្វផ្សាយបន្តនៅសកម្មភាពអនុវត្តការងារ និងជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឲកាន់តែមានប្រសិទ្ធភាពខ្ពស់ ៕

## កំពូលបង្វិលសំណុំរឿងនាំនារីរៀបការប្តីចិន ឲ្យឧទ្ធរណ៍ជម្រះជាថ្មី

https://www.postkhmer.com/ គឹម សារុំ | Publication date 06 June 2019 | 08:32 ICT

**ភ្នំពេញៈ** តុលាការកំពូលកាលពីម្សិលមិញ បានសម្រេចបង្វិលសំណុំរឿងស្ត្រីជាប់ចោទម្នាក់ឲ្យសាលាឧទ្ធរណ៍ជម្រះឡើងវិញ បន្ទាប់ពីបើកសវនាការកាលពីថ្ងៃទី ២៩ ខែ ឧសភា ពាក់ព័ន្ធនឹងករណីនាំស្ត្រីខ្មែរ ២ នាក់ ទៅរៀបការប្តីនៅប្រទេស ចិន ប្រព្រឹត្តកាលពីឆ្នាំ ២០១៥ នៅខេត្តបន្ទាយមានជ័យ។ ខណៈអវត្តមានស្ត្រីជាប់ចោទ លោកចៅក្រម គ្រង់ ស្រ៊ីម បានប្រកាសសាលដីកាពីម្សិលមិញថា សំណុំរឿងនេះមានស្ត្រីជាប់ចោទឈ្មោះជិន ពន្លឺដែលជាប់ចោទពីបទលក់ដូរមនុស្សសម្រាប់ឆ្លងដែន។ លោកថា បន្ទាប់ពីជំនុំជម្រះកាលពីថ្ងៃទី ២៩ ខែ ឧសភា មក គឺតុលាការយល់ថាក្រោយពីបានស្តាប់ការឆ្លើយបំភ្លឺរបស់ស្ត្រីជាប់ចោទ និងក្រោយពីបានស្តាប់ការសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទមកតុលាការកំពូលយល់ថា សាលាឧទ្ធរណ៍បានជំនុំជម្រះមិនទាន់ត្រឹមត្រូវតាមទម្រង់ច្បាប់នៅឡើយទេ។

លោកថា៖ «ដូច្នេះតុលាការកំពូលសម្រេចបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ចោល ហើយបង្វិលសំណុំរឿងទៅឧទ្ធរណ៍ជម្រះសាជាថ្មីឡើងវិញ»។ ពាក់ព័ន្ធនឹងការបង្វិលសំណុំរឿងឲ្យសាលាឧទ្ធរណ៍ជម្រះឡើងវិញនេះ កាលពីម្សិលមិញលោកស្រី លុយ សុធី ដែលជាមេធាវីការពារសិទ្ធិឲ្យស្ត្រីជាប់ចោទបានបង្ហាញការសោទរចំពោះការសម្រេចរបស់តុលាការកំពូលនាពេលនេះ។

លោកស្រី មេធាវី បានបញ្ជាក់ថា៖ «ខ្ញុំជាមេធាវីគឺខ្ញុំការពារក្តីតាមវិជ្ជាជីវៈតែប៉ុណ្ណោះ ហើយខ្ញុំមិនប្រកាន់ថាកូនក្តីមានឬក្រទេ ខ្ញុំប្រឹងប្រែងការពារក្តីតាមសមត្ថភាពរបស់ខ្ញុំ។ តុលាការកំពូលលោកសម្រេចនេះ គឺលោកផ្អែកលើច្បាប់ និងភ័ស្តុតាងគឺជាយុត្តិធម៌សម្រាប់កូនក្តីខ្ញុំ»។

កាលពីថ្ងៃជំនុំជម្រះនៅតុលាការកំពូល ស្ត្រីជាប់ចោទបានឆ្លើយប្រាប់ចៅក្រមថា កាលពីអំឡុងឆ្នាំ ២០១៥ មានស្ត្រីម្នាក់ឈ្មោះសាន បានមកអង្គុយលេងនៅផ្ទះរបស់គាត់ ហើយគាប់ជួនពេលនោះស្ត្រីជាបងថ្លៃរបស់គាត់នៅប្រទេសចិនបានទូរស័ព្ទមកគាត់ ខណៈស្ត្រីឈ្មោះ សាន ក៏កំពុងអង្គុយក្បែរនោះដែរ។ បន្ទាប់ពីបញ្ចប់ការសន្ទនាតាមទូរស័ព្ទ ស្ត្រីឈ្មោះសានបាននិយាយជាមួយគាត់ថា បើមានបងប្អូននៅចិនឲ្យជួយកូនស្រីរបស់ស្ត្រីឈ្មោះ ភាព ចំនួន ២ នាក់ឲ្យបានទៅធ្វើការនៅប្រទេសចិនផង។

ស្ត្រីជាប់ចោទបន្តថា ក្រោយមកស្ត្រី ឈ្មោះសាន បាននាំនារី ២ នាក់ ដោយម្នាក់ ឈ្មោះ ប៉ាង ស្រីពៅ អាយុ ១៧ ឆ្នាំ និងម្នាក់ឈ្មោះ ប៉ាង ណារី អាយុ ២៦ ឆ្នាំ ត្រូវជាកូនរបស់ស្ត្រី ឈ្មោះ ភាព ហើយគាត់ (ស្ត្រីជាប់ចោទ) ក៏បានឲ្យលេខទូរស័ព្ទរបស់បងស្រីនៅចិនទាក់ទងគ្នារហូតជួយបានរៀបការប្តីទៅចិនតែម្តង។ ប៉ុន្តែ ក្រោយពីនារីរងគ្រោះ ជាប្អូនទៅប្រទេសចិនបាន ១០ ខែ ក្នុងឆ្នាំ ២០១៦ ក៏បានត្រឡប់មកប្រទេសកម្ពុជាវិញ ហើយពេលនោះស្ត្រីឈ្មោះភាពជាម្តាយនារីរងគ្រោះគ្មានលុយធ្វើដំណើរមកទទួលកូនក៏ប្រាប់ទៅអង្គការមួយនៅក្នុងឃុំឲ្យជួយមកទទួលកូនជំនួស។ លុះពេលមកដល់ផ្ទះស្រាប់តែអង្គការនោះប្តឹងចាប់គាត់តែម្តង។ ស្ត្រីជាប់ចោទនិយាយថា គាត់ត្រូវបានសាលាដំបូងខេត្តបន្ទាយមានជ័យប្រកាសសាលក្រមនៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៧ ដោយផ្តន្ទាទោស ១៥ ឆ្នាំ និងបង្គាប់ឲ្យសងទៅនារីរងគ្រោះម្នាក់ៗ ៥ លានរៀល។ បន្ទាប់មកគាត់ប្តឹងមកសាលាឧទ្ធរណ៍ ហើយក៏ត្រូវសាលាឧទ្ធរណ៍ប្រកាសសាលដីកានៅថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៨ ដោយតម្កល់ទោស ១៥ ឆ្នាំដដែល ទើបឈានដល់ការប្តឹងសារទុក្ខមកកាន់តុលាការកំពូលតែម្តង៕

## ថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ០៤នាក់ ឲ្យមកកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI 05-06-2019

កោះកុង៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៦និង០០នាទី ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃ ចំនួន ០៤នាក់។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ០១នាក់ ឲ្យមកកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI 05-06-2019

ឧត្តរមានជ័យ៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិជាំ នាថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០១នាក់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

## លោក Samak Tubtanee មន្ត្រីនៃអង្គការមូលនិធិលើកកម្ពស់គុណភាពជីវិតពលករ (LPN) ទទួលបានរង្វាន់លើកទឹកចិត្តពី លោកនាយករដ្ឋមន្ត្រីថៃ

https://www.facebook.com/ Cambodia Migrant Labour Group - CMLG 05-06-2019

លោក Samak Tubtanee មន្ត្រីនៃអង្គការមូលនិធិលើកកម្ពស់គុណភាពជីវិតពលករ (LPN) ទទួលបានរង្វាន់លើកទឹកចិត្តពី លោកនាយករដ្ឋមន្ត្រីថៃ ប្រយុទ្ធ ចាន់ អូចា នៅក្នុងទិវាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំឆ្នាំ2019 ដែលបានប្រារព្ធធ្វើឡើងនៅព្រឹកថ្ងៃពុធទី០៥ ខែមិថុនាឆ្នាំ២០១៩ ក្នុងសណ្ឋាគារ Centra កណ្តាលទីក្រុងបាងកក ប្រទេសថៃ ចំពោះរង្វាន់ ដែលលោក Samak Tubtanee បានទទួលនោះគឺជារង្វាន់បុគ្គលមានស្នាដៃជួយជនរងគ្រោះដោយសារអំពើជួញមនុស្ស គួរបញ្ជាក់ផងដែរថាកក្នុងរយៈពេលកន្លងមកលោក Samak Tubtanee បានជួយអន្តរាគមន៍ពលករបរទេសមានដូចជា ខ្មែរ,ឡាវ និងភូមា ចំនួនរាប់រយនាក់ដែលរងគ្រោះដោយសារអំពើជួញដូរមនុស្សក្នុងប្រទេសថៃ បច្ចុប្បន្នលោក Samak Tubtanee ជាមន្ត្រីនៃអង្គការលើកកម្ពស់គុណភាពជីវិតពលករ ឬហៅកាត់ថា (LPN) ដែលមានទីតាំងនៅក្នុងស្រុកមហាឆៃ ខេត្តសាមុតសាខេន ។

## រថយន្តដឹកពលករខ្មែរទៅព្រំដែន បុកគូថរថយន្តដឹកដែក ពលកររងរបួសធ្ងន់ម្នាក់

https://prakpheaktra.blogspot.com / 2019/06/06

ខេត្តចាន់បុរី៖ យោងតាមរបាយការណ៍ពីកម្លាំងសមត្ថកិច្ចខេត្តចាន់បុរី ប្រទេសថៃ បានអោយដឹងថា នៅវេលាម៉ោង០៥:៥៥នាទី ព្រលឹមថ្ងៃព្រហស្បតិ៍ទី០៦ ខែមិថុនា ឆ្នាំ២០១៩ មានករណីរថយន្តឈ្នួលដឹកពលករកម្ពុជាទៅព្រំដែនបានជួបគ្រោះថ្នាក់ចរាចរណ៍បុករថយន្តសណ្តោងដឹកបន្ទះដែក បណ្តាលឱ្យមានមនុស្សរងរបួសធ្ងន់ម្នាក់ បច្ចុប្បន្នជនរងគ្រោះត្រូវសមត្ថកិច្ចថៃបញ្ជូនយកទៅសង្គ្រោះនៅមន្ទីរពេទ្យបោងណាម័រន។

# ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩

## ក្រុងប៉ោយប៉ែត-ស្រុកអារញ្ញលើកនេះពិភាក្សាគ្នាផ្តោតលើបទល្មើសគ្រឿងញៀន និងពលករឆ្លងដែន

http://www.rasmeinews.com/ June 7, 2019, 8:13 AM

ដោយ:ប.ជ័យ/បន្ទាយមានជ័យ: មន្ត្រីរដ្ឋបាលប៉ោយប៉ែតខេត្តបន្ទាយមានជ័យប្រទេសកម្ពុជា និងសមភាគីរដ្ឋបាលស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ ប្រទេសថៃ លើកនេះបានឆ្លាស់វេនធ្វើម្ចាស់ផ្ទះជួបប្រជុំពិភាក្សាគ្នាផ្តោតលើបទល្មើសរឿងញៀនឆ្លងដែន ។

លោក គាត ហ៊ុល អភិបាលក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៩ បានដឹកនាំប្រតិភូក្រុងប៉ោយប៉ែតរួមមានមន្ត្រីរាជការចំណុះរដ្ឋបាលក្រុងនិងការិយាល័យអង្គភាពពាក់ព័ន្ធទៅចូលរួមប្រជុំពិភាក្សាទ្វេភាគីជាមួយរដ្ឋបាលស្រុកអារញ្ញប្រាថេត។ ដឹកនាំដោយលោក សាវ និតសុរិយកុលអយុធ្យា អភិបាលស្រុក នៅសណ្ឋាគារវេណ្ឌចិន ស្ថិតក្នុងស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ ព្រះរាជាណាចក្រថៃ ។ មន្ត្រីទៅចូលរួមប្រជុំបានប្រាប់កាសែតរស្មីកម្ពុជាថ្ងៃទី៦ ខែមិថុនាថា: "កិច្ចប្រជុំស្តីពីការបង្ក្រាប និងទប់ស្កាត់បទល្មើសគ្រឿងញៀនឆ្លងដែន(BLO)"។ តែក៏ពិភាក្សា និងពិនិត្យវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការនៃស្រុក ក្រុងសម្ព័ន្ធមេត្រីភាពទាំង២ លើបញ្ហាសន្តិសុខ ការបង្ក្រាបបទល្មើស ពាណិជ្ជកម្ម ទេសចរវប្បធម៌ បរិស្ថាន សុខាភិបាល សិក្សាអប់រំកីឡា ពលករឆ្លងដែន ជាដើម។S/

## ចាប់ខ្លួនថ្មីទៀតហើយ សមត្ថកិច្ចថៃចាប់ខ្លួនពលករ ដោយសារមេឈ្មួញឈើឆ្លងដែនសុទ្ធតែជាមន្ត្រីយោធា និងមន្ត្រីនគរបាលវរៈការពារព្រំដែនគោក លេខ៧០២

http://nokorwatnews.com/archives/ 06-06-2019

ខេត្តឧត្តរមានជ័យ៖ នៅក្នុងសង្កាត់អូស្មាច់ក្រុងសំរោងខេត្តឧត្តរមានជ័យ ដែលបានល្បីជាច្រើនឆ្នាំមកហើយ រឿងចរាចរណ៍បទល្មើសឈើប្រណីតឆ្លងដែន សំបូរទៅដោយអ្នកមានអំណាច ជាមន្ត្រីយោធា និងមន្ត្រីប៉ូលិសដែលឈរជើងនៅទីនោះ ដែលមានការប្រមូលប្រជាពលរដ្ឋចូលកាប់ឈើគ្រញូងដោយខុសច្បាប់នៅក្នុងទឹកដីថៃ ដែលជាមូលហេតុបណ្ដាលឲ្យប្រជាពលរដ្ឋជាច្រើននាក់ ត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួនយកទៅផ្ដន្ទាទោសតាមច្បាប់ប្រទេសថៃជាច្រើននាក់ និងជាបន្តបន្ទាប់ ។ ជាក់ស្ដែងនៅល្ងាចថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៩ បុរសម្នាក់ឈ្មោះសុខ តឿ ភេទប្រុស អាយុ៣២ឆ្នាំ រស់នៅភូមិដើមជ្រៅ សង្កាត់អូស្មាច់ ក្រុងសំរោង ត្រូវបានអាជ្ញាធរថៃចាប់ខ្លួនរួមនឹងវត្ថុតាងឈើក្រក់ ឈើគ្រញូងចំនួនពីរកូនដុំ និងបន្តនាំខ្លួនយកទៅចាត់ការអនុវត្តទៅតាមផ្លូវច្បាប់ប្រទេសថៃ ។

ប្រភពបានបង្ហើបឲ្យដឹងថា មេឈ្មួញប្រមូលទិញឈើប្រណីតឆ្លងដែនមកពីប្រទេសថៃ នៅក្នុងសង្កាត់អូស្មាច់ ដែលជាដើមហេតុ និងជាមូលហេតុបណ្ដាលឲ្យពលករជាច្រើនអ្នកត្រូវបានអាជ្ញាធរថៃចាប់ខ្លួននោះរួមមាន ឈ្មោះថន ជាមន្ត្រីនគរបាលវរៈការពារព្រំដែនគោក៧០២ កូនចៅរបស់លោកវរៈសេនីយ៍ឯក គង់ សុខាន់ ។ ប្រភពបានបង្ហើបថា មេឈ្មួញរូបនេះ ត្រូវបានលោកមេបញ្ជាការនៅពីក្រោយខ្នង ព្រោះរកស៊ីចរាចរណ៍ឈើប្រណីតឆ្លងដែនច្រើនឆ្នាំមកហើយ ដោយគ្មានការហាមឃាត់ពីមេបញ្ជាការ ។ ឈ្មោះ ឈឿង សក្ដ ជាមន្ត្រីយោធាបម្រើការងារនៅកងពលតូចលេខ៤២ កូនចៅរបស់លោកឧត្ដមសេនីយ៍ទោ ប៉ែន វយ ។ ប្រភពបានបង្ហើបឲ្យដឹងថា លោក ប៉ែន វយ ជាអ្នកបើកដៃឲ្យរកស៊ីបទល្មើស កន្លងទៅ ។ លោកឧត្ដមសេនីយ៍ទោ ប៉ែន វយ បានឲ្យអ្នកសាព័ត៌មានដឹងកន្លងទៅថា លោកដឹងខ្លះ មិនដឹងខ្លះ ចំពោះសកម្មភាពរកស៊ីបទល្មើសឈើឆ្លងដែនមន្ត្រីរបស់លោក ឈ្មោះ ឈឿង សក្ដ លោកបញ្ជាក់ថា បើចង់ចាប់ឲ្យចាប់ទាំងអស់គ្នា កុំឲ្យមានភាពលំអៀង ។ ឈ្មួញ ឈ្មោះធឿន ជាមន្ត្រីយោធា និងឈ្មួញ ឈ្មោះ ប៊ិប៊ី ជាមន្ត្រីយោធា ។ មេឈ្មួញប្រមូលទិញឈើប្រណីតទាំងបួននាក់ខាងលើនេះហើយជាអ្នកកៀងគរ ពលករកាប់ឈើប្រណីតនៅក្នុងទឹកដីថៃ ដែលជាដើមហេតុ និងជាមូលហេតុជាមេបញ្ជា បង្កឲ្យមាន អសន្តិសុខនៅតាមខ្សែ បន្ទាត់ព្រំដែន កម្ពុជា ថៃ នៅសង្កាត់អូស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ ក៏ព្រោះតែ ត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួន ពលករគ្មានស្រាកស្រាន្ត ជាច្រើននាក់ កន្លងទៅដោយគ្មានអ្នកទទួលខុសត្រូវ ។

ហេតុមកដល់ពេលនេះ ភាពអសន្តិសុខមកលើពលរដ្ឋនៅតែបន្តកើតមានជាហូរហែ និងអត់ឈប់ឈរ ។ ហេតុនេះ សូមលោកឧត្ដមសេនីយ៍ទោ ម៉ែន លី ស្នងការនគរបាលខេត្តឧត្តរមានជ័យ មានវិធានការផង ព្រោះល្បីឈ្មោះមេឈ្មួញចរាចរណ៍ឈើប្រណីតឆ្លងដែនទាំងបួននាក់ខាងលើ ។ ជាពិសេសមន្ត្រីប៉ូលិសឈ្មោះ ថន មេឈ្មួញឈើចរាចរណ៍ឈើឆ្លងដែន ក៏ជាមូលហេតុដ៏ធំផងដែរ ក្នុងការបង្កអសន្តិសុខហូតមក ៕ ប៉ែន នួន

# ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩

## ក្រសួងការងារណែនាំម្ចាស់សិប្បកម្មឡឥដ្ឋនូវវិធានការ៥ចំណុច ដើម្បីបញ្ចៀសគ្រោះថ្នាក់កើតឡើងលើកុមារ

http://www.freshnewsasia.com/index.php/ 2019-06-09

(ភ្នំពេញ)៖ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានចេញសេចក្ដីណែនាំស្ដីពី ការហាមក្មេងចូលទៅក្នុងបរិវេណខ្សែសង្វាក់ផលិតកម្ម នៃសិប្បកម្មផលិតឥដ្ឋ ជម្រាបដល់ម្ចាស់សិប្បកម្មផលិតឥដ្ឋនៅមូលដ្ឋាន ឱ្យអនុវត្ត

នូវវិធានការចំនួន៥ចំណុចធំៗ ដើម្បីបញ្ចៀសរាល់គ្រោះថ្នាក់នានា កុំឱ្យកើតមានលើកុមារដោយថាហេតុណាមួយនៅក្នុងបរិវេណសិប្បកម្ម។

**វិធានការណែនាំទាំង៥ចំណុចនោះ រួមមាន៖**

១៖ រៀបចំដាក់ស្លាកសញ្ញាធំៗ និងងាយមើលឃើញដូចជា៖ * ហាមក្មេងចូលទៅក្នុងបរិវេណខ្សែសង្វាក់ផលិតកម្ម * ជនណាដែលនៅក្មេងចូលទៅ ក្នុងបរិវេណខ្សែសង្វាក់ផលិតកម្ម អាចប្រឈមនឹងបទល្មើសព្រហ្មទណ្ឌ * ការប្រើប្រាស់ពលកម្មកុមារនៅសិប្បកម្មផលិតឥដ្ឋ គឺអាចប្រឈមនឹងបទល្មើសព្រហ្មទណ្ឌ។

២៖ ហាមឃាត់ដាច់ខាតការប្រើប្រាស់ទាសភាពបំណុល ដើម្បីដាក់បន្ទុកសេរីភាពការងារកម្មករ។

៣៖ ត្រូវមានអ្នកឃ្លាំមើលជាប្រចាំ និងហាមក្មេងចូលក្នុងបរិវេណខ្សែសង្វាក់ផលិតកម្ម ឬធ្វើការនៅក្នុងសិប្បកម្មផលិតឥដ្ឋ។

៤៖ ត្រូវរៀបចំកន្លែងស្នាក់នៅឱ្យឃ្លាតឆ្ងាយពីខ្សែសង្វាក់ផលិតកម្ម និងត្រូវមានរបងការពារសុវត្ថិភាព ដែលខណ្ឌចែកបរិវេណខ្សែសង្វាក់ផលិតកម្ម និងកន្លែងស្នាក់នៅ។

៥៖ ហាមឃាត់ដាច់ខាតរាល់ទម្រង់ នៃការកេងប្រវ័ញ្ចពលកម្មលើកុមារ និងការបង្ខំឱ្យកុមារធ្វើការដើម្បីដោះបំណុល។

ក្រសួងការងារ ក៏បានបង្គាប់ឱ្យមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈគ្រប់រាជធានី-ខេត្ត ត្រូវផ្សព្វផ្សាយពីសេចក្តីណែនាំខាងលើនេះ ទៅដល់ម្ចាស់សិប្បកម្មផលិតឥដ្ឋ នៅតាមមូលដ្ឋានរបស់ខ្លួនផងដែរ។ សេចក្តីណែនាំរបស់ក្រសួងការងារ បានសង្កត់ធ្ងន់ថា ម្ចាស់ ឬនាយកសិប្បកម្មផលិតឥដ្ឋទាំងឡាយណា ដែលខកខានក្នុងការអនុវត្តតាមសេចក្តីណែនាំនេះ នឹងត្រូវទទួលរងនូវការផាកពិន័យ ឬអាចឈានទៅដល់ការបិទអាជីវកម្ម ឬអាចប្រឈមនឹងបទល្មើសព្រហ្មទណ្ឌ៕

## អគ្គស្នងការរងនគរបាលជាតិ ជម្រុញឲ្យមន្ត្រីអនុវត្តច្បាប់ខិតខំបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសរំលោភបំពានលើកុមារ និងអាជីវកម្មផ្លូវភេទ

http://cambodiapolice.com/policekh/ 6:00 pm ថ្ងៃទី 7 ខែមិថុនា ឆ្នាំ 2019

**ភ្នំពេញ ៖** លោកជំទាវនាយឧត្តមសេនីយ៍ យក់សុ ខា អគ្គស្នងការរងនគរបាលជាតិ បានជម្រុញដល់មន្ត្រីនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ត្រូវខិតខំបន្ថែមទៀតក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសរំលោភបំពានលើកុមារនិងអាជីវកម្មផ្លូវភេទខណៈករណីនេះនៅតែកើតឡើងគួរឲ្យព្រួយបារម្ភនៅប្រទេសកម្ពុជា។ មានប្រសាសន៍នៅក្នុងពិធីពិធីបិទវគ្គបណ្តុះបណ្តាលស្តីពី ការស៊ើបអង្កេតបទល្មើសរំលោភបំពានលើកុមារ នាល្ងាចថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩នេះ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ លោកជំទាវ នាយឧត្តមសេនីយ៍ យក់ សុខា បានលើកឡើងថា ក្នុងនាមយើងជានគរបាលយុត្តិធម៌ និងជានគរបាលប្រឆាំងការជួញដូរមនុស្ស ត្រូវតែស្រាវជ្រាវស៊ើបអង្កេតនូវរាល់បទល្មើសឲ្យមានប្រសិទ្ធភាពបំផុត ដើម្បីធ្វើយ៉ាងណាស្វែងរកចាប់ខ្លួនជនល្មើសឲ្យបាន ដើម្បីយកមកផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន។

លោកជំទាវ នាយឧត្តមសេនីយ៍ យក់ សុខា បញ្ជាក់ថា “**ក្នុងនាមយើងជាមន្ត្រីអនុវត្តច្បាប់ក្នុងពេលប្រតិបត្តិការត្រូវតែប្រកបដោយក្រមសិលធម៌ ជំនាញវិជ្ជាជីវៈ និងការទទួលសុខត្រូវ ជាពិសេសយល់ដឹងអំពីច្បាប់ និងការធ្វើកោសល្យវិច្ច័យប្រមូលភស្តុតាងកសាងសំណុំរឿងបញ្ជូនទៅតុលាការ**”។ លោកជំទាវអគ្គស្នងការរងនគរបាលជាតិ បានបញ្ជាក់ទៀតថា រយៈពេល ៥ថ្ងៃ នៃវគ្គបណ្តុះបណ្តាលនេះ គោលបំណងសំខាន់ពង្រឹងសមត្ថភាពបន្ថែមទៀតដល់មន្ត្រីជំនាញក្នុងការស៊ើបអង្កេតបទល្មើសរំលោភបំពានលើកុមារ ធ្វើយ៉ាងណាឲ្យកិច្ចប្រតិបត្តិការកាន់តែមានប្រសិទ្ធភាព។ឆ្លៀតក្នុងឱកាសនេះដែរ លោកជំទាវអគ្គស្នងការរងនគរបាលជាតិ ក្នុងនាម ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត

សារឿន អគ្គស្នងការនគរបាលជាតិ និងក្នុងនាមលោកជំទាវផ្ទាល់ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោក James McCabe នាយកទទួលប្រតិបត្តិការអង្គភាពការពារកុមារ (CPU) និងលោកស្រី Lucia Soleti ប្រធានផ្នែកកិច្ចការកុមារ តំណាងអង្គការ UNICEF និងគ្រូឧទ្ទេសនាមមកពីចក្រភពអង់គ្លេស ដែលបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការស៊ើបអង្កេតបទល្មើសរំលោភបំពានលើកុមារ នេះឡើងសំដៅពង្រឹងសមត្ថភាពដល់មន្រ្តីនគរបាលជាតិកម្ពុជា និងសូមស្នើឲ្យមានវគ្គបណ្តុះបណ្តាលនេះជាបន្តបន្ទាប់ទៀតផងដែរ។

សូមបញ្ជាក់ថានៅក្នុងឆ្នាំ២០១៨កន្លងទៅនេះ សមត្ថកិច្ចបានធ្វើការបង្ក្រាបបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទបានចំនួន ១០៤ករណី ថយចុះ៤៧ករណី ស្មើនិងជាង ៣១ភាគរយ ដោយចាប់ជនសង្ស័យបានចំនួន ១៦៨នាក់ ក្នុងនោះជនបរទេស ១៩នាក់ និងសង្គ្រោះជនរងគ្រោះបាន ២០៣នាក់។

ដោយឡែកទាក់ទងនឹងករណីរំលោភសេពសន្ថវៈ ដែលបង្ករឡើងដោយឪពុកបង្កើត ឪពុកចុង ជីតា ឬក៏ពូ អ៊ុំ ជាដើមនោះ គឺបានកើតឡើងជាង ១១១ករណី ដោយឃាត់ខ្លួនជនសង្ស័យបានជាង ១១៥នាក់ និងសង្គ្រោះជនរងគ្រោះបាន ១១៧នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំ ៦៨នាក់ ។ ទោះជាយ៉ាងណាក៏ដោយ លោកជំទាវ នាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរងនគរបាលជាតិ ក៏បានអំពាវនាវដល់មន្រ្តីអនុវត្តច្បាប់ និងភាគីពាក់ព័ន្ធទាំងអស់ត្រូវបង្កើនសកម្មភាពចុះអប់រំ និងណែនាំដល់ប្រជាពលរដ្ឋឲ្យបានសកម្មបន្ថែមទៀតទាក់ទងនឹងផលប៉ះពាល់ នៃបទល្មើសរំលោភបំពានលើកុមារ និងអាជីវកម្មផ្លូវភេទនេះ៕

## អង្គការ LPN បើកវគ្គបណ្តុះបណ្តាលអប់រំពលករខ្មែរលើច្បាប់និងសិទ្ធិការងារក្នុងប្រទេសថៃ

https://www.facebook.com Prak Pheak Tra បណ្តាញទេសន្តប្រវេសន៍ក្នុងប្រទេសថៃ 10-06-2019

នៅថ្ងៃច័ន្ទទី១០ ខែមិថុនា ឆ្នាំ២០១៩ មន្ត្រីអង្គការមូលនិធិបណ្តាញលើកកំពស់គុណភាពជីវិតពលករ បានចុះធ្វើការបណ្តុះបណ្តាលអប់រំផ្នែកច្បាប់និងសិទ្ធិការងារ ដល់ពលករកម្ពុជាចំនួន ៤០នាក់ កំពុងធ្វើការនៅក្នុងរោងចក្រ CPF (ណាងចក)ស្ថិតនៅទីក្រុងបាងកក ប្រទេសថៃ ។វគ្គបណ្តុះបណ្តាលអប់រំពលករខ្មែរលើកនេះបានផ្តោតសំខាន់លើច្បាប់និងសិទ្ធិការងារក្នុងប្រទេសថៃ ដើម្បីជាចំនេះដឹងដល់ពលករ ជាពិសេសសិទ្ធិប្រកាន់សង្គម ដែលពលករគួរយល់ដឹង។

## សមត្ថកិច្ចថៃចាប់បានពលរដ្ឋខ្មែរចំនួន19នាក់

https://www.facebook.com/ ទឹកចិត្ត ពលករ ឆ្លងដែន 09-06-2019 at 12:57 AM

សមកិច្ចថៃចាប់បានពលរដ្ឋខ្មែរចំនួន19នាក់ ពលរដ្ឋខ្មែរទាំង19នាក់នេះ បានឆ្លងដែនចូលប្រទេសថៃខុសច្បាប់ ដើម្បីចូលកាប់ឈើក្រញូងនៅលើទឹកដីថៃយកទៅលក់អោយឈ្មួញនៅស្រុកខ្មែរ តែត្រូវសមកិច្ចថៃចាប់បានយកទៅដំណើការតាមផ្លូវច្បាប់នៅប្រទេសថៃ។ សូមបងប្អូនខ្មែរកុំចូលកាប់ឈើនៅទឹកដីថៃអោយសោះ នៅពេលនេះសមកិច្ចថៃតឹងរឹងណាស់នៅតាមជាយដែនថៃគេការពារព្រៃឈើគេណាស់ សូមបងប្អូនខ្មែរយើងប្រយ័ត្នផង។ (អំពីខ្ញុំទឹកចិត្ត ពលករ ឆ្លងដែន)

## ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៩

## ក្រុមហ៊ុនជប៉ុនត្រូវការកម្លាំងពលកម្មបន្ថែមពីកម្ពុជាបន្ទាប់ពីវិសោធនកម្មច្បាប់អន្តោប្រវេសន៍

https://www.propertyarea.asia/ June 10, 2019 ដោយ Donald Lee

ភ្នំពេញ៖ ក្រុមហ៊ុនជប៉ុនកំពុងជ្រើសរើសប្រជាជនកម្ពុជាយ៉ាងសកម្ម ដើម្បីធ្វើការនៅជប៉ុន ដោយសារតែខ្លួនកំពុងជួបប្រទះការថយចុះកម្លាំងការងារយ៉ាងខ្លាំង។ ប្រទេសជប៉ុនកំពុងប្រឈមមុខ នឹងកង្វះខាតកម្លាំងពលកម្មធ្ងន់ធ្ងរនៅក្នុងវិស័យទាំងអស់ ជាពិសេសវិស័យសំណង់ និងកសិកម្ម។ យោងតាមក្រសួងសុខាភិបាលរបស់ជប៉ុនបាន

ឲ្យដឹងថា កម្លាំងពលកម្មរបស់ប្រទេសត្រូវបានគេរំពឹងថា នឹងថយចុះជិត១៣លាននាក់ក្នុងរយៈពេល២០ឆ្នាំខាងមុខ។ ប្រជាជនជប៉ុនត្រូវគេរំពឹងថានឹងធ្លាក់ពី១២៧លាននាក់ មកនៅត្រឹម១១០លាននាក់ត្រឹមឆ្នាំ២០៤០។ ដើម្បីដោះស្រាយបញ្ហានៃការធ្លាក់ចុះកម្លាំងពលកម្មរយៈពេលយូរ និងប្រឈមមុខនឹងវិបត្តិនេះ រដ្ឋាភិបាលជប៉ុនបានកែប្រែច្បាប់អន្តោប្រវេសន៍របស់ខ្លួន កាលពីខែមេសា ដើម្បីបន្ធូរបន្ថយការរឹតបន្តឹងលើ "កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស" របស់ខ្លួន។ ក្រោមច្បាប់ថ្មី រដ្ឋាភិបាលជប៉ុនរំពឹងថានឹងផ្តល់ទិដ្ឋាការចំនួន៣៤ម៉ឺន ក្នុងរយៈពេលប្រាំឆ្នាំខាងមុខ ដែលភាគច្រើនផ្តល់ទិដ្ឋាការជូនប្រទេសនៅអាស៊ីអាគ្នេយ៍។

យោងតាមច្បាប់ដែលបានកែសម្រួលនេះ អ្នកដែលឆ្លងកាត់ការធ្វើតេស្តជំនាញភាសាជប៉ុន និងបច្ចេកទេស សម្រាប់ទិដ្ឋាការ "ប្រភេទទី ១"នឹងអាចធ្វើការនៅប្រទេសជប៉ុនរហូតដល់៥ឆ្នាំ។ ការធ្វើតេស្តទិដ្ឋាការប្រភេទ "ប្រភេទ ១" នឹងមាននៅក្នុងប្រទេសកម្ពុជា ចិន ម៉ាឡេស៊ី ម៉ុងហ្គោលី មីយ៉ាន់ម៉ា នេប៉ាល់ ហ្វីលីពីន ថៃ និងវៀតណាម។ អ្នកដាក់ពាក្យសុំធ្វើការក្នុងវិស័យសាងសង់ និងសាងសង់នាវានឹងមានសិទ្ធិទទួលបានទិដ្ឋាការប្រភេទ"ប្រភេទទី២" ដែលនឹងអនុញ្ញាតឲ្យបុគ្គលម្នាក់ៗ បន្តទិដ្ឋាការរបស់ពួកគេជាអចិន្ត្រៃ ហើយនាំសមាជិកគ្រួសាររបស់ពួកគេទៅប្រទេសជប៉ុន។

ក្រុមហ៊ុនដូចជា One Visa មានមូលដ្ឋាននៅទីក្រុងតូក្យូ កំពុងព្យាយាមទាញយកផលចំណេញ ពីការធ្វើវិសោធនកម្មច្បាប់អន្តោប្រវេសន៍របស់ជប៉ុន។ នេះបើយោងតាម Nikkei Asian Review ។ ក្រុមហ៊ុននេះបានបើកសាលារៀនមួយនៅជាយក្រុងភ្នំពេញ ដើម្បីបណ្តុះបណ្តាលបុគ្គលិកកម្ពុជា និងសម្របសម្រួលសេវាកម្មផ្តល់ទិដ្ឋាការតាមអ៊ីនធឺណិត និងគ្រោងនឹងបញ្ជូនអតិថិជនទៅប្រទេសជប៉ុននៅចុងឆ្នាំនេះ។ កន្លងមកប្រទេសជប៉ុនបានបិទផ្លូវសំខាន់ៗនៅក្នុងការផ្គត់ផ្គង់កម្មករ ទៅប្រទេសជប៉ុនពីប្រទេសជាច្រើនបានកើតឡើងផងដែរ ដូចជាប្រទេសកម្ពុជាជាដើម។ យោងតាមក្រសួងយុត្តិធម៌របស់ប្រទេសជប៉ុនបានឲ្យដឹងថា ឈ្មួញកណ្តាលការងារជាច្រើននៅអាស៊ីអាគ្នេយ៍ត្រូវបានចោទប្រកាន់ថា ខុសច្បាប់ចំពោះការទាមទារប្រាក់ពីអ្នកដាក់ពាក្យសុំទិដ្ឋាការ ដែលមានកម្រៃសេវាហួសប្រមាណ សម្រាប់សេវាកម្មរបស់ពួកគេ ដែលមានតម្លៃរហូតដល់ទៅ ១០,០០០ដុល្លារឬច្រើនជាងនេះ៕

## វគ្គបណ្តុះបណ្តាលហ្វឹកហ្វឺនលើកទី១ ស្តីពីនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស និងក្រុមសីលធម៌

http://cambodiapolice.com/policekh/ 12:58 pm 11 មិថុនា 2019

ព្រះវិហារ៖ ថ្ងៃអង្គារ ៩កើត ដល់ថ្ងៃព្រហស្បតិ៍ ១១កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០១៩ នៅសាលប្រជុំស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ បើក វគ្គបណ្តុះបណ្តាលហ្វឹកហ្វឺនលើកទី១ ស្តីពីនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស និងក្រុមសីលធម៌ ក្នុងការសម្គាសកំណត់អត្តសញ្ញាណជនរងគ្រោះ ក្រោមអធិបតីភាព លោកឧត្តមសេនីយ៍ទោ គឹម ភាព អនុប្រធាននាយកដ្ឋាន ប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន លោកស្រីវរសេនីយ៍ឯក ប្រាំង ធីតា ស្នងការរង ទទួលផែនការងារប្រឆាំងអំពើជួញដូរមនុស្ស ការពារអនីតិជន និងការពារយេនឌ័រ តំណាងដ៏ខ្ពង់ខ្ពស់ លោកឧត្តមសេនីយ៍ទោ សួស សុខដារ៉ា ស្នងការនគរបាលខេត្តលោក សៀង វត្តា អ្នកសម្របសម្រួល គម្រោងតស៊ូមតិ នៃអង្គការសម្ព័ន្ធចាប់ដៃ។ ក្នុងនោះដែរក៏មានការអញ្ជើញចូលរួមពី អធិការរង នាយប៉ុស្តិ៍ ចំនួន៤ស្រុក ការិយាល័យជំនាញ មន្ទីរសង្គមកិច្ច មន្ទីរកិច្ចការនារី និងមណ្ឌលកុមារកំព្រា សរុប ៣០ នាក់ ក្នុងនោះ ស្រី ៦នាក់។

វគ្គបណ្តុះបណ្តាលហ្វឹកហ្វឺនលើកទី១ ស្តីពីនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស និងក្រុមសីលធម៌ ក្នុងការសម្គាសកំណត់អត្តសញ្ញាណជនរងគ្រោះ បានសហការជាមួយ អង្គការសម្ព័ន្ធចាប់ដៃ ក្នុងគោលបំណងផ្តល់ចំណេះ

ដឹង ដើម្បីបង្កើនការយល់ដឹងតាមរយៈការចែករំលែក ពិភាក្សា អំពីបទពិសោធន៍ និងការអនុវត្តន៍ជាក់ស្តែង ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបករណី អំពើជួញដូរមនុស្ស៕

## ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩

### ឃាត់ខ្លួនជនសង្ស័យ បង្ខំឲ្យក្មេងៗដើរសុំទានគេនៅម្តុំផាប់ស្ត្រីត ថែមទាំងឲ្យដេកជាមួយ ភ្ញៀវបរទេសហើយយកលុយពីគ្នា

https://khmernote.com/news/ June 11, 2019

ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចុះបង្ក្រាបករណីអំពើអូសទាញពេស្យាចារកុមារ និងករណីជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច ដោយឃាត់ខ្លួនជនសង្ស័យក្នុងអំឡុងខែឧសភា ឆ្នាំ២០១៩។ លោកវរសេនីយ៍ឯក ជា ហេង នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការរដ្ឋាននគរបាលខេត្តសៀមរាប បានប្រាប់អោយដឹងថា ជនសង្ស័យឈ្មោះ ពេត ម៉ៅ ភេទស្រី អាយុ ២៣ឆ្នាំ រស់នៅភូមិវិហារចិន សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ចំណែកជនរងគ្រោះទាំង៥មានដូចតទៅ ១.ឈ្មោះ រិទ្ធ ស្រីភ័ណ្ឌ ភេទស្រី អាយុ ១៥ឆ្នាំ, ២.ឈ្មោះ រិទ្ធ ស្រីពេជ្រ ភេទស្រី អាយុ ១៣ឆ្នាំ, ៣.ឈ្មោះ វណ្ណៈ ស្រីភ័ស្ស ភេទស្រី អាយុ ១៤ឆ្នាំ, ៤.ឈ្មោះ វណ្ណៈ ស្រីភាង ភេទស្រី អាយុ ១០ឆ្នាំ និង ៥.ឈ្មោះ ទូច ស្រីនិង ភេទស្រី អាយុ ១៤ឆ្នាំ។

ជនសង្ស័យបានអោយកុមារីទាំង៥ ដើរសុំទាននៅផ្សារចាស់តំបន់ផាប់ស្ត្រីត ចាប់ពីពេលល្ងាចម៉ោងប្រហែល ៧ រហូតដល់ម៉ោង៣ទៀបភ្លឺ ទើបហៅក្មេងស្រីទាំងអស់ទៅជួបជុំគ្នា នៅស្ពានឈើមុខសណ្ឋាគារតាព្រហ្ម និងតម្រូវអោយក្មេងៗទាំងអស់បង់ប្រាក់ម្នាក់ ១ម៉ឺន ទៅ២ម៉ឺនរៀលក្នុង១យប់។ ហើយបើក្មេងទាំងអស់នោះមិនស្តាប់តាម ជនសង្ស័យគំរាមវាយធ្វើបាប ព្រមទាំងបង្ខំអោយក្មេងជក់គ្រឿងញៀន ហើយបើមានភ្ញៀវបរទេសណាត្រូវការយកក្មេងទៅដេកជាមួយ ជនសង្ស័យជាអ្នកជំរុញអោយទៅជាមួយជនបរទេសហើយបកប្រែភាសាអោយក្មេងៗ រួចដកយកភាគរយដែលជនបរទេសអោយលុយទៅក្មេងៗថែមទៀត។

លោកបន្តទៀតថា ក្នុងករណីនេះជនសង្ស័យដែលមានឈ្មោះខាងលើនេះត្រូវបានឃាត់ខ្លួនតាមបញ្ជាលោក កើត វណ្ណារ៉េត ព្រះរាជអាជ្ញាអមសាលាដំបូង ខេត្តសៀមរាប នៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង ១៧និង ២០នាទី ហើយបន្តរៀបចំនិងកសាងសំណុំរឿងបញ្ជូនទៅតុលាការ៕

### កម្ពុជាស្នើម៉ាឡេស៊ី បន្តគាំទ្រនិង ការពារពលករខ្មែរ នៅទីនោះ

https://www.dap-news.com/archives/ ByID:112 Posted on 11 June 2019 | 14:10

ភ្នំពេញ ៖ លោក ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសខ្មែរ បានស្នើសុំភាគីម៉ាឡេស៊ី ឲ្យបន្តជួយគាំទ្រយកចិត្តទុកដាក់ ហើយគាំពារឲ្យបាន សមរម្យដល់ពលករកម្ពុជា ទាំងអស់ដែលកំពុងបម្រើការងារ នៅក្នុងប្រទេសរបស់ខ្លួន។

តាមរយៈលោកស្រី ទូត បញ្ញា អនុរដ្ឋលេខាធិការក្រសួងការបរទេស ក្នុងជំនួបពិភាក្សាការងារ ជាមួយលោក Eldeen Husaini BIN MOHD HASHIM ឯកអគ្គរដ្ឋទូតថ្មីម៉ាឡេស៊ីប្រចាំកម្ពុជា លោកឧបនាយករដ្ឋមន្ត្រី បានមានប្រសាសន៍ថា ភាគីម៉ាឡេស៊ី បានសហការធ្វើការជាមួយស្ថានទូតកម្ពុជា នៅទីក្រុងកូឡាឡាំពួ និងអង្គការអន្តរជាតិអង្គការអន្តោប្រវេសន៍ ក្នុងការសហការ ដោះស្រាយទាន់ពេលវេលាជួយពលករមានបញ្ហា ហើយក៏បានរួមចំណែកក្នុងការបញ្ជូន ពួកគេមកប្រទេសវិញផងដែរ ។ លោកបន្តថា "ស្នើសុំភាគីម៉ាឡេ បន្តការជួយគាំទ្រយកចិត្តទុកដាក់ ហើយ និងផ្តល់ប្រព្រឹត្តិកម្ម ឲ្យបានសមរម្យដល់ពលករកម្ពុជា ដែលធ្វើការនៅម៉ាឡេទាំងអស់" ។

ជាការឆ្លើយតបលោក Eldeen Husaini BIN MOHD HASHIM ថា រដ្ឋាភិបាលរបស់ម៉ាឡេស៊ី បានគិតគូរពីបញ្ហាពលករបរទេស ព្រោះនេះជាបញ្ហាអាទិភាពមួយរបស់រដ្ឋាភិបាល។ លោកសន្យាថា នឹងខិតខំផ្តល់កិច្ចសហប្រតិបត្តិការថែមទៀត ជាមួយភាគីកម្ពុជា ក្នុងការដោះស្រាយរាល់បញ្ហារបស់ពលករ ។

ជាមួយគ្នានេះដែរ លោកឧបនាយករដ្ឋមន្ត្រី បានលើកឡើងថា ចំពោះពាណិជ្ជកម្មរវាងប្រទេស នៅឆ្នាំ២០១៧ មានប្រហែល៤១១លានដុល្លារ ខណៈឆ្នាំ២០១៨ បានកើនឡើងទៅដល់ ៤៧៤លានដុល្លារ ។ ក្នុងនោះ លោកឧបនាយករដ្ឋមន្ត្រី ក៏បានស្នើសុំឲ្យកម្ពុជា-ម៉ាឡេស៊ី ជម្រុញការចរចាលើកិច្ចព្រមព្រៀង ស្តីពីការជៀសវាងការយកពន្ធត្រួតគ្នា ដែលមកដល់ពេលនេះ មិនទាន់បានចប់នៅឡើយទេ ។

សូមបញ្ជាក់ថា បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជា បានផ្អាកការជ្រើសរើស និងបញ្ជូនពលករខ្មែរ ទៅធ្វើការនៅម៉ាឡេស៊ី កាលពីចុងឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំយន្តការ និងបទដ្ឋានគតិយុត្តិជាច្រើនសម្រាប់ការពារ គ្រប់គ្រង និងលើកកម្ពស់សិទ្ធិដល់ពលករខ្មែរទាំងអស់ ដែលកំពុងស្នាក់នៅ និងធ្វើការនៅម៉ាឡេស៊ី។ គិតត្រឹម ខែតុលា ឆ្នាំ២០១៨ មានក្រុមហ៊ុនចំនួន ៦៩ នាំពលករខ្មែរទៅម៉ាឡេស៊ី។ ជាមួយគ្នានេះ ម៉ាឡេស៊ីក៏បានផ្លាស់ប្តូរលក្ខខណ្ឌការងារថ្មីផងដែរ ក្រោយពីកម្ពុជាផ្អាកបញ្ជូនពលករទៅ។ លក្ខខណ្ឌផ្លាស់ប្តូរនោះរួមមាន៖ នីតិវិធីក្នុងការជ្រើសរើសពលករ និងការតំឡើងប្រាក់ឈ្នួលខ្ពស់ជាងមុន ដើម្បីទាក់ទាញពលករបរទេស ពិសេសពលករកម្ពុជាឲ្យទៅធ្វើការនៅប្រទេស របស់ខ្លួនឲ្យកាន់តែច្រើនថែមទៀត ៕ ដោយ នឿត សម្លស្ស

## វគ្គពង្រឹងសមត្ថភាព ដល់មន្រ្តីបង្គោល ក្រុង-ស្រុក និងឃុំ-សង្កាត់ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

http://gdlf-kh.com/ 11/06/2019 Sek Samnang កំពង់ឆ្នាំង

ខេត្តកំពង់ឆ្នាំង៖ នាព្រឹកថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៩ នៅសាល "ក" សាលាខេត្តកំពង់ឆ្នាំង មានបើកវគ្គពង្រឹងសមត្ថភាព ដល់មន្រ្តីបង្គោល ក្រុង/ស្រុក និងឃុំ សង្កាត់ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ វគ្គបណ្តុះបណ្តាលប្រព្រឹត្តទៅក្រោមអធិបតីភាពលោកជំទាវ **ប៉ាល់ យឿន** អភិបាលរងខេត្តកំពង់ឆ្នាំង លោក លោកស្រី ប្រធាន អនុប្រធានមន្ទីរ អង្គភាព ជុំវិញខេត្ត ក្រុង/ស្រុក ឃុំ សង្កាត់ ចំនួន ៨៦នាក់ ស្រី ៣៦នាក់ ចូលរួមផងដែរ ៕

## ក្រសួងការងារ ដាក់ចេញវិធានការមួយចំនួន ដើម្បីបញ្ចប់ពលកម្មកុមារត្រឹមឆ្នាំ២០២៥

http://www.freshnewsasia.com/index.php/ 2019-06-12

**(ភ្នំពេញ)៖** នាឱកាសទិវាកុមារកម្ពុជា ទិវាកុមារអន្តរជាតិ ១មិថុនា ឆ្នាំ២០១៩ និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់ចេញវិធានការមួយចំនួន ដើម្បីសម្រេចទិសដៅបញ្ចប់ពលកម្មកុមារនៅត្រឹមឆ្នាំ២០២៥។ ទិវានេះធ្វើឡើងក្រោមអធិបតីភាពលោកស្រី ស៊ើង សរសុចិត្តា រដ្ឋលេខាធិការក្រសួងការងារ នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងការងារ។

ទិវាកុមារកម្ពុជា ទិវាកុមារអន្តរជាតិ ១មិថុនា ឆ្នាំ២០១៩ និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា នេះ បានប្រារព្ធឡើងក្រោមប្រធានបទ «កុមារត្រូវសម្រេចសុបិនរបស់ខ្លួន ដោយមិនត្រូវធ្វើជាពលកម្មកុមារនៅកន្លែងការងារណាមួយឡើយ» ដើម្បីរំលឹកដល់សិទ្ធិជាមូលដ្ឋានរបស់កុមារ និងបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចការពារកុមារពីគ្រប់ទម្រង់នៃការកេងប្រវ័ញ្ចពលកម្ម និងទប់ស្កាត់ ភាពគ្រោះថ្នាក់ការងារ ជាពិសេសការផ្តល់ឱកាសឱ្យកម្មករនិយោជិតវ័យក្មេងទទួលបានជំនាញ និងមុខរបរសមស្របសម្រាប់ការបង្កើនជីវភាពគ្រួសារឱ្យកាន់តែប្រសើរឡើង។ រាជរដ្ឋាភិបាលកម្ពុជា បានធ្វើឱ្យប្រទេសកម្ពុជាក្លាយជាប្រទេសមួយនាំមុខ ក្នុងចំណោមប្រទេសទាំង៥ក្នុងពិភពលោក ដែលបានលុបបំបាត់ពលកម្មកុមារ និងមានលក្ខខណ្ឌការងារល្អប្រសើរ មាន

គោលនយោបាយច្បាស់លាស់ ក្នុងការប្រឆាំងនឹងពលកម្មកុមារ និងជាប្រទេសនាំមុខមធ្យម ក្នុងចំណោមប្រទេសនាំមុខទាំង១៣នៅលើពិភពលោក ក្នុងវឌ្ឍនភាពប្រឆាំងពលកម្មកុមារ។

**ទន្ទឹមនឹងនេះ ដើម្បីសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សកលប្រកបដោយចីរភាព (២០១៥-២០៣០) ដែលចែងអំពីការបញ្ចប់ពលកម្មកុមារនៅឆ្នាំ២០២៥ រាជរដ្ឋាភិបាលកម្ពុជា មានវិធានការនិងប្តេជ្ញាចិត្ត៖**

* បន្តពង្រឹងយន្តការអនុវត្តច្បាប់និងអធិការកិច្ចការងារ និងសហការជាមួយអង្គការនិយោជិត និយោជក ដើម្បីដោះស្រាយករណីវិវាទពលកម្មកុមារ និងសុវត្ថិភាពការងារឱ្យបានទាន់ពេលវេលា ជាពិសេសជំរុញនិយោជកគោរពបទដ្ឋានការងារ និងការដាក់ពិន័យកម្រិតធ្ងន់សម្រាប់សហគ្រាស គ្រឹះស្ថាន ដែលប្រើប្រាស់ពលកម្មកុមារ

* ពង្រីកកិច្ចសហការអន្តរវិស័យ និងស្វែងរកដំណោះស្រាយសមស្របចំពោះបញ្ហាពលកម្មកុមារដែលមានចរិតលក្ខណៈពហុវិស័យ ដើម្បីធានាឧត្តមប្រយោជន៍របស់កុមារកម្ពុជា និងកសាងមូលធនមនុស្សស្របតាមបរិបទការងារសមរម្យ

* ជំរុញឱ្យគ្រប់ភាគីពាក់ព័ន្ធសហការគ្នា ដើម្បីធានាសុវត្ថិភាពការងារសម្រាប់កម្មករនិយោជិតវ័យក្មេង និងអំពាវនាវសាធារណៈជនរាយការណ៍អំពីករណីពលកម្មកុមារនៅកន្លែងធ្វើការ។ ទន្ទឹមនឹងនេះ ការណែនាំ ដល់អាណាព្យាបាល និងនិយោជកករណីរំលោភបំពានពលកម្មកុមារ ជាពិសេសកុមារបម្រើការងារក្នុងផ្ទះ គឺជាបទល្មើសព្រហ្មទណ្ឌ ដើម្បីកាត់បន្ថយការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

* ស្វែងរកការគាំទ្រធនធាននិងបច្ចេកទេស ដើម្បីស្រាវជ្រាវ និងចងក្រងប្រកាសពាក់ព័ន្ធនឹងពលកម្មកុមារនៃសកម្មភាពសេដ្ឋកិច្ចដែលវិវត្តន៍ថ្មីៗ និងយុទ្ធនាការឆ្ពោះទៅបញ្ចប់ពលកម្មកុមារនៅកម្រិតថ្នាក់ឃុំសង្កាត់។

**ដើម្បីឆ្លើយតបទៅនឹងការលុបបំបាត់គ្រប់ទម្រង់នៃពលកម្មកុមារ លោកស្រី ស៊ើង សរសុចិត្តា ផ្តល់នូវអនុសាសន៍ដូចតទៅ៖**

**១៖** គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ (គ.ជ.ព.) ត្រូវបន្តសម្របសម្រួលអនុវត្តអនុសញ្ញាអន្តរជាតិ និងគោលនយោបាយជាតិពាក់ព័ន្ធនឹងពលកម្មកុមារ ជាពិសេសសហការជាមួយអន្តរក្រសួង-ស្ថាប័ន ដើម្បីជំរុញអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ឆ្នាំ ២០១៦-២០២៥។

**២៖** អគ្គលេខាធិការដ្ឋាន គ.ជ.ព. និងនាយកដ្ឋានជំនាញត្រូវខិតខំពង្រឹងវិធានការអធិការកិច្ចការងារឱ្យមានប្រសិទ្ធភាព ទប់ស្កាត់គ្រោះថ្នាក់ការងារ និងភាពងាយរងគ្រោះផ្នែកសុខភាព សម្រាប់កម្មករនិយោជិតវ័យក្មេង ដើម្បីលុបបំបាត់ពលកម្មកុមារ ជាពិសេសពង្រីកវិសាលភាពការងារវិស័យសេដ្ឋកិច្ចមិនរៀបរយ ដូចជា កម្មករការងារផ្ទះ សិប្បកម្ម និងសេវាកម្មដទៃទៀត។

**៣៖** បន្តបណ្តុះបណ្តាលពង្រឹងសមត្ថភាពគ្រប់ភាគីពាក់ព័ន្ធ និងកៀរគរធនធានហិរញ្ញវត្ថុ និងស្វែងរកការគាំទ្រពីសាធារណៈជនចូលរួមប្រឆាំងពលកម្មកុមារ។

**៤៖** ពង្រីកការផ្សព្វផ្សាយ និងយុទ្ធនាការប្រឆាំងពលកម្មកុមារ និងការងារដោយបង្ខំទៅដល់មូលដ្ឋាន និងសហគមន៍នានា ដើម្បីទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ។

**៥៖** ពង្រឹងកិច្ចអន្តរាគមន៍ស្ទួល ដើម្បីសង្គ្រោះពលកម្មកុមារ និងហាមឃាត់ការងារដោយបង្ខំទៅតាមប្រភេទមុខរបរ និងបង្កើនកិច្ចសហប្រតិបត្តិការក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធ ក្នុងការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារពីគ្រប់ទម្រង់៕

## ថៃប្រគល់ពលរដ្ឋខ្មែរ ៨នាក់មកវិញ ក្រោយដាក់ទោស ២ឆ្នាំ ពីបទឆ្លងដែនខុសច្បាប់ ចូលកាប់ឈើគ្រញូងលើទឹកដីថៃ

http://www.freshnewsasia.com/index.php/ 2019-06-11

**(ព្រះវិហារ)៖** យ៉ាងហោចណាស់ប្រជាពលរដ្ឋខ្មែរចំនួន ៨នាក់ ត្រូវបានអាជ្ញាធរប្រទេសថៃ បញ្ជូនខ្លួនមកឲ្យអាជ្ញាធរកម្ពុជាវិញ នៅតាមមាត់ច្រកតំបន់អានសេះ ស្ថិតក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៩នេះ បន្ទាប់ពីជាប់ឃុំឃាំង អស់រយៈពេល២ឆ្នាំ បទឆ្លងដែនខុសច្បាប់ ចូលកាប់ឈើគ្រញូង។

លោកវរសេនីយ៍ទោ ឱ សេង អធិការនគរបាលស្រុកជាំក្សាន្ត បានភ្នាក់ងារ Fresh News ឲ្យដឹងថា នៅវេលាម៉ោង០១៖៣០នាទី ថ្ងៃទី១១ ខែមីថុនា ឆ្នាំ២០១៩នេះ អាជ្ញាធរថៃបានបញ្ជូនខ្លួន ពលរដ្ឋខ្មែរ៨នាក់ ដែលជាប់ឃុំឃាំងក្នុងខេត្តអ៊ូប៊ុន មកឲ្យលោកអនុសេនីយ៍ឯក អ៊ុយ សីថា អនុប្រធានក្រុមការងារទំនាក់ទំនង ច្រកតំបន់អានសេះ។ លោក ឱ សេង បានឲ្យដឹងទៀតថា ប្រជាពលរដ្ឋខ្មែរទាំង៨នាក់នេះ ត្រូវបានភាគីថៃចាប់កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ ក្នុងភូមិសាស្ត្រស្រុកណាំយឺន ខេត្តអ៊ូប៊ុន ប្រទេសថៃពីបទលួចចូលកាប់ឈើ ក្នុងទឹកដីថៃចូលតាមចំណុចមុំបី។ ប្រជាពលរដ្ឋខ្មែរទាំង ៨នាក់នេះមានឈ្មោះដូចតទៅ៖ ទី១៖ ឈ្មោះ នួន លោក ភេទប្រុស អាយុ ៤១ឆ្នាំ រស់នៅភូមិសែនរុងរឿង១ ឃុំមរកត, ២៖ ឈ្មោះ រ័ត្ន តា ភេទប្រុស អាយុ២២ឆ្នាំ នៅភូមិសែនរុងរឿង១ ឃុំមរកត, ៣៖ ឈ្មោះ នី នឿន ភេទប្រុស អាយុ២៧ឆ្នាំ រស់នៅភូមិសំរោង ឃុំតស៊ូ ស្រុកជ័យសែន, ៤៖ ឈ្មោះ ប៊ុន សុកជា ភេទប្រុស អាយុ២២ឆ្នាំ នៅភូមិឈើទាលគង ឃុំជាំក្សាន្ត, ៥៖ ឈ្មោះ នី សៀកណៃ ភេទប្រុស អាយុ៣៣ឆ្នាំ នៅភូមិឈើទាលគង ឃុំជាំក្សាន្ត, ៦៖ ឈ្មោះ ប៊ុន ចាន់ណាក់ ភេទប្រុស អាយុ២៨ឆ្នាំ នៅភូមិឈើទាលគង ឃុំជាំក្សាន្ត, ៧៖ ឈ្មោះ សេង គឹមសឿន ភេទប្រុស អាយុ៣២ឆ្នាំ នៅភូមិឈើទាលគង ឃុំជាំក្សាន្ត, និង៨៖ ឈ្មោះ វី រឿន ភេទប្រុស អាយុ១៩ឆ្នាំ នៅភូមិឈើទាលគង ឃុំជាំក្សាន្ត។ ក្រោយពីលោកអនុសេនីយ៍ឯក អ៊ុយ សីថា អប់រំរួចហើយក៏ឲ្យវិលត្រឡប់ទៅលំដ្ឋានវិញរៀងៗខ្លួន៕

## ករណី គ្រោះថ្នាក់ ចរាចរណ៍ រវាង រថយន្ត តូរីដឹក ពលករ និង រថយន្ត HRV

https://www.facebook.com/PrakPheakTraOfficial/ Prak Pheak Tra 12-06-2019

ករណីគ្រោះថ្នាក់ចរាចរណ៍រវាងរថយន្តតូរីដឹកពលករ និងរថយន្ត HRV នៅត្រង់ចំណុចផ្លូវជាតិប៉ុកដែង ខេត្តរ៉ាក់យ៉ង បណ្តាលអោយពលករខ្មែរចំនួន០២នាក់ និងជនជាតិថៃម្នាក់ស្លាប់ភ្លាមនៅកន្លែងកើតហេតុ ហេតុការណ៍នេះបានកើតឡើងនៅវេលាម៉ោង១០:០០យប់ ថ្ងៃអង្គារ ទី១១ ខែមិថុនា ឆ្នាំ២០១៩។

ឈ្មោះ អ្នក ស្លាប់

ទី ១ ឈ្មោះ គឹម សិលា ភេទ ប្រុស សញ្ជាតិ ខ្មែរ

ទី ២ ឈ្មោះ ដេន ម៉ក ភេទ ស្រី សញ្ជាតិ ខ្មែរ

ទី ៣ ឈ្មោះ ធូក ផៃ ខ្លាំងយ៉ៃ ភេទ ប្រុស សញ្ជាតិ ថៃ

បច្ចុប្បន្នសាកសពអ្នកស្លាប់ត្រូវបានសមត្ថកិច្ចថៃបញ្ជូនយកទៅរក្សាទុកនៅមន្ទីរពេទ្យប៉ុកដែង ដើម្បីប្រគល់ជូនសាច់ញាតិយកទៅធ្វើបុណ្យតាមប្រពៃណី ។

## រដ្ឋមន្ត្រីមហាផ្ទៃ ស្នើម៉ាឡេស៊ីពង្រឹង កិច្ចសហប្រតិបត្តិលើការ ប្រយុទ្ធប្រឆាំង ឧក្រិដ្ឋកម្មឆ្លងដែនបន្ថែមទៀត

https://www.dap-news.com/archives/ ByID:030 Posted on 12 June 2019 | 18:18

ភ្នំពេញ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃបានស្នើឲ្យរដ្ឋាភិបាលនៃ ប្រទេសម៉ាឡេស៊ី ឲ្យពិនិត្យមើលលទ្ធភាព ពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀត លើការប្រយុទ្ធប្រឆាំង ឧក្រិដ្ឋកម្ម ឆ្លងដែនគ្រប់ប្រភេទ ។ ក្នុងជំនួបជាមួយលោក Eldeen Husaini BIN MOHD HASHIM ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេស ម៉ាឡេស៊ីប្រចាំ នៅកម្ពុជា សម្តេចបានថ្លែងថា នឹងបន្តពង្រឹង និងពង្រីក កិច្ចសហប្រតិបត្តិការ រវាងកម្ពុជា-ម៉ាឡេស៊ី ដែលជាសមាជិកគ្រួសារ អាស៊ានតែមួយ ។ សម្តេចបន្តថា ម៉ាឡេស៊ី ជាប្រទេសមួយដែលមានភាព លេចធ្លោរនៅក្នុងតំបន់អាស៊ាន ។ ការរីកចម្រើន របស់ម៉ាឡេស៊ី បានផ្តល់ផលវិជ្ជមាន ដល់ប្រទេសនានានៅក្នុងតំបន់។ សម្តេចបន្តទៀតថា ទំនាក់ទំនងរវាងកម្ពុជា-ម៉ាឡេស៊ី ពីមួយថ្ងៃទៅមួយថ្ងៃ មានការកើនឡើងជាលំដាប់ ។ហើយរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលម៉ាឡេស៊ីនៅតែបន្ត យកចិត្តទុកដាក់ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការពង្រីកនូវទំហំពាណិជ្ជកម្ម ពង្រីកកិច្ចសហប្រតិបត្តិការ លើវិស័យសេដ្ឋកិច្ច ទេសចរណ៍ និងការស្វែងរកការងារធ្វើ រវាងប្រជាពលរដ្ឋ នៃប្រទេសទាំងពីរផងដែរ។ សម្តេច បន្ថែមថា "ខ្ញុំនឹងស្នើម៉ាឡេស៊ីឲ្យពិនិត្យ មើលលទ្ធភាព ទៅលើការកិច្ចសហប្រតិបត្តិការបន្ថែមទៀត ដូចជា កិច្ចសហប្រតិបត្តិការ ប្រយុទ្ធប្រឆាំងទៅ នឹងឧក្រិដ្ឋកម្មឆ្លងដែន គ្រប់ប្រភេទ"។ សម្តេចសង្កត់ធ្ងន់ថា បច្ចុប្បន្នកម្ពុជា កំពុងតែខិតខំយកចិត្តទុកដាក់ ក្នុងការបង្ក្រាបការជួញដូរគ្រឿងញៀន ។ ដែលនេះក៏ជាផ្នែកមួយក្នុងការ ពង្រីកកិច្ចសហប្រតិបត្តិការ រវាងកម្លាំងអនុវត្តន៍ នៃប្រទេសទាំងពីរ។ ដើម្បីធ្វើយ៉ាងណា បង្កើននូវជំនឿទុកចិត្ត របស់ប្រជាពលរដ្ឋ ក៏ដូចជាការវិនិយោគ ទៅវិញទៅមក រវាងប្រទេសទាំងពីរផងដែរ។

ជាការឆ្លើយតប លោក Eldeen Husaini BIN MOHD HASHIM ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសម៉ាឡេស៊ីប្រចាំនៅកម្ពុជា ក៏បានឯកភាពចំពោះសំណើរបស់សម្តេចផងដែរ។ លោកក៏បានកោតសរសើរចំពោះសុខដុមរមនា នៅក្នុងសង្គមដែលកម្ពុជាសម្រេចបាន ជាពិសេសការរស់នៅចម្រុះសាសនាប្រកបដោយភាពសុខដុមរមនា នៅក្នុងសង្គម ។

សម្តេចថា ថ្វីត្បិតតែរដ្ឋធម្មនុញ្ញកម្ពុជា បានចែងថា សាសនាព្រះពុទ្ធជាសាសនា របស់រដ្ឋ។ ប៉ុន្តែកម្ពុជាបានគោរព នូវសិទ្ធិសាសនា របស់ប្រជាពលរដ្ឋ ដែលកាន់សាសនាផ្សេងទៀត ដែលតែងតែធ្វើយ៉ាងណា ឲ្យសាសនាទាំងអស់ រស់នៅជាមួយគ្នា ប្រកបដោយភាព សុខដុមរមនា៕ ដោយៈដី លីថូ

## រយៈពេល៥ឆ្នាំ កុមារជិត៣ម៉ឺននាក់ ត្រូវបានដកហូតពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

http://bayontv.com.kh/ 12/06/2019

ភ្នំពេញ៖ មន្ត្រីជាន់ខ្ពស់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបញ្ជាក់ថា ក្នុងរយៈពេល៥ឆ្នាំ កន្លងមកនេះ កុមារចំនួនជិត០៣ម៉ឺននាក់ ត្រូវបានដកហូតពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងចំនួនជិត១៨ម៉ឺននាក់ទៀតត្រូវបានទប់ស្កាត់ពីការប្រើប្រាស់ពលកម្មកុមារ ដើម្បីផ្តល់ឱកាសឱ្យពួកគេទទួលបានការអប់រំ បំណិនជីវិត និងបណ្តុះបណ្តាលជំនាញ។

លោកជំទាវ ស៊ើង សរសុចិត្តា រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅក្រោយបញ្ចប់ទិវាពិភពលោកប្រឆាំងពលកម្មកុមារ កាលពីព្រឹកថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩នេះ បានមានប្រសាសន៍ប្រាប់ក្រុមអ្នក

សារព័ត៌មានថា តាមរយៈគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារជាសេនាធិការ បាននឹងកំពុងបន្តយកចិត្តទុកដាក់ទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដោយបង្ខំតាមរយៈការកសាងសមត្ថភាព មន្ត្រីអធិការកិច្ចការងារ ស្តីពីការប្រើប្រាស់ពលកម្មកុមារ និងការងារដោយបង្ខំ និងពង្រឹងយន្តការប្រឆាំងពលកម្មកុមារ ជាពិសេសលើវិស័យមុខរបរ និងភូមិសាស្ត្រដែលមានហានិភ័យខ្ពស់។

ជាមួយគ្នានេះ ឯកឧត្តម វ៉េង ហៀង អគ្គលេខាធិការ និងជាប្រធាននាយកដ្ឋានការងារកុមារ បានឲ្យដឹងថា បច្ចុប្បន្ននេះ ក្រសួងការងារបានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើសុខភាព សុវត្ថិភាពការងារសម្រាប់កម្មករនិយោជិតវ័យក្មេង និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនៅតាមសហគ្រាស គ្រឹះស្ថាន ដើម្បីសមធម៌ កំណើនសេដ្ឋកិច្ច និងការងារសមរម្យសម្រាប់យុវជន លើសពីនេះដើម្បីពង្រឹងការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ។

សូមបញ្ជាក់ថា ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារ ឆ្នាំនេះ ក្រោមប្រធានបទ កុមារត្រូវសម្រេចសុបិនរបស់ខ្លួន ដោយមិនត្រូវធ្វើជាពលកម្មកុមារនៅកន្លែងការងារណាមួយឡើយ ដើម្បីរំលឹកដល់សិទ្ធិជាមូលដ្ឋានរបស់កុមារ និងបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចការពារកុមារពីគ្រប់ទម្រង់នៃការកេងប្រវ័ញ្ចពលកម្ម និងទប់ស្កាត់ ភាពគ្រោះថ្នាក់ការងារ ជាពិសេសការផ្តល់ឱកាសឱ្យកម្មករនិយោជិតវ័យក្មេងទទួលបានជំនាញ និងមុខរបរសមស្របសម្រាប់ការបង្កើនជីវភាពគ្រួសារឱ្យកាន់តែប្រសើរឡើង៕

## លីកាដូ ស្នើយ៉ាងទទូច មិនឲ្យមានពលកម្ម កុមារនៅកម្ពុជា , ក្មេងមិនគ្រប់អាយុ មិនត្រូវឲ្យរបួស ឬស្លាប់នៅកន្លែងធ្វើការ

https://www.dap-news.com/archives/ ByID:112 Posted on 12 June 2019 | 16:50

ភ្នំពេញ ៖ សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) បានស្នើសុំដោយទទូច ដល់ភាគីពាក់ព័ន្ធជួយទប់ស្កាត់ ដោយមិនគួរបណ្តោយ ឲ្យមានពលកម្មកុមារ នៅក្នុងប្រទេសកម្ពុជា ហើយជាពិសេសក្មេងមិនទាន់គ្រប់អាយុមិនគួរត្រូវបានរងរបួស ឬស្លាប់បាត់បង់ជីវិតនៅកន្លែង ធ្វើការក្នុងវិស័យណាមួយនោះទេ។

ក្នុងទិវាពិភពលោកប្រឆាំង នឹងពលកម្មកុមារនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ អង្គការលីកាដូបានលើកឡើងថា ការចូលរួមរបស់ភាគី ពាក់ព័ន្ធទាំងអស់រួមមាន អាជ្ញាធរ ម្ចាស់សិប្បកម្មផលិតឥដ្ឋ កម្មករ-កម្មការិនី និងកូនៗរបស់អ្នកទាំងនោះ គឺជាមធ្យោបាយមួយប្រកបដោយប្រសិទ្ធភាព ដើម្បីលើកកម្ពស់ ការយល់ដឹងស្តីពី ការបម្រើពលកម្មដើម្បីដោះបំណុល និងកម្មករជាអនីតិជនដែលត្រូវបានប្រទះឃើញជារឿយៗក្នុងសិប្បកម្មផលិតឥដ្ឋ។

លីកាដូបន្តថា "ជាថ្មីម្តងទៀត សូមស្នើសុំដោយទទូចថា មិនគួរមានពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា ហើយក្មេងមិនទាន់គ្រប់អាយុ មិនគួរត្រូវបានរងរបួស ឬស្លាប់បាត់បង់ជីវិតនៅកន្លែងធ្វើការក្នុងវិស័យណាមួយនោះទេ។ អាជ្ញាធរកម្ពុជាគួរចាត់វិធានការឲ្យមានប្រសិទ្ធភាព ដើម្បីប្រឆាំងរាល់ទម្រង់នៃការប្រើប្រាស់ពលកម្មកុមារ និងទាសភាពបំណុល។ ប្រសិនបើចំណាត់ការទាំងនេះ មិនត្រូវបានធ្វើឡើងនោះទេ ទម្រង់អាក្រក់នៃទាសភាពសម័យទំនើបនេះ នឹងបន្តរីករាលដាលនៅក្នុងប្រទេសកម្ពុជា" ។

សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សបន្ថែមថា ធនធាន និងថវិកាគ្រប់គ្រាន់គួរត្រូវបានផ្តល់សម្រាប់អាជ្ញាធរដើម្បីឃ្លាំមើល និងស៊ើបអង្កេតទៅលើករណីពលកម្មកុមារ និងអនុវត្តមានប្រសិទ្ធភាពនូវការដាក់ទោសប្រឆាំងនឹងជនប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងច្បាប់ស្តីពីការងារ និងសេចក្តីណែនាំផ្សេងៗ។ ដូចគ្នាផងដែរ រាជរដ្ឋាភិបាល និងម្ចាស់សិប្បកម្មគួរមានទំនួលខុសត្រូវ និងគណនេយ្យភាពចំពោះភាពខ្វះចន្លោះក្នុងការបញ្ឈប់ទម្រង់ណាមួយ ឬទាំងអស់នៃពលកម្មកុមារ។

លីកាដូក៏បានឲ្យដឹងទៀតថា កាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៩ ក្រសួងការងារបានចេញសេចក្តីណែនាំដោយមានវិធានការ៥ចំណុចក្នុងការហាមក្មេងចូលទៅក្នុងបរិវេណខ្សែសង្វាក់ផលិតកម្មនៃសិប្បកម្មផលិតឥដ្ឋ។ វិធាន

ការទាំងនេះរួមមាន៖ ការធ្វើស្លាកសញ្ញាហាមឃាត់ ការហាមឃាត់ជាដាច់ខាតនូវការប្រើប្រាស់ទាសភាពបំណុល ការឃ្លាំមើលជាប្រចាំនៃខ្សែសង្វាក់ ផលិតកម្ម ការរៀបចំកន្លែងស្នាក់នៅឲ្យឃ្លាតឆ្ងាយពីខ្សែសង្វាក់ផលិតកម្ម និងការហាមឃាត់ជាដាច់ខាតនូវរាល់ទម្រង់នៃការកេងប្រវ័ញ្ចពលកម្មលើកុមារ។

សម្ព័ន្ធខ្មែរជំរឿន សង្កត់ធ្ងន់ថា អ្វីដែលសំខាន់ជាងការចេញសេចក្តីណែនាំទៅទៀតនោះគឺ អាជ្ញាធរគួរតែអនុវត្តវិធានការផ្លូវច្បាប់ឲ្យបានហ្មត់ចត់រួមមាន៖ ការធ្វើអធិការកិច្ចបានតឹងរឹង និងទៀងទាត់ ការធ្វើការជាមួយម្ចាស់សិប្បកម្មផលិតឥដ្ឋ ការអប់រំកម្មករអំពីហានិភ័យ និងបទល្មើសព្រហ្មទណ្ឌនៃពលកម្មកុមារ និងទាសភាពបំណុល៕ ដោយ នឿត សម្ផស្ស

## ថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ០២នាក់ ឲ្យមកកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI 12-06-2019

ឧត្តរមានជ័យ៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិជាំ នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០២នាក់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

## មីយ៉ាន់ម៉ាបញ្ជូនពលករ ជាង៣ម៉ឺននាក់ទៅធ្វើការក្រៅប្រទេស

http://nokorwatnews.com/archives/ 12-06-2019

ដោយសារតែការងារនៅក្នុងស្រុក មានតិច មិនអាចបំពេញតាមតម្រូវការ របស់ពលរដ្ឋ បានឡើយ ។ ទាំងនោះ ហើយបានជារដ្ឋាភិបាលមីយ៉ាន់ម៉ា សម្រេចបញ្ជូនពលករទៅក្រៅប្រទេសជាច្រើនក្នុងមួយខែៗ ដោយនៅក្នុងខែឧសភាកន្លងមក មានពលករដល់ទៅជាង៣ម៉ឺននាក់បានបញ្ជូនទៅក្រៅប្រទេស ។

កាលពីថ្ងៃទី១២ ខែមិថុនា មីយ៉ាន់ម៉ា បានប្រកាសថា ខ្លួនបានបញ្ជូនពលករទៅបម្រើការនៅក្រៅប្រទេសប្រហែល ៣០,៣២៦ នាក់ កាលពីខែឧសភា ឆ្នាំ២០១៩ ។ ពលករទាំងនោះ ចេញទៅបម្រើការនៅក្រៅប្រទេសពេញលក្ខណៈច្បាប់ ។ ក្រសួង ពលកម្ម, ចំណាកស្រុក និងប្រជាជន របស់មីយ៉ាន់ម៉ា បញ្ជាក់ថា ពលករទាំងនោះ រួមមាន ២០,៩៧៧ នាក់ ទៅកាន់ប្រទេសថៃ, ៨ ២៣៧ នាក់បញ្ជូនទៅកាន់ម៉ាឡេស៊ី, ៦៥៨ នាក់ ទៅកាន់ជប៉ុន, ៣៧៧នាក់ទៅកាន់កូរ៉េខាងត្បូង និង៣៧នាក់ទៅបម្រើការនៅប្រទេសសិង្ហបុរី ។ បន្ថែមពីលើនេះ ការងារក្នុងស្រុក មានប្រហែល ២៤,០១៩ ត្រូវបានផ្តល់ជូននៅក្នុងតំបន់មួយចំនួន អំឡុងខែឧសភា ឆ្នាំ២០១៩ ដូចជានៅទីក្រុង Yangon, Bago, Mandalay, Sagaing, Ayeyawaddy និងនៅតំបន់Tanintharyi ផងដែរ។

ដោយឡែកនៅក្នុងខេត្ត Kachin, Kayah, Kayin, Chin, Mon, Shan និង Rakhine នៅទីតាំងទាំងនេះ ការផ្តល់ជូនការងារធ្វើសម្រាប់ប្រជាជន មានប្រហែល១ ៦៨៥នាក់ ។ មីយ៉ាន់ម៉ា បានបញ្ជាក់ថា ខ្លួនកំពុងបង្កើតឲ្យមានឱកាសការងារកាន់តែប្រសើរ តាមរយៈការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងពាណិជ្ជកម្ម តាមអនឡាញថ្មីៗមួយ ដែលប្រៀបប្រដូចទៅនឹងស្ពានសម្រាប់ចម្លងរវាង និយោកជិក និងនិយោជក ។

កាលពីខែឧសភា ឆ្នាំ២០១៩ មីយ៉ាន់ម៉ាបានបង្កើតក្របខ័ណ្ឌថ្នាក់ជាតិរយៈពេល៥ឆ្នាំមួយ ដើម្បីគ្រប់គ្រងពលករចំណាកស្រុកអន្តរជាតិ ដោយសហការជាមួយអង្គការជនភៀសខ្លួនអន្តរជាតិ IOM ។ រដ្ឋាភិបាលមីយ៉ាន់ម៉ាក៏បានដាក់ចេញគោលនយោបាយស្តីអំពីពលករចំណាកស្រុកដែលទៅបម្រើការនៅក្រៅប្រទេសផងដែរ ដើម្បីឲ្យលក្ខណៈច្បាប់ តាមរយៈភ្នាក់ងាររបស់ខ្លួនដែលបានដាក់ពង្រាយនៅបរទេសចំនួន២៧៧ ទីកន្លែង ។ តាមក្រសួងពលកម្ម, ចំណាកស្រុក និងប្រជាជនមីយ៉ាន់ម៉ាបញ្ជាក់ថា ពលរដ្ឋមីយ៉ាន់ម៉ាដែលកំពុងធ្វើការនៅក្រៅប្រទេសសព្វថ្ងៃនេះ កើនដល់៥លាននាក់ហើយ ក្នុងនោះប្រហែល៣លាននាក់ ជាពលករវ័យក្មេង កំពុងបម្រើការនៅក្នុងប្រទេសថៃ ៕

## ជនអ៊ីស្លាមរ៉ូហ៊ីងយ៉ាង៦៥នាក់ ត្រូវបានរកឃើញនៅលើទូកខូចនៅសមុទ្រភាគខាងត្បូងថៃ

http://www.rasmeinews.com/ June 13, 2019, 8:17 AM

ក្រុមមន្ត្រីយោធាជើងទឹកថៃ បាននិយាយនៅថ្ងៃពុធ ទី១២ ខែមិថុនាថា ក្រុមជនអ៊ីស្លាមរ៉ូហ៊ីងយ៉ាងចំនួន៦៥នាក់ ត្រូវបានរកឃើញនៅលើទូកខូចមួយនៅសមុទ្រ នៅភាគខាងត្បូងនៃប្រទេសថៃ។ ទូកនេះ ត្រូវបានរកឃើញកាលពីថ្ងៃអង្គារនៅសមុទ្រភាគខាងត្បូងថៃ ចម្ងាយ៤០០គីឡូម៉ែត្រពីព្រំដែននៃប្រទេសមីយ៉ាន់ម៉ា។

សូមបញ្ជាក់ថា ជនជាតិរ៉ូហ៊ីងយ៉ាប្រហែល ៧៤០.០០០នាក់ បានរត់គេចខ្លួនចេញពីប្រទេសមីយ៉ាន់ម៉ាចាប់តាំងពីការបង្ក្រាបឃោរឃៅរបស់កងទ័ពកាលពីឆ្នាំ២០១៧ ប្រឆាំងក្រុមជនជាតិភាគតិចដែលមិនមានរដ្ឋនេះនៅក្នុងប្រទេសដែលមានពុទ្ធសាសនិកភាគច្រើននេះ។ ភាគច្រើននៃក្រុមអ៊ីស្លាមរ៉ូហ៊ីងយ៉ាង បានរត់គេចខ្លួនទៅជំរំជនភៀសខ្លួនដែលមានមនុស្សច្រើននៅប្រទេសបង់ក្លាដែស ខណៈដែលអ្នកផ្សេងទៀតបានធ្លាក់ចូលក្នុងអំពើការជួញដូរមនុស្សនៅពេលពួកគេស្វែងរកជីវិតប្រសើរនៅប្រទេសម៉ាឡេស៊ីឬថៃនោះ៕ដោយ៖ *សុខា/sn*

# ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩

## ក្រុមលេខាគណៈកម្មការព្រំដែនកម្ពុជា-ថៃប្រជុំគ្នា ដើម្បីត្រៀមទៅប្រជុំ (RBC) នៅប្រទេសថៃ

http://bayontv.com.kh/ 14/06/2019

ភ្នំពេញ ៖ ឧត្តមសេនីយ៍ទោ សេង ជារិន មេបញ្ជាការរងនាយសេនាធិការយោធភូមិភាគទី៥ និងជាប្រធានលេខា គណៈកម្មាធិការព្រំដែនថ្នាក់ភូមិភាគកម្ពុជា-ថៃ ដែលហៅកាត់ថា (RBC) នាព្រឹកថ្ងៃសុក្រ ទី១៤ ខែមិថុនា ឆ្នាំ២០១៩ នេះ បានដឹងនាំក្រុមការងារប្រជុំគណៈកម្មការព្រំដែនកម្ពុជា-ថៃដើម្បីត្រៀមក្នុងកិច្ចប្រជុំលើកទី២៧ ដែលប្រទេសថៃធ្វើជាម្ចាស់ផ្ទះ។ លោកឧត្តមសេនីយ៍ សេង ជារិន ប្រធានក្រុមលេខាគណៈកម្មការកម្ពុជា-ថៃ បានបញ្ជាក់ថា នៅក្នុងកិច្ចប្រជុំលើកទី២៧ (RBC) ដែលភាគីថៃធ្វើជាម្ចាស់ផ្ទះដែល នឹងជួបប្រជុំគ្នានៅលើទឹកដីថៃ នាថ្ងៃខាងមុខនេះ គឺនឹងផ្តោតសំខាន់ទៅលើបញ្ហាមួយចំនួនធំ ដូចជា បញ្ហាប្រជាពលករធ្វើការចំណាកស្រុក បញ្ហាប្រជាពលរដ្ឋធ្វើដំណើរទៅប្រទេសថៃដើម្បីព្យាបាលជំងឺ បញ្ហាបង្ការ និងបង្ក្រាបបទល្មើសឆ្លងដែន បញ្ហាប្រជាពលរដ្ឋខ្មែរចូលឆ្លងដែនទៅកាប់ឈើនៅប្រទេសថៃ បញ្ហាអន្តោប្រវេសន៍ខុសច្បាប់ បញ្ហាការចរាចរណ៍នៅគ្រឿងញៀន បញ្ហាទប់ស្កាត់ និងបង្ក្រាបនូវភេរវកម្មឆ្លងដែនជាដើម។

លោកឧត្តមសេនីយ៍រូបនេះ បានបន្តទៀតថា កិច្ចប្រជុំគណៈកម្មការព្រំដែន កម្ពុជា-ថៃ (RBC) លើកទី២៧ នេះ គឺនឹងលើកឡើងនូវបញ្ហាទាំងប៉ុន្មាននេះ ដាក់ចូលទៅក្នុងកិច្ចប្រជុំ ដើម្បីរួមគ្នាធ្វើការដោះស្រាយ សំដៅធ្វើការពង្រឹង និងពង្រីក បន្ថែមទៀត ទៅលើចំណងសម្ព័ន្ធមេត្រីភាពរវាងព្រំដែនទាំង២ (កម្ពុជា-ថៃ) នៅក្នុងទិសដៅតែមួយគឺព្រំដែនដែលមាន សុខសន្តិភាព ស្ថេរភាព នឹងប្រែក្លាយព្រំដែន នៃប្រទេសទាំង២ ឲ្យមានការអភិវឌ្ឍជឿនលឿនបន្ថែមទៀត។

សូមបញ្ជាក់ថា កាលពីកិច្ចប្រជុំ RBC លើកទី២៦ កម្ពុជា-ថៃដែលបានធ្វើឡើងនៅទីក្រុង ប៉ាតាយ៉ាប្រទេសថៃកាលពីកន្លងទៅនោះភាគីទាំងពីរ បានផ្តោតលើកិច្ចសហប្រតិបត្តិការទ្វេភាគី លើវិស័យសន្តិសុខ ដែលមានទី១– ការបង្ការទប់ស្កាត់ការកើតឡើងវិវាទ ទី២– ទប់ស្កាត់បញ្ហាឧក្រិដ្ឋកម្ម និងភេរវកម្មឆ្លងដែន ទី៣– ការពារបង្ក្រាបទប់ស្កាត់គ្រឿងញៀនឆ្លងដែន ទី៤– បង្ក្រាបបទល្មើសតាមព្រំដែន ទី៥– ការឆ្លងកាត់តាមព្រំដែន ទី៦– ទប់ស្កាត់ការជួញដូរមនុស្ស និងក្មេងអនាថា និងទី៧ – ពលករខុសច្បាប់ជាដើម ហើយតាមរយៈកិច្ចប្រជុំភាគីទាំងពីរបាន ស្វែងរកដំណោះស្រាយបង្ការនិងទប់ស្កាត់រួមគ្នា ដើម្បីផលប្រយោជន៍ប្រជាជន និងប្រទេស ទាំងពីរ៕

# បុរសបានបញ្ចប់ជីវិតដោយអាថ៌កំបាំង គ្មានអ្នកដឹងមូលហេតុ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៩ ម៉ោង ០៩:៤៧ មុំត សារុន

ខេត្តបន្ទាយមានជ័យ ៖ សពពលករម្នាក់ត្រូវភាគីថៃបញ្ជូនត្រឡប់តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត នៅរសៀលថ្ងៃទី13 ខែមិថុនា ឆ្នាំ2019 ក្រោយបញ្ចប់ជីវិតដ៏សែនអាថ៌កំបាំង គឺស្លាប់ដោយចង.កក្នុងប្រឡោះខ្សែខាងលើការ៉ុងខ្សាច់ដែលចងទុកសម្រាប់ទាត់លេង ហើយក៏គ្មានអ្នកណាម្នាក់ដឹងពីមូលហេតុឡើយ បានត្រឹមបង្កឱ្យភ្ញាក់ផ្អើលលើទឹកដីថៃ។

ជនរងគ្រោះខាងលើឈ្មោះទុយ បុត្រា ភេទប្រុស អាយុ26ឆ្នាំ ជាកម្មករប្រមូលលាមកមាន់នៅខេត្តនគររាជសីម៉ា ប្រទេសថៃ និងមានស្រុកកំណើតនៅភូមិស្នួលទ្រេត ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ បើតាមកម្មកររួមអាជីពមួយក្រុម និងជាសាច់ញាតិផងនោះប្រាប់កោះសន្តិភាពថា ជនរងគ្រោះខាងលើជាមនុស្សនៅលីវ ហើយមុនស្លាប់បានអង្គុយផឹកស្រាថៃ (ឡាវខាវ) 1ដបគ្នា4នាក់ កាលពីព្រលប់ថ្ងៃទី11 មិថុនា លុះម៉ោងជាង10យប់ថ្ងៃដដែល ក្រោយពីផឹកស៊ីរួច ក៏បែកគ្នាទៅសម្រាករៀងៗខ្លួន។

បើតាមឈ្មោះ ស៊ឹម សែន ភេទប្រុស អាយុ22ឆ្នាំ ដែលប្រទះឃើញសពជនរងគ្រោះមុនគេនិយាយថា ដំបូងគេឃើញជនរងគ្រោះអង្គុយមុខបន្ទប់ដេក លុះម៉ោងប្រហែល10កន្លះយប់ថ្ងៃដដែល ខ្លួនបានចេញពីបន្ទប់រកបត់ជើងតូច ស្រាប់តែប្រទះឃើញជនរងគ្រោះស្លាប់ព្យួ.កនៅចំណុចប្រឡោះខ្សែដែលចងការ៉ុងខ្សាច់ទុកសម្រាប់នាំគ្នាទាត់លេង ដើម្បីហាត់ប្រាណនោះតែម្តង។

យ៉ាងណាក៏ដោយ ក្រុមកម្មករ រួមអ្នកអាជីពនិយាយថា ជនរងគ្រោះមុនស្លាប់តែងតែនិយាយផ្តេសផ្តាស់ខុសពីធម្មតា។ ក្រោយកើតហេតុ សពជនរងគ្រោះត្រូវបានបញ្ជូនដល់វត្តបាលិលេយ្យក្នុងសង្កាត់ប៉ោយប៉ែត ហើយត្រូវសាច់ញាតិជួលរថយន្តដឹកទៅលំនៅដ្ឋាន ដើម្បីធ្វើបុណ្យតាមប្រពៃណី៕ (កែសម្រួលដោយ ៖ បុប្ផា)

# ថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ០១នាក់ ឲ្យមកកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI 13-06-2019

ឧត្តរមានជ័យ៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិជាំ នាថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០១នាក់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

# សមាគម អ្នកនេសាទនៅថៃ គំរាមធ្វើបាតុកម្ម នៅបាងកក ប្រសិនបើរដ្ឋាភិបាលថ្មី មិនដកច្បាប់ រឹតបន្តឹងចោលនោះទេ

https://www.dap-news.com/archives/ ByID:112 Posted on 13 June 2019 | 14:57

បរទេស៖ សមាគមអ្នកនេសាទជាតិរបស់ថៃ បានគំរាមធ្វើបាតុកម្មនៅក្នុងរដ្ឋធានីបាងកកប្រសិនបើរដ្ឋាភិបាលថ្មី មិនអើពើ ចំពោះសេចក្តីត្រូវការរបស់ខ្លួន ក្នុងការធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិយ៉ាងតឹងរ៉ឹងលើអ្នកនេសាទ និងក្រុមកម្មករលើទូក នេសាទនោះទេ។ យោងតាមសារព័ត៌មានថៃ បាងកកប៉ុស្តិ៍ ចេញផ្សាយនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ បានឱ្យដឹង ដោយផ្អែកតាមការលើកឡើងរបស់លោក លោក មង្គល ស៊ុកឆារឿន ខាណា ប្រធានសមាគម កាលពីថ្ងៃពុធថា «ប្រសិនបើច្បាប់ទាំងនេះមិនត្រូវបានផ្លាស់ប្តូរនោះទេ ក្រុមអ្នកនេសាទនឹងធ្វើដំណើរទៅកាន់ទីក្រុងបាងកក ហើយបោះជំរុំនៅមុខក្រសួងកសិកម្មថៃតែម្តង» ។ លោកបាននិយាយថា ច្បាប់ទាំងនេះនាំឱ្យមានការខ្វះខាត

កម្មករ នៅក្នុងវិស័យនេសាទ ដោយបង្ខំឱ្យប្រតិបត្តិករជាច្រើនមិនអាចរកស៊ីបាន។ សមាជិកសមាគម នឹងជួបប្រជុំគ្នានៅឯកិច្ចប្រជុំទូទៅរបស់ខ្លួន នៅទីផ្សារអាហារដ្ឋាន Talay Thai ក្នុងស្រុក Muang ខេត្ត ប៉ុទុម សាខន នៅថ្ងៃទី ២៨ ខែមិថុនា។ ពួកគេគ្រោងនឹងពិភាក្សាអំពីបញ្ហាដែលប្រតិបត្តិករនេសាទ ដែលត្រូវបានដាក់ទណ្ឌកម្មរយៈពេល ៥ឆ្នាំមកនេះ ចាប់តាំងពីរដ្ឋាភិបាល បានចាប់ផ្តើមអនុវត្តវិធានការ ក្នុងការទប់ស្កាត់ការអនុវត្តនេសាទខុសច្បាប់ ដែលមិនបានរាយការណ៍ និងគ្មានច្បាប់កំណត់ (IUU) សម្រាប់ការនេសាទ។ លោកបាននិយាយថា ពួកគេក៏នឹងស្វែងរកដំណោះស្រាយ ចំពោះបញ្ហាទាំងនេះហើយពង្រាង សំណើមួយទៅកាន់រដ្ឋាភិបាល ដើម្បីទូទាត់សំណងសម្រាប់ពួកគេ៕ ប្រែសម្រួលៈ ណៃ តុលា

## ថៃចោទប្រកាន់ក្រុមនាវិកដឹកជនរ៉ូហ៊ីងយ៉ាពីបទជួយជនអន្តោប្រវេសន៍ខុសច្បាប់

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 14/06/2019

ថៃ ៖ ប៉ូលីសបាននិយាយកាលពីថ្ងៃពុធថា អាជ្ញាធរថៃបានចោទប្រកាន់មេក្រុម និងនាវិកទូកដែលដឹកជនមូស្លីមភាគតិចរ៉ូហ៊ីងយ៉ាចំនួន ៦៥ នាក់ពីបទជួយជនអន្តោប្រវេសន៍ខុសច្បាប់បន្ទាប់ពីក្រុមនេះត្រូវបានគេរកឃើញជាប់គាំងនៅលើកោះភាគខាងត្បូងនៃប្រទេសថៃ ។ ប៉ូលីសបាននិយាយកាលពីថ្ងៃអង្គារថា បុរស ២៩ នាក់ ស្ត្រី ៣១ នាក់ និងកុមារ ៥ នាក់ត្រូវបានគេរកឃើញនៅលើកោះ Rawi នៅខេត្ត Satun ជាកន្លែងដែលទូករបស់ពួកគេត្រូវបានកើលឡើងគោកដោយសារតែពីបញ្ហាម៉ាស៊ីន ។ ក្រុមនាវិកដែលជាជនជាតិមីយ៉ាន់ម៉ា ៥ នាក់ និងមេក្រុមជនជាតិថៃត្រូវបានចោទប្រកាន់ពីបទជួយជនបរទេសឲ្យចូលទៅក្នុងប្រទេស ដោយខុសច្បាប់ជាបទល្មើសមួយដែលអាចជាប់គុករហូតដល់ ១០ ឆ្នាំ ។

លោកឧត្តមសេនីយ៍ Suchart Thirasawat បានប្រាប់រ៉យទ័រថា "យើងបានចោទប្រកាន់ជនសង្ស័យជនជាតិថៃ និងមីយ៉ាន់ម៉ាពីបទជួយដល់ជនអន្តោប្រវេសន៍ចូលមកដោយខុសច្បាប់" ។ លោកបាននិយាយថា ជនរ៉ូហ៊ីងយ៉ាកំពុងត្រូវបានយកចិត្តទុកដាក់ ខណៈអាជ្ញាធរព្យាយាមកំណត់ថាតើពួកគេជាជនរងគ្រោះនៃការជួញដូរមនុស្សឬយ៉ាងណា ។ លោក Suchart បានថ្លែងថា "យើងមិនបានដាក់ការចោទប្រកាន់ប្រឆាំងនឹងអ្នកដំណើររ៉ូហ៊ីងយ៉ានោះទេ ហើយយើងកំពុងធ្វើការ ដើម្បីកំណត់ថាតើពួកគេជាជនរងគ្រោះឬអត់" ។ ជនមូស្លីមរ៉ូហ៊ីងយ៉ាជាច្រើននាក់បានធ្វើដំណើរតាមទូកនៅក្នុងប៉ុន្មានខែថ្មីៗនេះ ដើម្បីព្យាយាមទៅដល់ប្រទេសម៉ាឡេស៊ី ដែលជាផ្នែកមួយនៃអ្វីដែលអាជ្ញាធរបារម្ភថា អាចជារលកថ្មីនៃការរត់ពន្ធមនុស្សតាមសមុទ្រ បន្ទាប់ពីការបង្ក្រាបការជួញដូរមនុស្សនៅឆ្នាំ ២០១៥ ។

លោក Jaruwat Kliangklao អភិបាលខេត្ត Satun បាននិយាយថា "ផ្អែកតាមអ្វីដែលយើងដឹងរហូតមកដល់ពេលនេះជនរ៉ូហ៊ីងយ៉ាទាំងនេះមកពីតំបន់ព្រំដែនរវាងមីយ៉ាន់ម៉ា និងបង់ក្លាដេស ហើយពួកគេកំពុងធ្វើដំណើរទៅប្រទេសម៉ាឡេស៊ី" ។

ប្រទេសមីយ៉ាន់ម៉ាចាត់ទុកជនរ៉ូហ៊ីងយ៉ា ជាជនអន្តោប្រវេសន៍ខុសច្បាប់មកពីទ្វីបឥណ្ឌា ហើយបានឃុំឃាំងមនុស្សរាប់ម៉ឺននាក់នៅក្នុងជំរុំលាតសន្ធឹងនៅរដ្ឋរ៉ាក់ឃីនចាប់តាំងពីអំពើហឹង្សាវាយប្រហារតំបន់នេះក្នុងឆ្នាំ ២០១២ ។ ភាពចលាចលនេះបានជំរុញឲ្យមនុស្សរាប់ម៉ឺននាក់នៃជនរ៉ូហ៊ីងយ៉ារត់ភៀសខ្លួនទៅប្រទេសមីយ៉ាន់ម៉ាតាមសមុទ្រដែលជាការភៀសខ្លួនមួយឈានដល់កម្រិតកំពូលនៅឆ្នាំ ២០១៥ នៅពេលដែលមនុស្សប្រមាណ ២៥,០០០ នាក់ដែលបានឆ្លងកាត់សមុទ្រអាដាម៉ាន់សម្រាប់ប្រទេសថៃ ម៉ាឡេស៊ី និងឥណ្ឌូនេស៊ីបានលង់ទឹកជាច្រើននាក់នៅក្នុងទូកដែលគ្មានសុវត្ថិភាព និងការដឹកជញ្ជូនលើសចំណុះ ៕

# ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩

## ក្រសួងការងារ រៀបចំសិក្ខាសាលាស្តីពី យុទ្ធនាការ វិធានការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ នៅតាមបណ្តារាជធានីខេត្ត

http://www.mlvt.gov.kh/index.php 17-06-2019

(ភ្នំពេញ,ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩)៖ ដើម្បីគ្រប់គ្រង និងអភិវឌ្ឍវិស័យសិប្បកម្មផលិតឥដ្ឋឱ្យមានបទដ្ឋានការងារល្អប្រសើរ និងធានានិរន្តរភាព លុបបំបាត់ពលកម្មកុមារនៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំសិក្ខាសាលាស្តីពី យុទ្ធនាការ វិធានការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ នៅតាមបណ្តារាជធានីខេត្ត ដែលមានសិប្បកម្មផលិតឥដ្ឋ លើកទីមួយ ឆ្នាំ២០១៩។ សិក្ខាសាលានេះ រៀបចំឡើងក្នុងគោលបំណង៖

១.ផ្តល់ការណែនាំដល់មន្ត្រីអធិការកិច្ចការងារ និងសមត្ថកិច្ចពាក់ព័ន្ធ ដែលទទួលសិទ្ធិជានគរបាលយុត្តិធម៌ ធ្វើអន្តរាគមន៍ក្នុងការដកហូត ទប់ស្កាត់ និងសមាហរណកម្មកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ។

២.បង្កើនការយល់ដឹង និងលើកកម្ពស់យុទ្ធនាការប្រឆាំងនឹងពលកម្មកុមារ តាមរយៈការកំណត់និយមន័យពលកម្មកុមារ ការលាតត្រដាងអំពីមូលហេតុ និងផលប៉ះពាល់នៃពលកម្មកុមារ គោលនយោបាយ និងបទដ្ឋានគតិយុត្តិ និងវិធានការនានា ដើម្បីប្រឆាំងនឹងពលកម្មកុមារនៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ។

៣.សហការ និងចូលរួមអនុវត្តវិធានការអធិការកិច្ចការងារ យន្តការទប់ស្កាត់ និងបង្ក្រាបបទល្មើស និងប្រព័ន្ធត្រួតពិនិត្យ តាមដានពលកម្មកុមារនៅកន្លែងធ្វើការ (សិប្បកម្មផលិតឥដ្ឋ) នៅសាលារៀន និងនៅតាមសហគមន៍ដែលកុមារ និងក្រុមគ្រួសាររបស់ពួកគេរស់នៅ ជូនស្ថាប័នថ្នាក់ក្រោមជាតិបន្តអនុវត្ត។

៤. ការចូលរួមចំណែករបស់មន្ត្រីអធិការកិច្ចការងារ និងសមត្ថកិច្ចពាក់ព័ន្ធក្នុងការផ្តល់យោបល់ ចែករំលែកបទពិសោធន៍ និងឆ្លុះបញ្ចាំងវឌ្ឍនភាពថ្មីៗនៃវិស័យសិប្បកម្មផលិតឥដ្ឋ ដើម្បីអោយសេចក្តីព្រាងគោលការណ៍ណែនាំនេះមានលក្ខណៈគ្រប់ជ្រុងជ្រោយក្នុងន័យលើកកម្ពស់លក្ខខណ្ឌការងារ និងឧត្តមប្រយោជន៍របស់កុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អញ្ជើញជាអធិបតីនាឱកាសបើកសិក្ខាសាលានេះដែរ លោកជំទាវ ស៊ើង សរសុចិត្តា រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តំណាង ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី អ៊ិត សំហេង មានប្រសាសន៍លើកឡើងថា កុមារគឺជាធនធានមនុស្សដែលមិនអាចខ្វះបាន សម្រាប់ការអភិវឌ្ឍប្រទេសជាតិនាពេលអនាគត ដើម្បីឱ្យធនធានមនុស្សប្រកបដោយសក្តានុពល ការផ្តល់កិច្ចការពារ និងការអភិវឌ្ឍកុមារ គឺជាភារកិច្ចយ៉ាងសំខាន់ ដែលតម្រូវឱ្យមានការអនុវត្តតាមបែបពហុវិស័យបញ្ចូលគ្នា ហើយសកម្មភាព អាទិភាពទាំងឡាយដែលត្រូវអនុវត្ត រួមមាន ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត ការកែលម្អយន្តការដែលមានស្រាប់ ការពិនិត្យតាមដាន ការពង្រឹង និងពង្រីកសេវាអប់រំ ការការពារ និងថែទាំសុខភាពកុមារ ដោយផ្តោតជាពិសេសលើកុមាររងគ្រោះ និងងាយ រងគ្រោះ។

លើសពីនេះទៀត ក្នុងនាមរដ្ឋភាគី ព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នលើ យុទ្ធបករណ៍អន្តរជាតិនានា ដើម្បីការពារកុមារពីការកេងប្រវ័ញ្ចពលកម្មកុមារ និងលើកកម្ពស់សិទ្ធិជាមូលដ្ឋានរបស់ពួកគេ ជាអាទិ៍ អនុសញ្ញាស្តីពីសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ អនុសញ្ញាលេខ ១៣៨ ១៨២ និង២៩របស់អង្គការអន្តរជាតិខាងការងារដែលពាក់ព័ន្ធនឹងការហាមប្រាម និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកការលុបបំបាត់ពលកម្មកុមារជាបញ្ហាដ៏សំខាន់មួយ នៅក្នុងចំណោមបញ្ហាសំខាន់ជាច្រើនរបស់កម្ពុជា ជាពិសេសគឺកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងដំណើរឆ្ពោះទៅការបញ្ចប់ពលកម្មកុមារនៅឆ្នាំ២០២៥ ដែលស្របនឹងគោលដៅអភិវឌ្ឍន៍សាកលប្រកបដោយចីរភាព(២០១៥-២០៣០)។

លោកជំទាវរដ្ឋលេខាធិការ បានអំពាវនាវឱ្យគ្រប់ភាគីពាក់ព័ន្ធចូលរួមទាំងអស់គ្នា សហការយ៉ាងជិតស្និត និងអនុវត្តឱ្យបានហ្មត់ចត់ តាមទិសដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលដោយមានឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការចូលរួមអនុវត្តប្រឆាំងដាច់ខាតទៅនឹងសកម្មភាពគ្រប់រូបភាពក្នុងការប្រើប្រាស់ពលកម្មកុមារនៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋឱ្យបានជោគជ័យដែលជាកាតព្វកិច្ចចូលរួមទប់ស្កាត់កុមារពី ទង្វើដែលនាំឱ្យអន្តរាយដល់ឱកាសសិក្សា សុខភាព សុខុមាលភាព និង ការអភិវឌ្ឍរបស់កុមារ។ លោកជំទាវសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា ខ្លឹមសារនៃសិក្ខាសាលានេះនឹងត្រូវបានប្រើប្រាស់ជាប្រយោជន៍ រួមទាំងមានការ ប្តេជ្ញាចិត្តយ៉ាងធំធេងក្នុងការអនុវត្តសកម្មភាពជាក់លាក់ប្រកបដោយជោគជ័យ ដើម្បីរួមចំណែកធ្វើឱ្យវិស័យសំណង់នៅកម្ពុជាគ្មានពលកម្មកុមារ៕

## អាជ្ញាធរថៃដោះលែងអ្នកទោស៥នាក់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៩ ម៉ោង ១៤:២០ ម៉ុត សារុន

ខេត្តឧត្តរមានជ័យ ៖ ក្រុមអាជ្ញាធរថៃបានធ្វើការដោះលែងអ្នកទោសខ្មែរចំនួន៥នាក់ និងបញ្ជូនមកប្រគល់ឱ្យក្រុមអាជ្ញាធរកម្ពុជានៅមាត់ច្រកទ្វារតំបន់ជប់គគីរ កាលពីរសៀលថ្ងៃទី១៣ មិថុនា២០១៩ ស្ថិតនៅក្នុងភូមិជប់គគីខាងលិច ឃុំបេង ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។

អ្នកទោសខ្មែរទាំង៥នាក់ខាងលើដែលក្រុមអាជ្ញាធរថៃដោះលែង ១-ឈ្មោះខាំ ផន ភេទប្រុសអាយុ៥២ឆ្នាំ ទីលំនៅភូមិបុស្សមាស ឃុំពពាល ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ២-ឈ្មោះខុម ហៃ ភេទប្រុស អាយុ៣៥ឆ្នាំ ៣-ឈ្មោះស៊ុយ តាំងអន ភេទប្រុស អាយុ៣១ឆ្នាំ ៤-ឈ្មោះជិត ហុីម ភេទប្រុស អាយុ២១ឆ្នាំ ។ អ្នកទាំង៤នាក់នេះមានទីលំនៅក្នុងភូមិអូរបិញ្ជៀន ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ត្រូវអាជ្ញាធរថៃចាប់ខ្លួនកាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ និង៥-ឈ្មោះហេង មស់ ភេទប្រុស អាយុ២៧ឆ្នាំ រស់នៅភូមិ១០៥ ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ត្រូវទាហានថៃចាប់ខ្លួនកាលពីថ្ងៃទី១៤ ធ្នូ ២០១៤។

តាមប្រភពពីមន្ត្រីបម្រើការងារនៅមាត់ច្រកទ្វារតំបន់ជប់គគីរបានឱ្យដឹងថា អ្នកទោសខ្មែរទាំង៥នាក់នោះ ត្រូវក្រុមអាជ្ញាធរថៃឃាត់ខ្លួនចោទពីបទលួចឆ្លងដែនកាប់ឈើគ្រញូងក្នុងដីថៃ ក្នុងនោះម្នាក់ជាប់ពន្ធនាគារ នៅស្រុកណាំរ៉ង ខេត្តបុរីរ៉ុំ និង៤នាក់ទៀតជាប់ពន្ធនាគារនៅខេត្តស៊ីសាកេត ប្រទេសថៃ។ តាមប្រភពពីមន្ត្រីដដែលបានបញ្ជាក់ថាក្រោយពីបានទទួលអ្នកទោសខ្មែរពីក្រុមអាជ្ញាធរថៃរួចមក សមត្ថកិច្ចបានធ្វើការអប់រំណែនាំ និងធ្វើកិច្ចសន្យាឱ្យវិលត្រឡប់ទៅជួបជុំក្រុមគ្រួសារក្នុងថ្ងៃដដែល៕

## ថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ០៣នាក់ ឲ្យមកកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI **June 15 at 12:52 AM •**

កោះកុង៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៥និង៤០នាទី ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃ ចំនួន ០៣នាក់។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ក្រុមហ៊ុនរបស់ថៃ យល់ព្រមបើកប្រាក់ខែ ឲ្យពលករខ្មែរ

https://www.dap-news.com/archives/ ByID:119 Posted on 16 June 2019 | 10:03

**ភ្នំពេញ៖** បន្ទាប់ពីមន្ត្រីស្ថានទូតកម្ពុជា បានជួបតំណាងក្រុមហ៊ុនមួយ ស្ថិតនៅស្រុកសាមផ្រាន ខេត្តណាខនប៉ាធុម ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធ នឹងករណីមិនបើកប្រាក់ឈ្នួល ពលករខ្មែរចំនួន១១នាក់នោះ ក្រុមបានយល់ព្រម បើកឲ្យពួកគាត់ហើយ ក្រោយមានការយល់ច្រឡំ លើចំណុចមួយចំនួន។

បើតាមការចុះផ្សាយរបស់ស្ថានទូតខ្មែរ នៅបាងកក បន្ទាប់ពីពិភាក្សារកដំណោះស្រាយគ្នារួចមក កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៩ តំណាងក្រុមហ៊ុន បានបញ្ជាក់ថា ដោយសារក្រុមហ៊ុនមានសាខាច្រើន នៅតាមបណ្តាខេត្តផ្សេងៗ ហើយសាខាក្នុងខេត្ត ដែលពលករកំពុងធ្វើការ មិនសូវមានការងារឲ្យពលករធ្វើ ដូច្នេះគាត់បានស្នើសុំប្តូរការងារ ឲ្យពលករទៅធ្វើការ នៅសាខាក្នុងខេត្តផ្សេង ប៉ុន្តែពលករមិនយល់ព្រម ហើយបានរត់គេចពីក្រុមហ៊ុន ទៅធ្វើការនៅកន្លែងផ្សេង ដោយមិនបានបើកប្រាក់ឈ្នួល ដែលនៅសល់ ។ ប្រភពបន្តថា «ដូច្នេះក្រុមហ៊ុន នឹងបើកប្រាក់ឈ្នួលដែល នៅសល់ទាំងអស់ឲ្យទៅពលករ ដោយសុំឲ្យពលករទាំងអស់ មកទទួលប្រាក់ឈ្នួល នៅស្នាក់ការរបស់ក្រុមហ៊ុន»៕

## ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩

### អ្នកនាំពាក្យក្រសួងការងារ៖ ការប្រើប្រាស់កុមារក្នុងខ្សែសង្វាក់ផលិតកម្មផលិតឥដ្ឋ អាចជាបទល្មើសព្រហ្មទណ្ឌ

http://www.freshnewsasia.com/index.php/ 2019-06-18

**(ភ្នំពេញ)៖** លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាព្រឹកថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៩នេះ បានបង្ហោះសារមួយក្នុងគណនីហ្វេសប៊ុករបស់លោក ដែលប្រៀបដូចជាកន្លឹងរំឭកដល់ម្ចាស់សិប្បកម្មផលិតឥដ្ឋសារជាថ្មីថា ឲ្យបញ្ឈប់ការប្រើប្រាស់ពលកម្មកុមារ និងការអនុញ្ញាតឲ្យកុមារចូលទៅក្នុងខ្សែសង្វាក់ផលិតកម្មផលិតឥដ្ឋ ជាបន្ទាន់ប្រសិនជាធ្លាប់មាននាពេលកន្លងមក ពីព្រោះសកម្មភាពនេះមិនត្រឹមតែខុសនឹងច្បាប់ការងារ ដែលត្រូវរងនូវការពិន័យពីអធិការការងារនោះទេ វាក៏អាចជាបទល្មើសព្រហ្មទណ្ឌយ៉ាងធ្ងន់ធ្ងរ មួយផងដែរ។ បើតាមការបញ្ជាក់បន្ថែមរបស់លោក ហេង សួរ ជាមួយអង្គភាព Fresh News នៅរសៀលថ្ងៃនេះថា «បទល្មើសព្រហ្មទណ្ឌនេះ ក៏អាចចោទទៅលើមេការ ឬអ្នកគ្រប់គ្រងខ្សែសង្វាក់ផលិតកម្ម ដែលខកខានក្នុងការដាក់ស្លាកសញ្ញាហាមក្មេង និងធ្វើរបងការពារការចូលទៅដល់ខ្សែសង្វាក់ផលិតកម្មផងដែរ។ រីឯឪពុកម្តាយរបស់កុមារដែលជាអ្នកនាំកុមារចូលដល់ខ្សែសង្វាក់ផលិតកម្ម រំលោភលើបំរាម និងលក្ខខណ្ឌសុវត្ថិភាពការងារ ក៏អាចត្រូវចោទប្រកាន់ពីករណីព្រហ្មទណ្ឌដូចគ្នាផងដែរ ប្រសិនជាមានឧបទ្ទវហេតុហេតុគ្រោះថ្នាក់ណាមួយកើតឡើងចំពោះកុមារ»។

សូមរំឭកថា កាលពីពេលថ្មីៗនេះ ក្រសួងការងារ បានចេញសេចក្តីណែនាំលេខ ០៥៦/១៩ ស្តីពី ការហាមក្មេងចូលទៅក្នុងបរិវេណខ្សែសង្វាក់ផលិតកម្មនៃសិប្បកម្មផលិតឥដ្ឋ ដែលក្នុងសេចក្តី ណែនាំនោះក៏បានហាមការប្រើប្រាស់បំណុលដើម្បីដាក់បន្ទុកលើកម្មករផងដែរ។ ដើម្បីជានានូវប្រសិទ្ធភាព នៃការអនុវត្តសេចក្តីណែនាំលេខ ០៥៦/១៩នេះ កាលពីថ្ងៃទី១៧ ខែមិថុនានេះ ក្រសួងក៏បានធ្វើសិក្ខាសាលាផ្សព្វផ្សាយមួយ ដល់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទាំង២៥ ឲ្យបានយល់ និងត្រូវចាប់ផ្តើមសហការជាមួយអាជ្ញាធរមូលដ្ឋានពិនិត្យទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងសិប្បកម្មផលិតឥដ្ឋទាំងអស់ដែលស្ថិតក្នុងដែនរបស់ខ្លួន។

បើតាមលោក ហេង សួរ ឆ្នាំ២០២០ ជាឆ្នាំគោលដៅ ដែលក្រសួងកំណត់មិនឲ្យមានការប្រើប្រាស់កុមារនៅក្នុងសិប្បកម្មផលិតឥដ្ឋ ហើយតាមរយៈសិក្ខាសាលាផ្សព្វផ្សាយ និងវិក្រឹត្យការសមត្ថភាពដល់មន្ត្រី អធិការកិច្ចការងារនាពេលថ្មីៗនេះ គឺមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនឹងចាប់ផ្តើមអនុវត្តការផាកពិន័យភ្លាមៗ ចាប់ពីថ្ងៃនេះតទៅ ប្រសិនជារកឃើញបទល្មើសនេះ៕

## យុទ្ធនាការ វិធានការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ

http://www.cen.com.kh/archives/ June 19, 2019

ភ្នំពេញ៖ មន្ត្រីជាន់ខ្ពស់ក្រសួងកាងារ បានអំពាវនាវឱ្យគ្រប់ភាគីពាក់ព័ន្ធចូលរួមទាំងអស់គ្នា សហការយ៉ាងជិតស្និទ្ធនិងអនុវត្តឱ្យបានហ្មត់ចត់ តាមទិសដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលដោយមានឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការចូលរួមអនុវត្តប្រឆាំងដាច់ខាតទៅនឹងសកម្មភាពគ្រប់រូបភាពក្នុងការប្រើប្រាស់ពលកម្មកុមារ នៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋឱ្យបានជោគជ័យ។ ដើម្បីគ្រប់គ្រង និងអភិវឌ្ឍវិស័យសិប្បកម្មផលិតឥដ្ឋឱ្យមានបទដ្ឋានការងារល្អប្រសើរ និងធានានិរន្តរភាព លុបបំបាត់ពលកម្មកុមារនៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ បានរៀបចំសិក្ខាសាលាស្តីពី យុទ្ធនាការ វិធានការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ នៅតាមបណ្តារាជធានីខេត្ត ដែលមានសិប្បកម្មផលិតឥដ្ឋ លើកទីមួយ ឆ្នាំ២០១៩។ សិក្ខាសាលានេះ រៀបចំឡើងក្នុងគោលបំណង៖

១.ផ្តល់ការណែនាំដល់មន្ត្រីអធិការកិច្ចការងារ និងសមត្ថកិច្ចពាក់ព័ន្ធ ដែលទទួលសិទ្ធិជានគរបាលយុត្តិធម៌ ធ្វើអន្តរាគមន៍ក្នុងការដកហូត ទប់ស្កាត់ និងសមាហរណកម្មកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ។

២.បង្កើនការយល់ដឹង និងលើកកម្ពស់យុទ្ធនាការប្រឆាំងនឹងពលកម្មកុមារ តាមរយៈការកំណត់និយមន័យពលកម្មកុមារ ការលាតត្រដាងអំពីមូលហេតុ និងផលប៉ះពាល់នៃពលកម្មកុមារ គោលនយោបាយ និងបទដ្ឋានគតិយុត្តិ និងវិធានការនានា ដើម្បីប្រឆាំងនឹងពលកម្មកុមារនៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ។

៣.សហការ និងចូលរួមអនុវត្តវិធានការអធិការកិច្ចការងារ យន្តការទប់ស្កាត់ និងបង្ក្រាបបទល្មើស និងប្រព័ន្ធត្រួតពិនិត្យ តាមដានពលកម្មកុមារនៅកន្លែងធ្វើការ (សិប្បកម្មផលិតឥដ្ឋ) នៅសាលារៀន និងនៅតាមសហគមន៍ដែលកុមារ និងក្រុមគ្រួសាររបស់ពួកគេរស់នៅ ជូនស្ថាប័នថ្នាក់ក្រោមជាតិបន្តអនុវត្ត។

៤. ការចូលរួមចំណែករបស់មន្ត្រីអធិការកិច្ចការងារ និងសមត្ថកិច្ចពាក់ព័ន្ធក្នុងការផ្តល់យោបល់ ចែករំលែកបទពិសោធន៍ និងឆ្លុះបញ្ចាំងវឌ្ឍនភាពថ្មីៗនៃវិស័យសិប្បកម្មផលិតឥដ្ឋ ដើម្បីអោយសេចក្តីព្រាងគោលការណ៍ណែនាំនេះមានលក្ខណៈគ្រប់ជ្រុងជ្រោយក្នុងន័យលើកកម្ពស់លក្ខខណ្ឌការងារ និងឧត្តមប្រយោជន៍របស់កុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អញ្ជើញជាអធិបតីនាឱកាសបើកសិក្ខាសាលានេះដែរ លោកស្រីស៊ើង សរសុចិត្តា រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានប្រសាសន៍លើកឡើងថា កុមារ គឺជាធនធានមនុស្សដែលមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍប្រទេសជាតិនាពេលអនាគត ដើម្បីឱ្យធនធានមនុស្សប្រកបដោយសក្តានុពល ការផ្តល់កិច្ចការពារ និងការអភិវឌ្ឍកុមារ គឺជាភារកិច្ចយ៉ាងសំខាន់ ដែលតម្រូវឱ្យមានការអនុវត្តតាមបែបពហុវិស័យបញ្ចូលគ្នា ហើយសកម្មភាព អាទិភាពទាំងឡាយដែលត្រូវអនុវត្ត រួមមាន ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត ការកែលម្អយន្តការដែលមានស្រាប់ ការពិនិត្យតាមដាន ការពង្រឹង និងពង្រីកសេវាអប់រំ ការការពារ និងថែទាំសុខភាពកុមារ ដោយផ្តោតជាពិសេសលើកុមាររងគ្រោះ និងងាយ រងគ្រោះ។ លើសពីនេះទៀត ក្នុងនាមរដ្ឋភាគី ព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នលើ យុទ្ធបករណ៍អន្តរជាតិនានា ដើម្បីការពារកុមារពីការកេងប្រវ័ញ្ចពលកម្មកុមារ និងលើកកម្ពស់សិទ្ធិជាមូលដ្ឋានរបស់ពួកគេ ជាអាទិ៍ អនុសញ្ញាស្តីពីសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ អនុសញ្ញាលេខ ១៣៨ ១៨២ និង២៩ របស់អង្គការអន្តរជាតិខាងការងារដែលពាក់ព័ន្ធនឹងការហាមប្រាម និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។ រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកការលុបបំបាត់ពលកម្មកុមារជាបញ្ហាដ៏សំខាន់មួយ នៅក្នុងចំណោមបញ្ហាសំខាន់ជាច្រើនរបស់កម្ពុជា ជាពិសេសគឺកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងដំណើឆ្ពោះទៅការបញ្ចប់ពលកម្មកុមារនៅឆ្នាំ២០២៥ ដែលស្របនឹងគោលដៅអភិវឌ្ឍន៍សាកលប្រកបដោយចីរភាព(២០១៥-២០៣០)។

លោកស្រីរដ្ឋលេខាធិការ បានអំពាវនាវឱ្យគ្រប់ភាគីពាក់ព័ន្ធចូលរួមទាំងអស់គ្នា សហការយ៉ាងជិតស្និទ្ធនិងអនុវត្តឱ្យបានហ្មត់ចត់ តាមទិសដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលដោយមានឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការចូលរួមអនុវត្តប្រឆាំងដាច់ខាតទៅនឹងសកម្មភាពគ្រប់រូបភាពក្នុងការប្រើប្រាស់ពលកម្មកុមារនៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋឱ្យបានជោគជ័យដែលជាកាតព្វកិច្ចចូលរួមទប់ស្កាត់កុមារពី ទង្វើដែលនាំឱ្យអន្តរាយដល់ឱកាសសិក្សា សុខភាព សុខុមាលភាព និង ការអភិវឌ្ឍរបស់កុមារ។ លោកជំទាវសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា ខ្លឹមសារនៃសិក្ខាសាលានេះនឹងត្រូវបានប្រើប្រាស់ជាប្រយោជន៍ រួមទាំងមានការ ប្តេជ្ញាចិត្តយ៉ាងធំធេងក្នុងការអនុវត្តសកម្មភាពជាក់លាក់ប្រកបដោយជោគជ័យ ដើម្បីរួមចំណែកធ្វើឱ្យវិស័យសំណង់នៅកម្ពុជាគ្មានពលកម្មកុមារ។៚ ដោយៈកូឡាប

## ILO ចុះមកវាយតម្លៃ សកម្មភាព ប្រែក្លាយសេដ្ឋកិច្ចក្រៅ ប្រព័ន្ធនៅកម្ពុជា ឲ្យទៅជាសេដ្ឋកិច្ច ក្នុងប្រព័ន្ធ

https://www.dap-news.com/archives/ ByID:112 Posted on 19 June 2019 | 13:32

ភ្នំពេញ ៖ ក្រុមការងារនាយកដ្ឋាន បច្ចេកទេស របស់អង្គការ ILO ដឹកនាំដោយលោក Paolo Carlini អ្នកប្រឹក្សាយោបល់ ឯករាជ្យអន្តរជាតិ បានចុះមកវាយតម្លៃ លើយុទ្ធសាស្ត្រ និងផែនការសកម្មភាព ក្នុងការប្រែក្លាយអ្នកដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ច ក្រៅប្រព័ន្ធចូលទៅក្នុង សេដ្ឋកិច្ចក្នុងប្រព័ន្ធ ដែលរាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តចាប់ពីឆ្នាំ២០១៤-២០១៨។ ការចុះមកវាយតម្លៃផែនការ សកម្មភាពខាងលើ ត្រូវបានធ្វើឡើងនៅទីស្តីការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមការទទួលស្វាគមន៍ពីសំណាក់លោក ម៉ម វណ្ណៈ រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៩។

លោក ម៉ម វណ្ណៈ បានឲ្យដឹងថា រាជរដ្ឋាភិបាលកម្ពុជាបានបង្កើត ការងារជូនប្រជាពលរដ្ឋយ៉ាងច្រើន ធ្វើឲ្យអត្រាមានការងារ ធ្វើស្មើនឹង៩៩.៣% នៃកម្លាំងពលកម្ម សរុបមានប្រមាណ១០លាននាក់ ក្នុងនោះកម្មករនិយោជិតសេដ្ឋកិច្ច ក្នុងប្រព័ន្ធជិត១.៥លាននាក់ កម្មករនិយោជិតសេដ្ឋកិច្ចក្រៅប្រព័ន្ធ ២.៤លាននាក់ វិស័យកសិកម្មជាង៤លាននាក់ ពលករធ្វើការក្រៅប្រទេស១.២លាននាក់ និងមន្ត្រីសាធារណៈប្រមាណ ៥០ម៉ឺននាក់។ លោកបន្តថា គោលនយោបាយជាតិស្តីពីមុខរបរនិងការងារ(NEP ២០១៥-២០២៥)គោលដៅលើកកម្ពស់ការងារសមរម្យ និងមានផលិតភាពការងារខ្ពស់ តាមរយៈការបង្កលក្ខណៈឲ្យមានការប្រែក្លាយ កម្មករនិយោជិត និងអង្គភាពពីសេដ្ឋកិច្ចក្រៅប្រព័ន្ធទៅក្នុងសេដ្ឋកិច្ចផ្លូវការ ដោយធានាបាននូវការកែលម្អ និងរក្សាបាននូវជីវភាពរស់នៅក្នុងអំឡុងពេល នៃដំណើរការប្រែក្លាយនេះ ៕

## ពលករម្នាក់ជួបគ្រោះអកុសលលើដីថៃ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៩ ម៉ោង ១៣:៥៣ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ ពេលឡើងផ្សារដែកស្រាប់តែបាក់រន្ទាធ្លាក់ពលករម្នាក់បណ្តាលឱ្យរងរបួសធ្ងន់ ក្រោយមកក៏បានស្លាប់ក្នុងមន្ទីរពេទ្យក្រុងបាងកក ប្រទេសថៃ ។ ជនរងគ្រោះដែលស្លាប់ឈ្មោះម៉ន ម៉េត ភេទប្រុស អាយុ៤២ឆ្នាំ ជាពលករផ្នែកផ្សារដែកធ្វើការនៅក្រុងបាងកក ប្រទេសថៃ និងមានស្រុកកំណើតក្នុងភូមិត្រពាំងតាម៉ូក ឃុំពានរោង ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។ តាមប្រភពពីក្រុមគ្រួសារសាច់ញាតិរបស់ជនរងគ្រោះបានប្រាប់ឱ្យដឹងថា គ្រោះថ្នាក់ខាងលើបានកើតឡើងកាលពីម៉ោងជាង៣រសៀលថ្ងៃទី១៦ មិថុនា ឆ្នាំ២០១៩ ខណៈពេលដែលជនរងគ្រោះកំពុងឡើងផ្សារដែកកំពស់ប្រហែល៧ទៅ៨ម៉ែត្រនៅក្នុងការដ្ឋានសំណង់មួយ ស្រាប់តែបាក់រន្ទាធ្លាក់មកដី បណ្តាលឲ្យជនរងគ្រោះរងរបួសធ្ងន់ ហើយក្រោយមកក៏បានស្លាប់នៅយប់ថ្ងៃដដែលក្នុងមន្ទីរពេទ្យក្រុងបាងកក។ សពជនរងគ្រោះត្រូវ

បានភាគីថៃបញ្ជូនមកវិញតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតកាលពីយប់ថ្ងៃទី១៨ មិថុនា ហើយត្រូវសាច់ញាតិជួលរថយន្តដើម្បីដឹកបន្តទៅលំនៅដ្ឋានធ្វើបុណ្យតាមប្រពៃណី៕ (កែសម្រួលដោយ ៖ ធីតា)

**លិចទូកនេសាទត្រីថៃ បណ្តាលអោយមានពលករខ្មែរ 02នាក់ស្លាប់ និងជនជាតិថៃ ស្លាប់ 01**

https://www.facebook.com/PrakPheakTraOfficial/ បណ្តាញទេសន្តប្រវេសន៍ក្នុងប្រទេសថៃ 19-06-2019

ករណីទូកនេសាទត្រីថៃ ឈ្មោះ ឆៃវ៉ារី លិចក្នុងតំបន់សលាត ស្ថិតក្នុងស្រុកកោះគូត ខេត្តត្រាត ប្រទេសថៃ កាលពីកាលពីថ្ងៃទី18ខែមិថុនាឆ្នាំ2019 កន្លងទៅនេះបណ្តាលអោយមានពលករខ្មែរ 02នាក់ស្លាប់ និងជនជាតិថៃស្លាប់ 01នាក់ ក្នុងហេតុការណ៍នេះដែរកម្លាំងយោធាជើងទឹកថៃបាន ជួយសង្គ្រោះពលករបានចំនួន 12នាក់ ដោយសុវត្ថិភាព។

## ថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០១៩

## ពលករខ្មែរធ្វើការលើទូកនេសាទថៃ ២នាក់លិចទូកស្លាប់ និង ១០នាក់ត្រូវបានសង្គ្រោះ

https://www.rfa.org/khmer/news/ ដោយ ទីន ហ្សាការីយ៉ា 2019-06-20

សមត្ថកិច្ចថៃបានបញ្ជូនសាកសពពលករខ្មែរ ២នាក់ទៅធ្វើកោសល្យវិច័យនៅមន្ទីរពេទ្យ បន្ទាប់ពីលិចទូកស្លាប់នៅខេត្តត្រាត (Trat) ប្រទេសថៃ កាលពីរសៀលថ្ងៃទី១៨ មិថុនា។ អ្នកបកប្រែប្រចាំនៅអង្គការលើកកម្ពស់គុណភាពពលករ (IPN) ប្រចាំនៅខេត្តសមុទ្រសាខន (Samut Sakon) ប្រទេសថៃ លោក ប្រាក់ ភត្រា ប្រាប់អាស៊ីសេរីនៅរសៀលថ្ងៃទី២០ មិថុនាថា ជនរងគ្រោះជាបុរសទាំងអស់ រួមមានឈ្មោះ ណេង នី អាយុ ២២ឆ្នាំ និងឈ្មោះ កៅ ប៊ុនថៃ អាយុ ២៤ឆ្នាំ បានលិចទូកស្លាប់នៅក្នុងទឹកសមុទ្រនៅស្រុកកោះកូត ខេត្តត្រាត (Trat)។ លោកបន្តថា នៅលើកទូកនេសាទនោះ មានកម្មករចំនួន ១៥នាក់ គឺពលករខ្មែរចំនួន១២ និងថៃ ៣នាក់ ក្នុងនោះខ្មែរ ២នាក់ និងថៃម្នាក់បានស្លាប់នៅក្នុងទឹកសមុទ្រ។ លោកបន្ថែមថា នៅថ្ងៃទី១៩ មិថុនា កងទ័ពជើងទឹករបស់ថៃបានរកឃើញសាកសពអ្នកទាំង២ និងបានជួយសង្គ្រោះមនុស្សចំនួន ១២នាក់រួចពីគ្រោះថ្នាក់៖ «បាទទាំងអស់ ១៥នាក់ ដោយខាងទាហានជើងទឹកថៃគេជួយអន្តរាគមន៍បាន១២នាក់ ទូកភាគច្រើនដែលគ្រោះថ្នាក់ដោយសារបើកបរនៅពេលយប់ ដូចជាវាទៅបុកថ្ម និងទៅជលគ្នាជាមួយទូកគេផ្សេងទៀត ព្រោះអីករណីកន្លងមក វាមានកប៉ាល់ផ្សេងបុកលិចច្រើនលិចជាច្រើនដងមកហើយ ដោយឡែកករណីនេះ វាអត់មានអីទេ ប្រហែលជាគ្រោះថ្នាក់ដោយចៃដន្យ»។ លោកបន្តថា សមត្ថកិច្ចនៅមិនទាន់ដឹងមូលហេតុពីការលិចទូកនេះនៅឡើយទេតែសន្និដ្ឋានថា អាចបណ្តាលមកពីបើកបុកថ្មក្រឡាប់។ លោកបន្តថា សមត្ថកិច្ចថៃបានបញ្ជូនសាកសពពលករខ្មែរទៅធ្វើកោសល្យវិច័យនៅមន្ទីរពេទ្យក្នុងស្រុកក្លងយ៉ៃ (Klorng Yai) ខេត្តត្រាតរបស់ថៃ ហើយមកទល់ព្រឹកថ្ងៃទី២០មិថុនា ខាងថៃមិនទាន់ប្រគល់សាកសពទៅឱ្យសាច់ញាតិនៅកម្ពុជាយកទៅធ្វើបុណ្យនៅឡើយទេ៕

## នេះហើយជីវិត! រៀបការជាមួយប្តីចិន ក្នុងក្តីសង្ឃឹមជួយយិតយោងគ្រួសារ តែមិននឹកស្មានក្លាយជាទេសករផ្លូវភេទ ដំបូងជាមួយបុរស៣នាក់ក្នុងផ្ទះតែ១ និងចុងក្រោយ យកទៅលក់ជាស្រីសោភិនី

https://ksn.news/world/ June 19, 2019

នេះជារឿងរ៉ាវដ៏កម្សត់ និងបទពិសោធន៍ជីវិតដ៏ឈឺចាប់បំផុត របស់ស្ត្រីវ័យក្មេងម្នាក់ ស្ថិតនៅក្នុងត្រកូលក្រីក្រ ដែលបានរៀបការជាមួយបុរសជនជាតិចិន ក្នុងក្តីសង្ឃឹមថានឹងបានជួយយិតយោងគ្រួសារថ្កុំថ្កើន តែទីបំផុត នាងត្រូវជួបព្យុះកាមទេពជាមួយបុរសដទៃ បង្ខំឲ្យធ្វើជា «ស្រីសោភិនី» រហូតទ្រាំទ្រលែងបានរត់គេចខ្លួន ។

AP បានរាយការណ៍ថា Natasha Masih អាយុ ១៩ ឆ្នាំ រស់នៅជាខេត្តដាច់ស្រយាលមួយ ដែលភាគច្រើនជាអ្នកកាន់សាសនាគ្រីស្ត ក្នុងប្រទេសប៉ាគីស្ថាន ហើយក៏ជាខេត្តមួយសុទ្ធតែជាអ្នកក្រីក្របំផុត ហេតុដូច្នេះហើយ ទើបផ្តេកផ្តួលរៀបការជាមួយបុរសជនជាតិចិនយ៉ាងងាយ ដើម្បីបានប្រាក់ផ្គត់ផ្គង់គ្រួសារ ប៉ុន្តែ ទោះជាមិនមានចិត្តចង់រៀបការ ក៏គ្មានផ្លូវជ្រើសរើសដែរ ព្រោះ Natasha នៅមានប្អូនស្រី ៤ នាក់ និងឪពុកមានជំងឺឈឺខ្នង ដូច្នេះហើយទើបឪពុកនិងសាច់ញាតិណែនាំឲ្យរៀបការជាមួយបុរសចិន រួចទៅរស់នៅស្រុកឆ្ងាយ ភាគខាងជើងប្រទេសចិន ។

នាងរៀបថាៈ ផ្ទះរបស់ប្តីជនជាតិចិននោះ គឺមានទំហំតូច គ្មានបន្ទប់បាយ និងបន្ទប់ងូតទឹកទេ ហើយនៅក្នុងគ្រួសារប្តី មានបុរស ៣ នាក់ និងនារី ២ នាក់ទៀត ជាមិត្តភក្តិប្តីនៅជាមួយគ្នា ។ ប៉ុន្តែ នាងពិតជារន្ធត់ចិត្ត និងខ្លាចខ្លាំងណាស់ បន្ទាប់រស់នៅទីនោះមិនបានប៉ុន្មានផង នាងក៏ត្រូវគេបង្ខំឲ្យរួមភេទជាមួយបុរសទាំង ៣ នាក់ ដែលរស់នៅក្នុងផ្ទះនោះជាមួយគ្នា ។ បន្ទាប់ពីពីនោះ ប្តីទុយ៌សបាននាំនាងទៅលក់ធ្វើជា «ស្រីខូច» នៅសណ្ឋាគារមួយក្នុងស្រុកអ៊ូរុមហ្ស៊ី តំបន់ស្វយ័តស៊ិនជៀង អ៊ុយហ្គ័រ ។ ទោះយ៉ាងណា នៅទីបំផុត Natasha មានភ័ព្វសំណាងល្អ ដោយបានមនុស្សមួយក្រុម ដែលជាសមាជិកគ្រិស្តសាសនិក មកជួយរំដោះនាងចេញពីប្តីតិរិច្ឆាននោះ ។ នាងនិយាយថា ប្តីរបស់នាងបានប្រាប់នាងថាៈ «ខ្ញុំទិញអ្នកនៅក្នុងប្រទេសប៉ាគីស្ថាន ។ ដូច្នេះ អ្នកគឺជាកម្មសិទ្ធិរបស់ខ្ញុំ ។ អ្នកគឺជាទ្រព្យសម្បត្តិរបស់ខ្ញុំ» ។

ទោះបីជាអាជ្ញាធរបានស៊ើបអង្កេតបំបែកក្រុមជួញដូរមនុស្ស និងចាប់ខ្លួនអ្នករួមគំនិតចិន និងប៉ាគីស្ថានរាប់សិបនាក់យ៉ាងណាក៏ដោយ ក៏ការបោសសម្អាតគឺមានការពិបាកដែរ ដោយសារមានបណ្តាញនៅទីក្រុង Lahore តំបន់ Punjab ត្រូវបានចាក់ឫសយ៉ាងជ្រៅអស់រយៈពេលជាច្រើនឆ្នាំមកហើយ ស្ថិតក្រោមពួកមន្ត្រីប៉ូលីសពុករលួយ ជំរុញឲ្យមានកការទិញ-លក់កូនក្រមុំធ្វើជាទាសករផ្លូវភេទ រហូតមកដល់ថ្ងៃនេះ ៕

## ឆ្នាំ២០១៩៖ អាមេរិកបញ្ចុះចំណាត់ថ្នាក់កម្ពុជារឿងទប់ស្កាត់ការជួញដូរមនុស្ស

http://km.rfi.fr/cambodia/ ដោយ វណ្ណ សុគន្ធា21/06/2019 21/06/2019

*ក្រសួងការបរទេសអាមេរិក នៅថ្ងៃទី២០ មិថុនា បានចេញរបាយការណ៍មួយស្តីពី ការជួញដូរមនុស្សនៅលើពិភពលោក ប្រចាំឆ្នាំ២០១៩ ដែលក្នុងនោះ ក៏មានប្រទេសកម្ពុជាផងដែរ។ តាមរយៈរបាយការណ៍នេះ អាមេរិកបានអះអាងថា វិធានការរបស់អាជ្ញាធរកម្ពុជាចំពោះការបង្ក្រាប និងទប់ស្កាត់អំពើជួញដូរមនុស្ស នៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ដូច្នេះហើយ អាមេរិកបានបញ្ចុះចំណាក់ថ្នាក់កម្ពុជាមួយចំណាត់ថ្នាក់ទៀតនៅក្នុងឆ្នាំ២០១៩នេះ។*

នៅឆ្នាំ២០១៩នេះ ក្រសួងការបរទេសអាមេរិកបានបញ្ចុះចំណាត់ថ្នាក់កម្ពុជាលើការទប់ស្កាត់ការជួញដូរមនុស្សពីកម្រិតលេខ២ (Tier2) មកកម្រិតលេខ២ដូចគ្នា តែស្ថិតក្នុងបញ្ជីតាមដានឃ្លាំមើល (Tier 2 Watch list)។ ការបន្ថយចំណាត់ថ្នាក់នេះ គឺក្រសួងបរបរទេសអាមេរិកមើលឃើញថា រដ្ឋាភិបាលកម្ពុជាមិនបានអនុវត្តបានពេញលេញទៅតាមស្តង់ដារនៃការលុបបំបាត់អំពើជួញដូរមនុស្សឱ្យស្ថិតក្នុងកម្រិតទាបបំផុត។ បើតាមក្រសួងការបរទេសអាមេរិក អាជ្ញាធរកម្ពុជាមិនបង្ហាញឱ្យឃើញពីកើនឡើងនៃកិច្ចប្រឹងប្រែងរបស់ខ្លួនក្នុងការលុបបំបាត់អំពើជួញដូរមនុស្ស។ ក្រសួងការបរទេសអាមេរិក បានគូសបញ្ជាក់ថា អាជ្ញាធរកម្ពុជាមិនបានប្រមូល និង ចែករំលែកព័ត៌មានសំខាន់ៗនៃការអនុវត្តច្បាប់លើបញ្ហានេះបានគ្រប់គ្រាន់។ ចំណែក បញ្ហាពុករលួយនៅតែបន្តរាំងដល់ការអនុវត្តច្បាប់ នីតិវិធីប្រឆាំងនឹងបទឧក្រិដ្ឋ ជាពិសេសការផ្តល់សេវាដល់ជនរងគ្រោះ។ បើទោះបីចំណាត់ថ្នាក់កម្ពុជាលើការទប់ស្កាត់អំពើជួញដូរមនុស្សនេះមិនសូវល្អក៏ពិតមែន តែក៏មិនទាន់ថ្នាក់អាក្រក់ខ្លាំងនោះដែរ។ ក្រសួងការបរទេសអាមេរិក បានបញ្ជាក់ថា រដ្ឋាភិបាលកម្ពុជាបានបង្ហាញពីខិតខំរបស់ខ្លួនក្នុងទប់ស្កាត់ការជួញដូរមនុស្សនេះ មានជាអាទិ៍ ការបន្តបញ្ជូនអ្នកជួញដូរ

មនុស្សទៅកាន់តុលាការ និង បានកាត់ទោសតាមច្បាប់ បង្កើនការបណ្តុះបណ្តាលលើអនុវត្តច្បាប់ ព្រមទាំងចាត់វិធានការលើកស្ទួយការយល់ដឹង និងជំរុញឱ្យមានការធ្វើចំណាកស្រុកដោយសុវត្ថិភាព។

គួរជម្រាបជូនថា នៅក្នុងការវាយតម្លៃអំពីការទប់ស្កាត់ការជួញដូរមនុស្ស ក្រសួងការបរទេសអាមេរិក បានចែកចេញជា៤ចំណាត់ថ្នាក់។ ចំណាត់ថ្នាក់លេខ១ (Tier 1) សម្រាប់ប្រទេសណាដែលបានអនុវត្តបានពេញលេញទៅតាមស្តង់ដារនៃច្បាប់ការពារជនរងគ្រោះពីការជួញដូររបស់អាមេរិក។ ចំណាត់លេខ២ (Tier 2) គឺសម្រាប់ដាក់ឱ្យប្រទេសណាដែលអនុវត្តមិនទាន់បានពេញលេញទៅតាមស្តង់ដារ ប៉ុន្តែកំពុងបង្ហាញការខិតខំខិតទៅរកស្តង់ដារ។ ចំណាត់ថ្នាក់លេខ២តែស្ថិតក្នុងបញ្ជីតាមដានឃ្លាំមើល (Tier 2 Watch List) គឺស្រដៀងគ្នានឹងចំណាត់ថ្នាក់លេខ២ដែរ តែគ្រាន់តែបន្ថែមនូវការតាមដានត្រួតពិនិត្យពីការប្តេជ្ញាចិត្តធ្វើឱ្យបានតាមស្តង់ដារនៅឆ្នាំបន្ទាប់។ ដោយឡែក ចំណាត់ថ្នាក់លេខ៣ (Tier3) គឺសម្រាប់ប្រទេសណាដែលអនុវត្តមិនបានពេញលេញទៅតាមស្តង់ដារនៃច្បាប់ការពារជនរងគ្រោះពីការជួញដូរ ហើយគ្មានការបង្ហាញពីការខិតខំអនុវត្ត៕

## ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០១៩

## កម្ពុជាច្រានចោលការចាត់ចំណាត់ថ្នាក់របស់អាមេរិក រឿងជួញដូរមនុស្ស

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 24 June 2019 | 08:15 ICT

**ភ្នំពេញៈ** មន្ត្រីជាន់ខ្ពស់កម្ពុជា បានបញ្ចេញប្រតិកម្ម ទៅនឹងរបាយការណ៍របស់សហរដ្ឋអាមេរិកដែលបន្តដាក់ចំណាត់ថ្នាក់កម្ពុជា ក្នុងស្ថានភាពអាក្រក់នៃការមិនលុបបំបាត់អំពើជួញដូរមនុស្សដោយមិនបានបំពេញ និងមិនបានតាំងចិត្តខ្ពស់ក្នុងការលុបបំបាត់ជាអ្វីដែលក្រុមមន្ត្រីកម្ពុជាបានច្រានចោលដោយថា កម្ពុជាមានការខិតខំប្រឹងប្រែង និងមានការប្តេជ្ញាខ្ពស់ណាស់ ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។

លោក យឹម វិរៈ អ្នកនាំពាក្យគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ថ្លែងថា រហូតមកដល់ថ្ងៃអាទិត្យម្សិលមិញ កម្ពុជា មិនទាន់ទទួលបានរបាយការណ៍របស់អាមេរិក ដែលលើកឡើងពីបញ្ហាការជួញដូរមនុស្សនៅកម្ពុជាជាផ្លូវការនោះទេ បន្ទាប់ពីសហរដ្ឋអាមេរិក បានចេញផ្សាយរបាយការណ៍នេះ កាលពីថ្ងៃសុក្រ។ ទោះយ៉ាងណា លោក វិរៈ មិនបានច្រានចោលទាំងស្រុង ចំពោះរបាយការណ៍នេះទេ ដោយលោកគ្រាន់តែថ្លែងថា វាហាក់មានភាពលម្អៀង ចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលបានខិតខំប្រឹងប្រែងបំពេញការងាររបស់ខ្លួនក្នុងការទប់ស្កាត់ ការជួញដូរមនុស្ស ប៉ុន្តែបែរជាត្រូវបានចាត់ចំណាត់ថ្នាក់អាក្រក់បែបនេះទៅវិញ។ លោកបញ្ជាក់ថា៖ «ការវាយតម្លៃរបស់សហរដ្ឋអាមេរិកជារៀងរាល់ឆ្នាំ គឺផ្អែកលើគោលការណ៍បទដ្ឋានអប្បបរមានៃការវាយតម្លៃរបស់គេ។ ប៉ុន្តែជាសិទ្ធិសេរីភាពក្នុងការពិនិត្យឃើញជ្រុងណាមួយដូចដែលរដ្ឋាភិបាល របស់យើងមិនទាន់មានការខិតខំប្រឹងប្រែងនោះ យើងមិនទាន់ដឹងមានការជាក់លាក់នៅឡើយទេ»។ លោកបន្តថា៖ «ការខិតខំប្រឹងប្រែងរបស់យើងមានការប្តេជ្ញាខ្ពស់ណាស់ ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សដោយសារតែអំពើជួញដូរ គឺជាការរំលោភសិទ្ធិដ៏ធ្ងន់ធ្ងររបស់បុគ្គលដែលយើងត្រូវតែការពារដាច់ខាត។ អ្វីដែលជាការព្រួយបារម្ភ គឺការវាយតម្លៃនេះ គឺចូលជាង ១០ ឆ្នាំហើយ ដែលកម្ពុជាធ្លាប់ទទួលបាន TIER 2 watch list ហ្នឹង ក្នុងរយៈពេល ២ ឆ្នាំ ជាប់គ្នាក៏មានដែរ ហើយក្រោយមកយើងខិតខំប្រឹងប្រែង គេដាក់មក TIER 2 វិញដែលទើបតែឆ្នាំនេះយើងវិលមក TIER 2 watch list វិញ។ ការខិតខំរបស់យើងបានច្រើនណាស់គាត់មិនបានមើលឃើញទេ ទៅជារឿងរ៉ាវដែលគាត់គិតថាយើងមិនបានធ្វើ ហើយរបាយការណ៍វាទៅបញ្ច្រាស់គ្នានឹងការខិតខំរបស់យើងទៅវិញ»។

កាលពីថ្ងៃសុក្រ អាមេរិកបានចេញផ្សាយរបាយការណ៍មួយ ស្តីពីការជួញដូរមនុស្សក្នុងពិភពលោក ក្នុងនោះក៏មានប្រទេសកម្ពុជា និងប្រទេសនៅតំបន់អាស៊ានចំនួន ៤ ផ្សេងទៀតមាន ប្រ៊ុយណេ ឡាវ ម៉ាឡេស៊ី និងវៀតណាម ស្ថិតនៅចំណាត់ថ្នាក់ប្រទេសដែលមិនបានបំពេញបទដ្ឋានគ្រប់គ្រាន់ ក្នុងការលុបបំបាត់ការជួញដូរមនុស្ស។ របាយ

ការណ៍នោះបង្ហាញថា ចំណាត់ថ្នាក់កម្ពុជានៅឆ្នាំនេះ បានបន្តធ្លាក់ចុះមួយកម្រិតទៀតពេលគឺកាលពីឆ្នាំ ២០១៨ មានចំណាត់ថ្នាក់លេខ ២ ហើយធ្លាក់មកនៅចំណាត់ ថ្នាក់ លេខ ២ កន្លះដែលកៀកនឹងចំណាត់ថ្នាក់លេខ ៣ ដែលត្រូវបានគេចាត់ទុកជាប្រទេសមានស្ថានភាពអាក្រក់បំផុតក្នុងអំពើជួញដូរមនុស្ស។ តាមរបាយការណ៍របស់អាមេរិកបានលើកឡើងថា ដើមចមដែលកម្ពុជាធ្លាក់ក្នុងចំណាត់ថ្នាក់នេះក៏ព្រោះតែអាជ្ញាធរកម្ពុជា មិនបានបង្កើនសកម្មភាពរបស់ខ្លួន ឲ្យខ្លាំងក្លាជាងមុននោះទេ ក្នុងការលុបបំបាត់អំពើជួញដូរមនុស្ស ខណៈដែលបញ្ហាអំពើពុករលួយ និងការស៊ើបអង្កេតពីការជួញដូរមនុស្សគ្មានតម្លាភាព។ បន្ថែមពីនេះ រដ្ឋាភិបាលកម្ពុជាក៏បានប្រើប្រាស់ច្បាប់ទាំងបំពានប្រឆាំងទៅនឹងគណបក្សប្រឆាំង និងអ្នកមួយចំនួន ដែលហ៊ានបង្ហាញរូបភាពផ្សេងៗជុំវិញស្ថានភាពនៃការជួញដូរមនុស្សនៅក្នុងប្រទេសផងដែរ។ របាយការណ៍ថា៖ «រដ្ឋាភិបាលកម្ពុជា មិនអាចបំពេញតាមបទដ្ឋានអប្បបរមាសម្រាប់ឈានដល់ការលុបបំបាត់ការជួញដូរមនុស្សនោះទេរដ្ឋាភិបាលកម្ពុជា មិនបានបង្ហាញការកើនឡើង នៃការខិតខំប្រឹងប្រែង បើប្រៀបធៀបនឹងរយៈពេលការធ្វើរបាយការណ៍មុន។ អាជ្ញាធរមិនបានប្រមូលឬចែករំលែកព័ត៌មានសំខាន់ៗអំពីកិច្ចប្រឹងប្រែងអនុវត្តច្បាប់ឲ្យបានគ្រប់គ្រាន់នៅឡើយទេ ហើយអំពើពុករលួយនៅតែបន្តរាំងប្រតិបត្តិការអនុវត្តច្បាប់ដំណើរការនីតិវិធីព្រហ្មទណ្ឌ និងការផ្តល់សេវាជូនជនរងគ្រោះ»។ របាយការណ៍ដដែល ក៏បានលើកឡើងផងដែរថា រាជរដ្ឋាភិបាលមិនបានស៊ើបអង្កេតពីភាពជឿជាក់បាននៃបទល្មើសទាក់ទងនឹងការឈ្មួញជួញដូរធំៗ ដែលបណ្តាលឲ្យបុរស ស្ត្រី និងកុមាររាប់ពាន់នាក់នៅទូទាំងប្រទេស ក្លាយជាជនរងគ្រោះ នៃការជួញដូរតាមរយៈបំណុល ជាពិសេសក្នុងវិស័យឡឥដ្ឋ។

ប៉ុន្តែលោក ផៃ ស៊ីផាន អ្នកនាំពាក្យរដ្ឋាភិបាលបានថ្លែងកាលពីម្សិលមិញថា កម្ពុជាមិនខ្វល់នឹងការដាក់ចំណាត់ថ្នាក់ក្នុងកម្រិតណារបស់អាមេរិកពេលនេះនោះទេ ព្រោះកន្លងមក កម្ពុជាបានចូលរួមសកម្មភាពជាច្រើន ដូចជាការរៀបចំច្បាប់ និងយន្តការគ្រប់ជាន់ថ្នាក់ ដើម្បីឆ្លើយតប និងប្រយុទ្ធប្រឆាំង នឹងអំពើជួញដូរមនុស្ស។ ជាមួយគ្នានេះ លោក ស៊ីផាន ក៏អះអាងដែរថា កម្ពុជាធ្វើសកម្មភាពទាំងនេះ ក៏មិនមែនឆ្លើយតប ឬដើម្បីទទួលបានការសរសើរពីសហរដ្ឋអាមេរិកនោះដែរព្រោះសកម្មភាពរបស់កម្ពុជា គឺធ្វើឡើងដើម្បីឆ្លើយតបនឹងអំពើអមនុស្សធម៌ទាំងនេះដែលក្នុងនាមជារដ្ឋាភិបាលកម្ពុជា ត្រូវតែចាត់វិធានការ។ លោកបញ្ជាក់ថា៖ «អាហ្នឹងគឺជាការវាយតម្លៃរបស់គេប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាមិនសូវជាយកចិត្តទុកដាក់ចំពោះការវាយតម្លៃ ចំណាត់ថ្នាក់យ៉ាងម៉េចយ៉ាងម៉ារបស់អាមេរិកនោះទេ យើងមិនបានធ្វើការងារនេះដើម្បីបំពេញចិត្តសហរដ្ឋអាមេរិកនោះទេ។ ក៏ប៉ុន្តែជាក្រមសីលធម៌ និងវប្បធម៌របស់កម្ពុជា គឺយើងបានប្តេជ្ញាប្រឆាំងនឹងអំពើជួញដូរនេះ»។

លោកស្រី មាស សាអ៊ីម អនុប្រធានផ្នែកស្ត្រី និងកុមារនៃសមាគមអាដហុក ដែលធ្វើការពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងចំណាកស្រុក បានថ្លែងថា រដ្ឋាភិបាល បានខិតខំទប់ស្កាត់បញ្ហានេះហើយ ប៉ុន្តែគ្រាន់តែអ្វីដែលពួកគាត់បានធ្វើគឺហាក់មិនចំគោលដៅ និងមិនបានឆ្លើយតបទៅនឹងទិដ្ឋភាពជាក់ស្តែងក្នុងសង្គមកម្ពុជាតែប៉ុណ្ណោះ។ លោកស្រីបញ្ជាក់ថា៖ «បើគាត់មានឆន្ទៈក្នុងការដោះស្រាយ ហេតុអ្វីមេខ្យល់ធំ (ជួញដូរមនុស្ស) មិនត្រូវបានចាប់ខ្លួន បែរជាចាប់បានតែមេខ្យល់តូចៗ ដែលពេលខ្លះជាជនរងគ្រោះផង។ ខ្ញុំអាចនិយាយថា មន្ត្រីរដ្ឋាភិបាលមួយចំនួនធំ គាត់មានការប្រឹងប្រែងប៉ុន្តែការប្រឹងប្រែងមួយចំនួននោះមិនចំគោលដៅ និងឆ្លើយតបទៅនឹងការស្វែងរកយុត្តិធម៌របស់ជនរងគ្រោះនឹងការជួញដូរនោះទេ»។

របាយការណ៍របស់អាមេរិក ក៏បានផ្តល់អនុសាសន៍មួយចំនួន ដោយជំរុញឲ្យកម្ពុជា អនុវត្តឲ្យបានដោយការបង្កើតភ្នាក់ងារស៊ើបអង្កេតសម្ងាត់ និងមន្ត្រីតាមមើលដំណើរការតុលាការ កំណត់មុខសញ្ញាជនងាយរងគ្រោះ ដោយការកែសម្រួលច្បាប់ដើម្បីឲ្យមានការសងជំងឺចិត្តដល់ជនរងគ្រោះ បង្កើនការយល់ដឹងជាសាធារណៈពីការធ្វើចំណាកស្រុក និងពង្រឹងការត្រួតពិនិត្យលើភ្នាក់ងារជ្រើសរើសពលករ។ ជាពិសេសនោះរដ្ឋាភិបាល ត្រូវបង្កើនការស្តារនីតិសម្បទាដល់ជនរងគ្រោះ និងត្រួតពិនិត្យលើស្ថាប័នផ្តល់ប្រាក់កម្ចីឯកជន ដើម្បីកាត់បន្ថយភាពងាយរងគ្រោះនៃបំណុល

ដែលជាដើមហេតុក្នុងការលើកទឹកចិត្តដល់ជនរងគ្រោះឲ្យធ្វើចំណាកស្រុក ទាំងនៅក្នុង និងទៅក្រៅប្រទេស ដែលអនុសាសន៍ទាំងនេះត្រូវបាន លោក យឹម វិរៈ អះអាងថា កម្ពុជានឹងពិនិត្យមើលឡើងវិញ៕

## នគរបាលការពារព្រំដែនកម្ពុជា-ថៃ ពង្រឹងកិច្ចសហប្រតិបត្តិការចូលរួមទប់ស្កាត់បទល្មើសឆ្លងដែនខុសច្បាប់

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 24/06/2019

ខេត្តបន្ទាយមានជ័យ ៖ កម្លាំងនគរបាលប៉ុស្តិ៍ស្ទាយព្រៃនៃវរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៥ និងកម្លាំងទាហានឈុតខ្មៅនៃកងអនុសេនាធំ១២.០៤ ជួរមុខកម្ពុជា-ថៃ ឈរជើងក្នុងភូមិសាស្ត្រឃុំតាគង់ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ឈមនិងឃុំផាន់សឹក ស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ បានជួបប្រជុំក្នុងទឹកដីថៃ នៅព្រឹកថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៩ ដើម្បីពង្រឹងការទំនាក់ កិច្ចសហប្រតិបត្តិការបង្ការទប់ស្កាត់និងបង្ក្រាបបទល្មើសឆ្លងដែនខុសច្បាប់។ គ្រាដែលមានសេចក្តីរាយការណ៍ឱ្យដឹងថា កន្លងមកបទល្មើសឆ្លងដែនខុសច្បាប់មួយចំនួនបានកើតឡើងជាបន្តបន្ទាប់ទាមទារឱ្យកម្លាំង ជួរមុខរវាងកម្ពុជា-ថៃ ត្រូវតែរួមគ្នាមានវិធានការទប់ស្កាត់បទល្មើសទាំងនោះ។ កងកម្លាំងជួរមុខកម្ពុជា-ថៃដោយភាគីទាំង២បានប្រជុំពិភាក្សាផ្តោតសំខាន់លើកិច្ចសហប្រតិបត្តិការទប់ស្កាត់បទល្មើសឆ្លងដែនរួមមានៈ បទល្មើសជួញដូរគ្រឿងញៀនឆ្លងដែនខុសច្បាប់ បទល្មើសនាំពលករឆ្លងដែនខុសច្បាប់ បទល្មើសនាំទំនិញគ្រប់ប្រភេទគេចពន្ធខុសច្បាប់ បទល្មើសចោរកម្មឆ្លងដែនខុសច្បាប់ និងបទល្មើសឆ្លងដែនមួយចំនួនទៀតផងដែរ។

កិច្ចប្រជុំនោះកងកម្លាំងជួរមុខកម្ពុជា-ថៃធ្វើឡើងនៅចំណុចប៉ុស្តិ៍ព្រំដែន(អ១៣) ភូមិផាន់សឹក ឃុំផាន់សឹក ស្រុកអារញ្ញ ខេត្តស្រះកែវ ដោយភាគីកម្ពុជាដឹកនាំដោយនាយប៉ុស្តិ៍ព្រំដែនស្ទាយព្រៃលោកវរសេនីយ៍ត្រី អឿម ប៊ុនធឿន នៃវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៥ ចំណែកភាគីថៃដឹកនាំដោយមេបញ្ជាការរងកងអនុសេនាធំ ១២.០៤ លោកអនុសេនីយ៍ត្រី សង្រ្កាន ធូខាំនី។ នាយប៉ុស្តិ៍ព្រំដែនស្ទាយព្រៃលោកវរសេនីយ៍ត្រី អឿម ប៊ុនធឿន នៃវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ បានប្រាប់ឱ្យដឹងថា កិច្ចប្រជុំរវាងកងកម្លាំងជួរមុខកម្ពុជា-ថៃ ក៏បានលើកឡើងផ្តល់ព័ត៌មានគ្នាទៅវិញទៅមកជុំវិញនៃកិច្ចសហប្រតិបត្តិការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសឆ្លងដែនខុសច្បាប់ និងកើតមានបញ្ហាមិនប្រក្រតីតាមបន្ទាត់ព្រំដែនភាគីទាំង២ក៏ត្រូវជូនដំណឹងគ្នាទៅវិញទៅមកផងដែរ ដើម្បីរួមគ្នាដោះស្រាយតាមនីតិវិធី អនុវត្តលើស្មារតីយោគយល់គ្នាដោយ បញ្ចៀសបញ្ហាប្រឈមតានតឹងដាក់គ្នាដោយអាវុធ ប្រែក្លាយតំបន់ព្រំដែនជាព្រំដែនសន្តិភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍។ នាយប៉ុស្តិ៍ព្រំដែនស្ទាយព្រៃលោកវរសេនីយ៍ត្រី អឿម ប៊ុនធឿន នៃវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ ប្រាប់ឱ្យដឹងទៀតថា ក្នុងកិច្ចប្រជុំនោះផងដែរ លោក ក៏បានសំណូមពរទៅភាគីថៃក្នុងករណីពលករខ្មែរលួចឆ្លងដែនខុសច្បាប់ដោយប្រការណាមួយសូមឱ្យភាគីថៃយោគយល់ដល់ពលករខ្មែរដោយចាប់អនុវត្តតាមច្បាប់អន្តោប្រវេសន៍ប្រទេសថៃ ចៀសវាងការប្រើអំពើហិង្សា រឺបាញ់សម្លាប់ជាដើម។ លោកនាយប៉ុស្តិ៍ព្រំដែនស្ទាយព្រៃនៃវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ក៏បានបញ្ជាក់ឱ្យដឹងទៀតថា កិច្ចប្រជុំរវាងភាគីទាំង២ បានធ្វើឡើងក្នុងបរិយាកាសស្និតស្នាល សាមគ្គីភាពមិត្តភាពរឹងមាំ៕

## ថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ០៤នាក់ ឲ្យមកកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI June 21 at 5:51 PM

កោះកុង៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៧ និង១៥នាទី ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ពីភាគីថៃ ចំនួន០៤នាក់។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ៦៨នាក់ ឲ្យមកកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI June 21 at 4:36 PM

ឧត្តរមានជ័យ៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិជាំ នាថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ៦៨នាក់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកបឹងត្រកួន៣៧នាក់, ចាក់ប្រែង០៩នាក់, អូរស្វាយ០៥នាក់, ត្រពាំងបី០៥នាក់, ចំបកកោង០៤នាក់, ជំនុន០៣នាក់, អូរថ្ម០២នាក់, អូរស្មាច់០១នាក់, ភ្នំខ្មោច០១នាក់, ទឹកជប់០១នាក់៕

## ប៉ូលិសចិនជួយសង្គ្រោះស្ត្រីបរទេសជាង១,១០០នាក់ដែលត្រូវគេលក់

https://vayofm.com/news/detail/ ដោយ៖ ពេញ ផេង 22-06-2019 6:28 am

ប៉ូលិសចិនបានជួយសង្គ្រោះស្ត្រីជាង១,១០០នាក់ ធ្វើដំណើរមកពីតំបន់អាស៊ីអាគ្នេយ៍ ដែលត្រូវបានគេលក់ឲ្យទៅធ្វើជាប្រពន្ធបុរសជាច្រើនកាលពីឆ្នាំមុន។ នេះបើតាមការបញ្ជាក់ពីអាជ្ញាធរកាលពីថ្ងៃសុក្រ។ ក្មេងៗចំនួន១៧នាក់ក៏ត្រូវបានជួយសង្គ្រោះផងដែរ នៅក្នុងប្រតិបត្តិការរួមគ្នាជាមួយប៉ូលិសមីយ៉ាន់ម៉ា កម្ពុជា ឡាវ វៀតណាម និងថៃ ចន្លោះពីខែកក្កដាដល់ខែធ្នូឆ្នាំមុន នេះបើតាមសេចក្តីថ្លែងការណ៍ក្រសួងសន្តិសុខសាធារណៈ។

ជនសង្ស័យជាង១,៣០០នាក់ ក្នុងនោះមានជនបរទេស២៦០នាក់ ត្រូវបានឃាត់ខ្លួន ក្នុងប្រតិបត្តិការបង្ក្រាបការចាប់ពង្រត់ ការលក់ដូរមនុស្ស និងការបន្លំអាពាហ៍ពិពាហ៍។ អ្នកនាំពាក្យក្រសួងសន្តិសុខសាធារណៈបានឲ្យដឹងនៅក្នុងសេចក្តីថ្លែងការណ៍ថា ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ មានឧក្រិដ្ឋជនក្នុងស្រុក និងបរទេសបានឃុបឃិតគ្នា ចាប់ពង្រត់ស្ត្រីជាច្រើននាក់ហើយលក់ដូរពួកគេឲ្យធ្វើជាប្រពន្ធបុរសជាច្រើន។ ប៉ុន្តែស្ត្រីខ្លះទៀតបានធ្លាក់ខ្លួនទៅរៀបការក្រោមរូបភាពបោកប្រាស់ ធ្វើឲ្យពួកគេប្រឈមនឹងការរំលោភបំពាន ការឃុំឃាំងក្រោមច្បាប់អន្តោប្រវេសន៍ ឬក៏ត្រូវបង្ខំឲ្យពួកគេធ្វើជាស្រីពេស្យា៕

# ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១៩

## កូរ៉េជួយកម្ពុជា បន្តគម្រោងអភិវឌ្ឍន៍ ប្រព័ន្ធសេវាការងារ សាធារណៈ

https://www.dap-news.com/archives/ ByID:117 Posted on 24 June 2019 | 17:15

**ភ្នំពេញ៖** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះកិច្ចព្រមព្រៀង ជាមួយក្រសួងការងារ និងមុខរបរនៃសាធារណរដ្ឋកូរ៉េ លើការដាក់ឲ្យដំណើរការអនុវត្តគម្រោង «ការអភិវឌ្ឍប្រព័ន្ធផ្តល់ សេវាការងារសាធារណៈ ឬហៅថា PES System» ក្រោមគម្រោង Korea-Cambodia WorkNet ដំណាក់កាលទី២ (២០១៩-២០២០)។ នេះបើតាមការចុះផ្សាយ ពីគេហទំព័រក្រសួងការងារ ។

កិច្ចព្រមព្រៀងនេះ ត្រូវបានចុះហត្ថលេខាដោយលោក ហៃ ហ៊ុនឡេង ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ(NEA) ជាមួយលោក យ៉ាង ស៊ុងជុន (Yang Seung-jun) ប្រធាននាយកដ្ឋានសហប្រតិបត្តិ ការអភិវឌ្ឍនៃ

ក្រសួងការងារ និងមុខរបរនៃសាធារណរដ្ឋកូរ៉េ ក្រោមអធិបតីភាពលោកបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ នាថ្ងៃរសៀលថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩។

មុនពិធីចុះហត្ថលេខានេះ លោកអ៊ិត សំហេង បានជួបពិភាក្សាជាមួយលោក យ៉ាន ស៊ុងជុន ដោយផ្តោតលើកិច្ចសហប្រតិបត្តិការវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរវាងកម្ពុជា និងសាធារណរដ្ឋកូរ៉េ។ នាឱកាសនោះ រដ្ឋមន្ត្រីលើកឡើងថា នាពេលកន្លងមក កម្ពុជា-កូរ៉េមានទំនាក់ទំនងល្អជាមួយគ្នា និងជាដៃគូកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ដោយភាគីកូរ៉េ បានទទួលពលករកម្ពុជា ទៅធ្វើការនៅទីនោះជាបន្តបន្ទាប់ ។ រហូតដល់បច្ចុប្បន្នចំនួន ពលករកម្ពុជា ទៅធ្វើការនៅកូរ៉េ កើនដល់ជិត៦ម៉ឺននាក់។

ពាក់ព័ន្ធនឹងគម្រោង «ការអភិវឌ្ឍប្រព័ន្ធផ្តល់សេវាការងារសាធារណៈ ឬហៅថា PES System» នេះ ត្រូវបានបណ្ឌិតរដ្ឋមន្ត្រី គាំទ្រ និងលើកទឹកចិត្តយ៉ាងពេញទំហឹង និងបានស្នើឲ្យក្រុមការងារបច្ចេកទេសទាំងពីរភាគី ខិតខំធ្វើការងារបានជិតស្និទ្ធ ដើម្បីសម្រេចបានជោគជ័យសម្រាប់ប្រទេសជាតិទាំងពីរ ។ ពាក់ព័ន្ធគម្រោងការអភិវឌ្ឍប្រព័ន្ធផ្តល់សេវាការងារសាធារណៈនេះដែរ លោក យ៉ាង បានបង្ហាញក្តីរំពឹងទុកថា នឹងទទួលបានលទ្ធផលល្អប្រសើរ សម្រាប់ជាទ្រព្យសម្បត្តិ របស់ប្រជាជាតិទាំងពីរ៕

# ថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៩

## សម្តេចក្រឡាហោម ស ខេង ស្នើទៅរដ្ឋមន្ត្រីយុត្តិធម៌ ឱ្យបង្កកទ្រព្យសម្បត្តិអ្នកជួញដូរគ្រឿងញៀន និងអ្នកជួញដូរមនុស្ស

http://www.freshnewsasia.com/ 2019-06-26

**(ភ្នំពេញ)៖** សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានស្នើទៅលោក អង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឱ្យសហការគ្នាធ្វើសកម្មភាព បង្កក់ទ្រព្យសម្បត្តិជនណា ដែលជួញដូរគ្រឿងញៀន និងជនណាដែលជួញដូរមនុស្ស។

ការលើកឡើងរបស់សម្តេចរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទៅកាន់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បែបនេះ បានឡើងក្នុងឱកាស ដែលសម្តេចអញ្ជើញជាអធិបតីភាព ក្នុងទិវាប្រឆាំងគ្រឿងញៀនអន្តរជាតិ នៅព្រឹកទី២៦ ខែមិថុនា ឆ្នាំ២០១៩ នេះ នៅមជ្ឈមណ្ឌលកោះពេជ្រ រាជធានីភ្នំពេញ។ សម្តេចក្រឡាហោម ស ខេង បានលើកឡើងថា ឥទ្ធិពលគ្រឿងញៀននេះ បើតាមការយល់ឃើញរបស់សម្តេច វាមានផលអាក្រក់ណាស់។ ទីមួយ៖ វាធ្វើឱ្យបាត់បង់ធនធានមនុស្ស ព្រោះគ្រឿងញៀន វាយលុកក្នុងស្រទាប់យុវវ័យ ដែលកំពុងតែសិក្សារៀនសូត្រ ធ្វើឱ្យអនាគតប្រទេសជាតិត្រូវអន្តរាយ។ ទីពីរ៖ គ្រឿងញៀននេះ វាពាក់ព័ន្ធនឹងបទល្មើសគ្រប់ប្រភេទ អ្នកប្រើគ្រឿងញៀនអាចក្លាយទៅជាគេរវេរ អាចទៅជាចោរលួច ចោរប្លន់ ដែលវាជាបទឧក្រិដ្ឋមួយ។

សម្តេចរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាក់បន្តយ៉ាងដូច្នេះថា៖ **«ចំណុចមួយទៀត ដែលខ្ញុំចង់និយាយនៅទីនេះ អ្នករកស៊ីគ្រឿងញៀន បានលុយមកតើលុយនោះ ជាលុយស្របច្បាប់ ឬមិនស្របច្បាប់? គេមិនដែលឱ្យតម្លៃឱ្យភាពស្របច្បាប់លុយដែលបានមកពីគ្រឿងញៀនជាលុយត្រឹមត្រូវទេ។ គេចាត់ទុកថា លុយបានមកពីការរកស៊ីគ្រឿងញៀននេះ គឺជាលុយកខ្វក់ គឺជាលុយខ្មៅ ហើយបើវាជាលុយខ្មៅហើយនោះ បទល្មើសគ្រឿងញៀនវាច្រើន វានឹងប៉ះពាល់ដល់ចរាចរលុយកាក់របស់កម្ពុជា ដែលនេះជាបញ្ហា»**។ សម្តេចបន្តថា «អញ្ចឹងទេ ខ្ញុំស្នើដល់ស្ថាប័នតុលាការ ក៏ដូចជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សហការគ្នាដើម្បីអនុវត្តនូវមាត្រាណាមួយ ខ្ញុំចាំមិនច្បាស់ទេ ប៉ុន្តែត្រូវតែបង្កក់ទ្រព្យសម្បត្តិ ទាំងលុយ ទាំងអចលនទ្រព្យ មានទាំងដី ម៉ូតូ ហើយលុយនោះពេលអនុវត្តសាលដីកា មានព្រះរាជអាជ្ញាទៅជាមួយសមត្ថកិច្ចហើយ។ បន្ទាប់មកទើបព្រះរាជអាជ្ញាចេញដីកាចោទប្រកាន់ គឺពេលហ្នឹងយើងត្រូវតែបង្កក់ទ្រព្យសម្បត្តិ តាំងពីពេលនេះ

ទៅបានន័យថា តុលាការ ព្រះរាជអាជ្ញា គាត់ចេញដីការមួយបង្កក់ទ្រព្យសម្បត្តិ របស់ជនសង្ស័យគ្រឿងញៀន ព្រោះថា បើមិនអញ្ចឹងទេ យើងឃុំតែមនុស្សប៉ុន្តែលុយវាចរាចរណ៍»។

បើតាមសម្តេចក្រឡាហោម ស ខេង ករណីមួយទៀត ដែលសម្តេចស្នើទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឱ្យបង្កក់ទ្រព្យសម្បត្តិនោះ គឺត្រូវបង្កក់ទៅលើជនណា ដែលរកស៊ីករណីជួញដូរមនុស្ស។ សម្តេចថ្លែងថា មូលហេតុដែលសម្តេចស្នើទៅឱ្យមានការបង្កក់ទ្រព្យសម្បត្តិ អ្នកជួញដូរមនុស្ស ព្រោះថវិកាដែលបានមកពី ការធ្វើសកម្មភាពជួញដូរមនុស្សនេះ វាអាចក្លាយជាហិរញ្ញប្បទាន បង្កជាភេរវកម្ម ហើយវាជាការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរទៀតផង។

សម្តេចរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាក់ថា «**យកមនុស្សទៅលក់ ទៅដល់គេឱ្យធ្វើពលកម្ម ឱ្យដក់គ្រឿងញៀន ទម្រាំមកផ្ទះវិញស្គមស្គាំ មិនបានប៉ុន្មានក៏ស្លាប់ទៅ វាវេទនាណាស់.....**»៕

## លោកជំទាវ ប៉ុណ្ណ សំខាន់ អគ្គលេខាធិការគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សៈសួរសុខទុក្ខ និងចូលរួមឧបត្ថម្ភ គ្រួសារសពជនរងគ្រោះ ក្នុងខេត្តកំពង់ឆ្នាំងដែលរងគ្រោះក្នុងឧបទ្ទវហេតុរលំអគារនៅខេត្តព្រះសីហនុ

http://gdlf-kh.com/ 25/06/2019 Sek Samnang កំពង់ឆ្នាំង

ខេត្តកំពង់ឆ្នាំង៖នៅថ្ងៃ២៥ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង១៣ និង៣០នាទី លោកជំទាវ **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គជបជ) តំណាងលោកជំទាវ **ជូ ប៊ុនអេង**អនុប្រធានសមាគមន៍នារី និងអនុប្រធានអចិន្ត្រៃយ៍ (គជបជ) រួមដំណើរដោយលោកជំទាវតំណាងរាស្ត្រ លោកជំទាវក្រុមប្រឹក្សាខេត្ត លោកអភិបាលស្រុក មេឃុំ នរបាលបុស្តិ៍ និងសសយក បានចុះសួរសុខទុក្ខ និងចូលរួមឧបត្ថម្ភ គ្រួសារសពជនរងគ្រោះ ក្នុងខេត្តកំពង់ឆ្នាំងដែលរងគ្រោះក្នុងឧបទ្ទវហេតុរលំអគារនៅខេត្តព្រះសីហនុ។

សពមានចំនួន ០៣ ក្នុងសពមួយ បានទទួលថវិកា ១,២០០,០០០រៀល (មួយលានពីរសែនរៀល)។ សពទាំង ៣ស្ថិតនៅក្នុងឃុំ ពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ សព១ទៀតត្រូវបានម្តាយយកទៅស្ទឹងមានជ័យ។ សពទាំង៣ត្រូវបានបូជាតាមប្រពៃណី៕

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ផ្ញើសារលិខិតចូលរួមរំលែកទុក្ខក្រុមគ្រួសារ និងញាតិជនរងគ្រោះ នៅក្នុងសោកនាដកម្មរលំបាក់អគារ ក្នុងខេត្តព្រះសីហនុ

http://www.freshnewsasia.com/ 2019-06-26

**(ភ្នំពេញ)៖** ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានផ្ញើសាររំលែកទុក្ខចំពោះក្រុមគ្រួសារជនរងគ្រោះ ក្នុងឧបទ្ទវហេតុបាក់រលំអគារកម្ពស់ ៧ជាន់ សង្កត់លើ ស្ថិតនៅភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

នៅក្នុងសាររំលែកទុក្ខ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានក្តីរន្ធត់យ៉ាងខ្លាំង និងសោកស្តាយជាអនេក បន្ទាប់ពីបានទទួលដំណឹងដ៏ក្រៀមក្រំអំពីសោកនាដកម្មរលំបាក់អគារកំពស់ ៧ជាន់ កាលពីព្រឹកទី២២ ខែមិថុនា ឆ្នាំ២០១៩ នៅខេត្តព្រះសីហនុ ដោយបានបង្កឲ្យមានការ បាត់បង់អាយុជីវិត និងរងរបួសបងប្អូនជនរួមជាតិជាកម្មករ-កម្មការិនី ដែលបម្រើការងារនៅក្នុងការដ្ឋានសាងសង់នោះ។ ក្នុងឱកាសប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំនេះ យើងខ្ញុំទាំងអស់គ្នាសូមសំដែងនូវការសោកស្តាយស្រណោះអាឡោះអាល័យ និងសូមចូលរួមចែករំលែកនូវមរណទុក្ខជាមួយក្រុមគ្រួសារ និងញាតិមិត្តទាំងអស់ដែលបានបាត់បង់សមាជិកខ្លួន នៅក្នុងហេតុការដ៏សោកសៅនេះ ដោយក្តីសង្វេគជាទីបំផុត និងសូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធសពរបស់បងប្អូន បានសោយសុខក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ព្រមទាំងសូមជូន

ពរដល់បងប្អូនជាជនរងគ្រោះដែលកំពុងសម្រាកព្យាបាលរបួស សូមបានឆាប់ជាសះស្បើយដើម្បីអាចវិលមកប្រកបជីវភាពជាប្រក្រតីឡើងវិញ។

ជាថ្មីម្តងទៀត យើងខ្ញុំជាថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស (គ.ជ.ប.ដ) សូមកោតសរសើរ និងផ្តល់កម្លាំងចិត្តដល់ក្រុមជួយសង្គ្រោះមកពីគ្រប់ផ្នែកទាំងអស់ ដែលបាននិងកំពុងប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តជួយសង្គ្រោះ ដល់ជនរងគ្រោះដែលកំពុងជាប់នៅក្រោមគំនរអគាររលំបាក់ ទទួលបានជោគជ័យ និងសុខសុវត្ថិភាពគ្រប់ៗគ្នា៕

## វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ស្តីពី ការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ

https://www.cpp.org.kh/ POSTED ON ថ្ងៃ អង្គារ, 25 មិថុនា, 2019 អត្ថបទដោយ KIMAU MET

នៅថ្ងៃច័ន្ទ ៧រោច-ពុធ៩រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក.ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៤-២៦ ខែមិថុនា ឆ្នាំ២០១៩ ការិយាល័យទប់ស្កាត់ការរំលោភសេពសន្ថវៈ ក្នុងនាយកដ្ឋានការពារផ្លូវច្បាប់ នៃក្រសួងកិច្ចការនារី បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ស្តីពី ការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ (នៅខេត្តមណ្ឌលគិរី)ដែលមានខេត្តចំនួន៧ចូលរួមមាន ខេត្តមណ្ឌលគិរី រតនគិរី កំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង និងខេត្តតាកែវ។ ក្នុងគោលបំណង÷ផ្តល់ចំណេះដឹង និងបទពិសោធន៍មួយចំនួនដល់មន្ត្រីខេត្ត ស្រុក ឃុំ សង្កាត់ និងប្រជាពលរដ្ឋ នៅមូលដ្ឋាន ក្នុងការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ យកទៅអនុវត្តឱ្យមានប្រសិទ្ធភាព និងជួយជនរងគ្រោះឱ្យបានទាន់ពេលវេលា។

## ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០១៩

## រដ្ឋមន្ត្រីមហាផ្ទៃ ឲ្យភាគីពាក់ព័ន្ធ ពន្យល់ពលរដ្ឋខ្មែរ កុំចូលកាប់ឈើខុសច្បាប់នៅថៃ ព្រោះថៃមានសិទ្ធិ បាញ់សម្លាប់ចោល

https://www.dap-news.com/ ByID:114 Posted on 27 June 2019 | 12:50

ភ្នំពេញ ៖ ក្រោយពីមានប្រជាពលរដ្ឋខ្មែរ ត្រូវទាហានថៃបាញ់សម្លាប់ ដោយសារតែលួចចូល កាប់ព្រៃឈើខុសច្បាប់ នាពេលកន្លងមកនោះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអំពាវនាវឲ្យគ្រប់ភាគីពាក់ព័ន្ធ ត្រូវនាំគ្នាទៅពន្យល់ប្រជាពលរដ្ឋ អំពីបញ្ហាកាប់ព្រៃឈើខុសច្បាប់នៅថៃ ពីព្រោះថៃមានច្បាប់បាញ់សម្លាប់ នៅនឹងកន្លែង ចំពោះជនណា ទៅលួចកាប់ព្រៃឈើខុសច្បាប់ លើទឹកដីរបស់គេ។

ក្នុងពិធីប្រកាស ចូលកាន់មុខតំណែង អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ សម្តេច ស ខេង បានថ្លែងឲ្យដឹងថា នៅតាមតំបន់ព្រំដែន ប្រជាពលរដ្ឋកម្ពុជា-ថៃ មានសិទ្ធិចេញចូលមករកស៊ី ជាមួយគ្នាជារៀងរាល់ថ្ងៃ ប៉ុន្តែអ្វីដែលហាមឃាត់ គឺការឆ្លងដែនខុសច្បាប់ ទៅរកកាប់ឈើនៅថៃ។ សម្តេចមានប្រសាសន៍ថា "ប៉ុន្មានថ្ងៃមុននេះដឹងថា បានចូលទៅក្នុងទឹកដីថៃ៣នាក់ រស់នៅព្រះវិហារទាំងអស់។ អាហ្នឹងធ្វើម៉េចពន្យល់ ប្រជាពលរដ្ឋកុំឲ្យចូល ពីព្រោះថៃមានច្បាប់ចេះ គឺមានច្បាប់កាត់ទោសប្រហារជីវិត ហើយមិនចាំបាច់ដល់តុលាការទេ គឺអ្នកការពារព្រៃរបស់គេមានសិទ្ធិ ដើម្បីបាញ់សម្លាប់ កាលណាអ្នកប៉ះពាល់ព្រៃរបស់គេ" ។ ជាងនេះទៅទៀត រដ្ឋមន្ត្រីមហាផ្ទៃ រំលឹកថា នាពេលកន្លងទៅសម្តេច និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃថៃ ក៏បានពិភាក្សាគ្នាផងដែរ ពីបញ្ហានេះ។ ពេលនោះភាគីថៃប្រាប់ថា បើចាប់បានគឺបាញ់សម្លាប់តែម្តង។

ទន្ទឹងនឹងនេះ ជាមួយភាគីឡាវវិញ រដ្ឋមន្ត្រីមហាផ្ទៃ បានថ្លែងសំណូមពរថា បើចាប់ពលរដ្ឋខ្មែរ ឆ្លងខុសច្បាប់ទៅឡាវ កុំបាញ់សម្លាប់ តែអនុវត្តន៍ទោស ទៅតាមច្បាប់ឡាវទៅ។ សម្តេចបញ្ជាក់ថា "ខ្ញុំជួបជាមួយនាយករដ្ឋមន្ត្រីឡាវ ខ្ញុំស្នើគាត់ថា ព្រោះគាត់អត់មានច្បាប់ដូចថៃទេ (ច្បាប់បាញ់សម្លាប់) បានន័យថា ឡាវចាប់ទៅអនុវត្តតាមច្បាប់។ ប៉ុន្តែដល់ថៃវិញគឺត្រូវបាញ់ ចឹងឡាវយើងស្នើទៅគាត់ធ្វើបាន ។ ឡាវចាប់ម៉េចចាប់ទៅ កុំតែអនុវត្តសម្លាប់ អាហ្នឹងឡាវធ្វើបាន" ។

ដើម្បីការពារធនធានធម្មជាតិ នៅកម្ពុជាឲ្យបានគង់វង្ស សម្តេចក្រឡាហោម ស ខេង ក៏បានប្តេជ្ញាចិត្ត ការពារធនធានធម្មជាតិឲ្យបាន ដើម្បីទុកឲ្យ កូនចៅជំនាន់ក្រោយបានមើល ខណៈនៅខេត្តព្រះវិហារ គឺសំបូរទៅដោយប្រភពរ៉ែ៕ ដោយ ៖ អេង ប៊ូឆេង

## ជនជាតិចិន និងឥណ្ឌូនេស៊ីបើកហាងយកនារីខ្មែរមិនគ្រប់អាយុបម្រើសេវាផ្លូវភេទនៅប៉ោយប៉ែត

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 27/06/2019

ខេត្តបន្ទាយមានជ័យ ៖ ក្រុងប៉ោយប៉ែតមានម៉ាស្សាជ្រកក្រោមផ្លាកកាស៊ីណូដែលរកស៊ីបម្រើសេវាផ្លូវភេទឲ្យជនបរទេសមានក្មេងស្រីអនិតិជនភាគច្រើនប្រមាណជាង២០កន្លែង ហើយជាថៅកែជនជាតិចិន និងឥណ្ឌូនេស៊ីដែលមិនសហការជាមួយមន្ត្រីជំនាញឡើយ ។

មន្ត្រីជំនាញម្នាក់បានបង្ហើបប្រាប់ព័ត៌មានថា នៅក្រុងប៉ោយប៉ែតមានកន្លែងម៉ាស្សាដែលលួចលាក់ប្រកបមុខរបរផ្លូវភេទសម្រាប់ភ្ញៀវបរទេសមានប្រមាណជាង២០កន្លែង ដែលកំពុងជ្រកក្រោមផ្លាកសញ្ញាកាស៊ីណូក្រុងប៉ោយប៉ែត ។មន្ត្រីរូបនោះបានបញ្ជាក់ថា កន្លែងម៉ាស្សាដែលលួចលាក់បើកសេវាផ្លូវភេទភាគច្រើនជាថៅជនជាតិចិន និងឥណ្ឌូនេស៊ី ដែលមានប្រមាណជាង២០កន្លែងក្នុងក្រុងប៉ោយប៉ែត ហើយមួយកន្លែងមានស្រីម៉ាស្សាដែលលួចលាក់បម្រើផ្លូវភេទមាន១០ទៅ២០នាក់ ហើយភាគច្រើនជាអនិតិជន មានអាយុ១៥ឆ្នាំក៏មានដែរ ។

ព័ត៌មានទទួលបាន គឺក្មេងស្រីម្នាក់ដែលធ្វើការក្នុងហាងម៉ាស្សាលួចលាក់បម្រើសេវាផ្លូវភេទ បានឲ្យដឹងថា៖ មានជនជាតិខ្មែរភាគច្រើន ជាងគេគឺជនជាតិវៀតណាម ដែលបម្រើសេវាផ្លូវភេទមានភ្ញៀវបរទេសជនជាតិចិន និងថៃ បើបម្រើក្នុងបន្ទប់សេវាម៉ាស្សា១ម៉ោងតម្លៃ២.០០០បាត និងចេញមប្រើសេវាក្រៅ១ម៉ោង៣.០០០បាត ។ហើយនៅក្រុងប៉ោយប៉ែតនេះមានកន្លែងម៉ាស្សាលួចលាក់បម្រើសេវាផ្លូវភេទជាច្រើនកន្លែងថៅកែជនជាតិចិន និងឥណ្ឌូនេស៊ី ។ បើតាមប្រភពពីមន្ត្រីជំនាញបានបង្ហើបប្រាប់ថា៖ ពិតជាពិបាកធ្វើការជាមួយព្រោះ ថៅកែជនជាតិចិន និងឥណ្ឌូនេស៊ីជ្រកក្រោមផ្លាកកាស៊ីណូ ដោយយកអំណាចក្រុមហ៊ុនកាស៊ីណូមិនសហការមន្ត្រីជំនាញទេ ។

លោកឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរងទទួលបន្ទុកការងារប្រឆាំងការជួញដូរ និងការពារក្មេងស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យបានប្រាប់ថា ជាការពិតណាស់នៅក្រុងប៉ោយប៉ែតដែលជាប់ព្រំដែនកម្ពុជា-ថៃ គឺជាតំបន់ដែលមានច្រើនកន្លែងម៉ាស្សាតម្រូវការភ្ញៀវបរទេស ហើយកន្លងមកកម្លាំងជំនាញបានចុះធ្វើការណែនាំអប់រំដល់ម្ចាស់ហាងម៉ាស្សា មិនឲ្យលួចលាក់មានបម្រើសេវាផ្លូវភេទដោយខុសច្បាប់ឡើយ ។ លោកស្រីបានបញ្ជាក់ថា ជាពិសេសមិនឲ្យមានអ្នកបម្រើការងារក្នុងហាងម៉ាស្សាជាអនិតិជនឡើយ តែបើមានរកឃើញ និងមានវិធានការតាមច្បាប់ ហើយសុំឲ្យខាងម្ចាស់ហាងម៉ាស្សាទាំងអស់នោះសហការជួយកម្លាំងជំនាញផងពេលចុះធ្វើការ៕

## ឃាត់ខ្លួនជនម្នាក់ពីបទពង្រាត់យុវតីតាមពាក្យបណ្ដឹងឪពុក

http://www.rasmeinews.com/ June 26, 2019, 8:23 PM

ដោយៈគ្រញូង/ប៉ៃលិនៈយុវជន ម្នាក់ ត្រូវកម្លាំងនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តប៉ៃលិនឃាត់ខ្លួនបញ្ជូនទៅតុលាការកាលពីព្រឹកថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ តាមពាក្យបណ្ដឹងរបស់ឪពុកយុវតីម្នាក់នៅក្នុងក្រុងប៉ៃលិនដោយចោទពីបទល្បួងកូនស្រីចេញពីផ្ទះ ជា លើក ទី ២អស់ រយៈពេល ជាង កន្លះ ខែមកហើយ។

លោកអ៊ុនសេរីវ័ត្នស្នងការរងទទួលផែនសេនាធិការខេត្តប៉ៃលិនបានឱ្យដឹងថាក្មេងស្រីមានឈ្មោះ ស. វ.អាយុ ១៥ ឆ្នាំ ជា អតីត សិស្ស រៀន ថ្នាក់ ទី៦នៃសាលាបឋមសិក្សាសខេងអូរតាវៅ។មានឪពុកឈ្មោះ ជុំ ភក្តី អាយុ ៣៥ ឆ្នាំ ម្ដាយឈ្មោះ ឆាត ឃឿ ន អាយុ ៣៧ ឆ្នាំ រស់នៅ ក្នុងភូមិ អូរ តា វៅ សង្កាត់ អូរ តា វៅ ក្រុងប៉ៃលិន។ដោយឡែកជនសង្ស័យឈ្មោះល័ក្ខហៅម៉ូនអាយុ២៥ឆ្នាំទីលំនៅ មិនពិតប្រាកដ។

លោកជុំ ភក្តីជាឪពុកបានឱ្យដឹងថា ក្រោយមកកូនស្រី របស់ គាត់ក៏ បន្ត លួចរ ត់ទៅ តាម យុវជន នោះ ជា លើក ទី ២ដោយ មិនឃើញ ត្រឡប់ មក ផ្ទះ វិញ ឡើយ ទើប គាត់ សម្រេចចិត្ត ដាក់ ពាក្យបណ្ដឹង ទៅ ស្នងការ ខេត្ត តែ ម្ដង ។

ពាក់ព័ន្ធ នឹង បញ្ហា នេះលោក អេ ង ភារ នាយការិយាល័យ ជួញដូរមនុស្សនិងការពារអនីតិជននៃស្នងការនគរបាលខេត្តប៉ៃលិនបានឱ្យដឹងថា នៅព្រឹកថ្ងៃទី២៦ ខែមិថុនានេះថា នឹងកសាងសំណុំរឿងទៅតុលាការដើម្បី ដោះស្រាយ តាមច្បាប់៕S/

## សំណុំរឿង ម្ដាយខ្ញុំលក់ខ្ញុំ ប្រកាសសាលក្រមហើយ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៩ ម៉ោង ០៨:៣៣ ឃឹម ប៊ុនណាក់

រាជធានីភ្នំពេញ ៖ សាលក្រមបានប្រកាសធ្វើឡើង កាលពីរសៀលថ្ងៃទី២៦ ខែមិថុនា លើសំណុំរឿង ម្ដាយខ្ញុំលក់ខ្ញុំ ដោយតម្រូវផ្ដន្ទាទោសលើជនជាប់ចោទដាក់ពន្ធនាគារកំណត់២ឆ្នាំ និងសងជម្ងឺចិត្តទៅដើមបណ្ដឹង២នាក់ចំនួន៧០លានរៀល ។ សាលក្រមបានទុកសិទ្ធិឲ្យជនជាប់ចោទប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

គួរបញ្ជាក់ថា សាលាដំបូងរាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ បានបន្តលើកយកសំណុំរឿង ម្ដាយខ្ញុំលក់ខ្ញុំ មកបើកសវនាការជំនុំជម្រះក្ដី ដែលអង្គសវនាការនោះមានលោក កូយ សៅ ចៅក្រមជំនុំជម្រះ និងលោក វង្ស ប៊ុនវិសុទ្ធ ព្រះ រាជអាជ្ញារងជាតំណាងអយ្យការ ។

ជនត្រូវចោទក្នុងសំណុំរឿងក្ដីនេះឈ្មោះ រ៉ាត់ រ័ត្នមុនី ភេទប្រុស អាយុ៤៧ឆ្នាំ ត្រូវបានសមត្ថកិច្ចចាប់ និងឃុំខ្លួនកាលពីថ្ងៃទី១៣ ខែធ្នូ ២០១៨ ពាក់ព័ន្ធនឹងការផលិតវីដេអូរឿង ម្ដាយខ្ញុំលក់ខ្ញុំ។ ជនត្រូវចោទត្រូវបានតំណាងអយ្យការចោទប្រកាន់ពីបទ ញុះញង់ឲ្យមានការរើសអើង តាមមាត្រា៤៩៦ នៃ ក្រមព្រហ្មទណ្ឌ ប្រព្រឹត្តកាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៨ ដែលដើមបណ្ដឹងក្នុងសំណុំរឿងក្ដីនេះមាន៤ នាក់ ៕ (កែសម្រួលដោយ ៖ ធីតា)

## បែកធ្លាយ លោក អាន់ សំអាត់ ប្រធានការិយាល័យច្រកចេញចូលតែមួយសាលាខេត្តឧត្តរមានជ័យ ប្រមូលប្រាក់ពុករលួយរាប់ម៉ឺនដុល្លារពីពលរដ្ឋក្រីក្រតាមរយៈផ្ដល់បណ្ណ័ព្រំដែន

http://nokorwatnews.com/ 27-06-2019

ខេត្តឧត្តរមានជ័យ៖ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ នេះមានការបែកធ្លាយមកថា លោកអាន់ សំអាត ប្រធានការិយាល័យច្រកចេញចូលតែមួយ សាលាខេត្តឧត្តរមានជ័យ បានប្រព្រឹត្តអំពើពុករលួយយ៉ាងធ្ងន់ធ្ងរ ដោយធ្វើ

សកម្មភាព គាបសង្កត់ធ្វើបាប ជញ្ជក់ឈាមពី ប្រជាពលរដ្ឋក្រីក្ររាប់ពាន់នាក់ក្នុងមួយខែ និងប្រមូលប្រាក់បានរាប់ម៉ឺនដុល្លារក្នុងមួយខែ តាមរយៈការផ្ដល់សៀវភៅឆ្លងដែន ។

ប្រភព បានឲ្យដឹងថា លោក អាន់ សំអាត់ បានដាក់បណ្ដាញជាច្រើនកន្លែងនៅសង្កាត់អូរស្មាច់ ទទួលប្រមូលធ្វើសៀវភៅឆ្លងដែនកំណត់យកប្រាក់ក្នុងម្នាក់ពី ១៤ទៅ១៥ម៉ឺនរៀល ពីពលរដ្ឋមកពីខេត្តផ្សេង ដែលត្រូវការប្រើប្រាស់សៀវភៅឆ្លងដែន ទៅព្យាលជំងឺ រឺទៅធ្វើពលករស្រុកថៃ ។ ប្រភពបន្ថែមថា បង់ប្រាក់ក្នុងម្នាក់១៤ទៅ១៥ម៉ឺនរៀល គឺអ្នកប្រមូលទទួលធ្វើបណ្ណំព្រំដែន យកប្រាក់មកប្រគល់ឲ្យលោក អាន់ សំអាត ប្រធានការិយាល័យច្រកចេញចូលតែមួយចំនួន១០ម៉ឺនរៀល ក្នុងម្នាក់ រីឯកអ្នកប្រមូលចំណេញម្នាក់៤ទៅ៥ម៉ឺនរៀល ។ ប្រភពបានបន្តថា លោកអាន់សំអាត បានផ្ដើន នឹង អនុក្រឹតរបស់ក្រសួងមហាផ្ទៃ ក្នុងការផ្ដល់បណ្ណំព្រំដែន គឺយកថ្លៃសេវា ចាប់ពី១៤ម៉ឺនរៀល និង១៥ម៉ឺនរៀល ក្នុងសៀវភៅឆ្លងដែនមួយក្បាល ដែលសៀវភៅបន្ទុកក្រសួងមហាផ្ទៃតម្រូវកំណត់ បណ្ណំព្រំដែនមួយក្បាលតែពីរម៉ឺនរៀល ។ មិនតែប៉ុណ្ណោះ លោក អាន់ សំអាត បានយកលំនៅឋានរបស់ខ្លួន ធ្វើជាកន្លែងច្រកចេញចូលតែមួយសម្រាប់ធ្វើបណ្ណំឆ្លងដែន និងបំពេញបែបបទផ្សេងៗដោយមិនបានឆ្លងកាត់ការត្រួតពិនិត្យឯកសារផ្សេងៗពីរដ្ឋបាលសាលាខេត្ត ។ គ្រាន់តែមានហត្ថលេខាលោក លឹម សុខតូ អភិបាលរងខេត្តម្នាក់គ្រប់គ្រាន់ ដោយមិនគោរពទៅតាមបទដ្ឋានគតិយុត្ត របស់ក្រសួងមហាផ្ទៃ ដាក់ចេញដើម្បីឲ្យអនុវត្ត ។

សព្វថ្ងៃនេះ មានប្រជាពលរដ្ឋមិនក្រោមរាប់ពាន់នាក់ក្នុងមួយខែ ដែលបានចាញ់បោក និងត្រូវលោក អាន់សំអាត គាបសង្កត់ពួកគាត់ឲ្យបង់ប្រាក់លើសសៀវភៅបន្ទុក។ គួរបញ្ជាក់ថា ក្នុងម្នាក់ត្រូវបង់ប្រាក់ចាប់ពី១៤ម៉ឺនរៀលទៅ១៥ម៉ឺនរៀល ក្នុងរយៈពេលពីរទៅបីថ្ងៃបានសៀវភៅឆ្លងដែនយកទៅប្រើប្រាស់ ដែលតម្លៃខាងលើនេះ បានលើសទៅនឹងសៀវភៅបន្ទុករបស់ក្រសួងមហាផ្ទៃបានកំណត់ រហូតគុណ និង៧ដង ដែលក្រសួងកំណត់យកសេវាត្រឹមតែ២ម៉ឺនរៀលតែប៉ុណ្ណោះ ។ ប្រភពបន្ថែមថា លោកអាន់ សំអាត បានជញ្ជក់ឈាមរាស្ត្រចាប់តាំងពីក្រសួងមហាផ្ទៃចេញអនុក្រឹត្យប្រកាសផ្ទេរសេវាកម្មផ្ដល់សៀវភៅឆ្លងដែន ពីនគរបាលអន្តោប្រវេសន៍ មកឲ្យអាជ្ញាធរខេត្តជាអ្នកទទួលវិញម្ដង ។ សូមគូសបញ្ជាក់ផងដែថា រាល់ការបំពេញបែបបទសៀវភៅឆ្លងដែន របស់ច្រកចេញចូលតែមួយ សាលាខេត្តឧត្តរមានជ័យ មានតែហត្ថលេខាលោក លឹម សុខតូ អភិបាលរងខេត្តឧត្តរមានជ័យតែម្នាក់ ដោយមិនមានការត្រួតពិនិត្យរាល់ឯកសារផ្សេងៗឆ្លងកាត់រដ្ឋបាលខេត្តនោះទេ ។

ដោយមានការដាក់ការសង្ស័យថា មានការឃុបឃិត និយមបក្ខពួក ក្រុមការងារនៅក្នុងសាលាខេត្តឧត្តរមានជ័យ ទើបមិនបានបំពេញតាមលក្ខខណ្ឌរបស់ក្រសួងបានដាក់ជូន ពោលគឺលោកអាន់ សំអាត ប្រធានការិយាល័យច្រកចេញចូលតែមួយ មិនបានគោរពទៅតាមបទដ្ឋានគតិយុទ្ធរបស់ក្រសួងមហាផ្ទៃនោះទេ បែរជាយកផ្ទះខ្លួនឯងធ្វើកន្លែងធ្វើការងារ តម្រូវឲ្យពលរដ្ឋបង់សេវាលើសសៀវភៅបន្ទុក សម្រុកប្រមូលប្រាក់រាប់ម៉ឺនដុល្លារ ពីរាស្ត្រក្រីក្ររាប់ពាន់នាក់ចាញ់បោករៀងរាល់ថ្ងៃ ដោយមិនដឹងខ្លួន។

លោក អាន់ សំអាត បានឲ្យដឹងតាមទូរសព្ទ័ថា លោកធ្វើគោរពតាមសេចក្ដីណែនាំរបស់ក្រសួងទាំងអស់ បើប្រពលរដ្ឋណាម្នាក់មិនមានឯកសារគ្រប់គ្រាន់ ឬសាច់ញាតិខ្លួនយកមកទេ គឺលោកមិនទទួលឡើយ ព្រោះគ្មានបុគ្គលណាម្នាក់ កាន់ឯកសារ៤ទៅ៥ច្បាប់ មកធ្វើបានទេ ៕ ប៉ែន នួន

## សមត្ថកិច្ចថៃ បានបញ្ជូនប្រជាពលរដ្ឋកម្ពុជាចំនួន ១៣នាក់ មកកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI 26-06-2019

សមត្ថកិច្ចថៃ បានបញ្ជូនប្រជាពលរដ្ឋកម្ពុជាចំនួន ១៣នាក់ ដែលបានដោះលែងពីពន្ធនាគារខេត្តឧប៊ុនប្រទេសថៃ មកប្រគល់ជូនសមត្ថកិច្ចកម្ពុជាប្រចាំច្រកទ្វារតំបន់ព្រំដែន អានសេះ នារសៀលថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩។ សមត្ថកិច្ចយើងបានធ្វើការអប់រំរួច ឲ្យត្រឡប់ទៅលំនៅដ្ឋានវិញរៀងៗខ្លួន៕

# អង្គការ (LPN) ចូលរួមពិភាក្សាដោះស្រាយបញ្ហាជូនក្រុមគ្រួសារពលករកម្ពុជាពីរគ្រួសារ និងជនរងគ្រោះម្នាក់ ដែលរងគ្រោះថ្នាក់ស្លាប់បាត់បង់ជីវិត ក្នុងហេតុការណ៍លិចទូកនេសាទត្រីនៅកោះគូតខេត្តត្រាត

https://www.facebook.com/Cambodia-Migrant-Labour-Group-CMLG 27-06-2019

26.06.19 អង្គការបណ្តាញលើកកម្ពស់គុណភាពជីវិតពលករ (LPN) បានធ្វើដំណើរទៅកាន់ ច្រកទ្វារព្រំដែនអន្តរជាតិខ្លងឡឹក ស្រុក អារញ្ញ ខេត្តស្រះកែវ ដើម្បីចូលរួមពិភាគក្សារដោះស្រាយបញ្ហាជូនក្រុមគ្រួសារពលករកម្ពុជាពីរគ្រួសារនិងជនរងគ្រោះម្នាក់ ដែលរងគ្រោះថ្នាក់ស្លាប់បាត់បង់ជីវិត ក្នុងហេតុការណ៍លិចទូកនេសាទត្រីនៅកោះគូតខេត្តត្រាត កាលពីថ្ងៃទី18 ខែមិថុនា ឆ្នាំ2019 កន្លងទៅ ក្នុងកិច្ចចូលរួមពិភាក្សាដោះស្រាយបញ្ហាជូនគ្រួសារពលករកម្ពុជា ដោយមានការអញ្ជើញចូលរួមពីសំណាក់ ប្រធានមន្ទីរគាំពារសិទ្ធិ និងសុខុមាលភាពខេត្តស្រះកែវ ,អជ្ញាធរអធិការកិច្ចផ្នែកគាំពារសិទ្ធិ និងសុខមាលភាពនៃក្រសួងការងារ, ប្រធានមន្ទីរសន្តិសុខសង្គមខេត្តស្រះកែវ, តំណាងឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ ,មន្ត្រីកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវ អនុប្រធានមន្ទីរប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តបន្ទាយមានជ័យ ,អនុប្រធានមន្ទីរសសំចតក្រុងប៉ោយប៉ែត ,នគរបាលច្រកទ្វារព្រំដែនក្រុងប៉ោយប៉ែត។ លិទ្ធផលពិភាក្សាដោះស្រាយមានដូចតទៅ៖

ខាងភាគីថៃបានតម្រូវអោយក្រុមគ្រួសារជនរងគ្រោះរកឯកសារបន្ថែម ចំនួនមួយគ្រួសារ 1ច្បាប់ ដោយខាងភាគីអាជ្ញាធរកម្ពុជាជាអ្នកជួយសម្រួលរឿងឯកសារដែលខ្វះខាត។

ក្នុងនោះដែរខាងមន្ត្រីកុងស៊ុលប្រចាំស្រះកែវ បានទទួលបកប្រែឯកសារសំខាន់ៗរបស់ក្រុមគ្រួសារជនរងគ្រោះដើម្បីយកទៅប្រើប្រាស់ក្នុងការទទួលយកសំណងពីថៅកែនិងបេឡាសន្តិសុខសង្គមថៃ។

1.មន្ទីរគាំពារនឹងសុខមាលភាព ទទួលសំណើពីជនរងគ្រោះដើម្បីជំរុញទៅថៅកែបើកប្រាក់ខែដែលនៅសេសសល់ដល់សាច់ញាតិនិងជនរងគ្រោះ។

2.សាច់ញាតិពលករ ស្លាប់បាត់បង់ជីវិត ឈ្មោះ ប៊ុន ធារ៉ា ហៅ (ប៊ុនថៃ កៅ) ត្រូវទទួលបានសំណង ពីរបេឡាសន្តិសុខសង្គម តាមច្បាប់ក្រសួងការងារថៃ។

3-សាច់ញាតិពលករ ស្លាប់បាត់បង់ជីវិត ឈ្មោះ នី នាង ត្រូវទទួលបានសំណងផ្ទាល់ពីថៅកែ ដោយមានមន្ទីរសន្តិសុខសង្គមថៃ ជាអ្នកជំរុញទៅថៅកែអោយធ្វើការចរាចរជាក្រុមគ្រួសារជនរងគ្រោះ ដើម្បីផ្តល់សំណងណាមួយដែលសមរម្យដល់សាច់ញាតិជនរងគ្រោះអោយឆាប់រហ័ស។

4-ខាងសាច់ញាតិជនរងគ្រោះសម្រេចទទួលយកប្រាក់សំណងតាមរយៈក្រសួងការបរទេសថៃ នៅស្ថានទូតថៃប្រចាំក្រុងភ្នំពេញ ប្រទេសកម្ពុជាយើង។

ក្នុងបញ្ហានេះដែរដោយសារតែ ពលករ ឈ្មោះ នី នាង បានចូលមកធ្វើការនៅក្នុងប្រទេសថៃ ដោយមិនត្រឹមត្រូវទើបការទទួលបានសំណងតម្រូវអោយថៅកែជាអ្នកផ្តល់ជូន។ យ៉ាងណាមិញករណីទាមទារសំណងដល់សាច់ញាតិជនរងគ្រោះខាងលើនេះអជ្ញាធរព័ន្ធទាំងកម្ពុជា និងក្នុងប្រទេសថៃនិងធ្វើការតាមដានបន្តរហូតដល់ខាង ក្រុមគ្រួសារជនរងគ្រោះទទួលបានសំណងតាមសិទ្ធិ និងច្បាប់ការងារថៃដែលបានកំណត់។

## កម្លាំងសមត្ថកិច្ចអន្តោប្រវេសន៍ថៃ ប្រចាំច្រកទ្វារអន្តរជាតិខ្លងឡឹក ខេត្តស្រះកែវ បានធ្វើការឃាត់ខ្លួន ពលរដ្ឋខ្មែរ ចំនួន 02នាក់ ប្រើប្រាស់ឯកសារទិដ្ឋាការវីសាក្លែងក្លាយ

https://www.facebook.com/PrakPheakTraOfficial/ PheakTra **27-06-2019**

14.06.19 កន្លងទៅកម្លាំងសមត្ថកិច្ចអន្តោប្រវេសន៍ថៃ ប្រចាំច្រកទ្វារអន្តរជាតិខ្លងឡឹក ស្រុក អារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ បានធ្វើការឃាត់ខ្លួន ពលរដ្ឋខ្មែរ ចំនួន 02 នាក់ បន្ទាប់ពីសមត្ថកិច្ចថៃ រកឃើញថា ពលរដ្ឋខ្មែរទាំងពីរនាក់ ប្រើប្រាស់ឯកសារទិដ្ឋាការវីសាក្លែងក្លាយនៅក្នុងប្រទេសថៃ។ ដោយពលរដ្ឋខ្មែរទាំងពីរបានសារភាពថា ពួកគាត់បាន ចូលមកធ្វើការនៅទីក្រុងបាងកក ប្រទេសថៃ បន្ទាប់ផុតសពុលភាពស្នាក់នៅ ហើយមានមិត្តភ័ក្តិសញ្ជាតិខ្មែរដូចគ្នាជួយទំនាក់ទំនងក្រុមខ្យល់រត់ឯកសារក្នុងប្រទេសថៃអោយធ្វើវីសារអោយ ក្នុងតម្លៃ 12000฿ ដោយពួកគាត់មិនដឹងថាជាឯកសារក្លែងក្លាយ ។ តាមស្រាវជ្រាវរបស់សម្ថកិច្ចថៃ បានអោយដឹងថាពលរដ្ឋខ្មែរទាំងពីរនាក់គ្មានប្រវត្តិរូបចេញចូលប្រទេសថៃ សោះ សម្ថកិច្ចថៃបានកសាងសំណុំរឿងបញ្ជូនទៅអធិការដ្ឋាន តម្រួតខ្លងឡឹក ដើម្បីស្រាវជ្រាវបន្ថែមអ្នកដែលទទួលធ្វើដើម្បីចាត់វិធានការណ៍តាមផ្លូវច្បាប់។

# ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩

## កម្លាំងជំនាញខេត្តសៀមរាប ឃាត់ខ្លួនជនជាតិចិន ៦នាក់ ករណីចែកចាយរូបភាពអាសអាភាស

https://www.chnchannel.com/ អត្ថបទដោយ Ritvan កាលបរិច្ឆេទ ថ្ងៃទី 28 ខែ មិថុនា ឆ្នាំ 2019

**សៀមរាប៖** កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ កម្លាំងជំនាញខេត្តសៀមរាប បង្ក្រាបករណីចែកចាយរូបភាព និងសម្ភារៈអាសអាភាសតាមប្រព័ន្ធអ៊ីនធើណេត និងបានឃាត់ខ្លួនជនសង្ស័យចំនួន ៦នាក់ នៅចំណុចផ្ទះវីឡាជួល ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។ យោងតាមប្រភពព័ត៌មានពីសមត្ថកិច្ចបានឲ្យដឹងថា **ជនសង្ស័យទាំង ៦នាក់មាន ៖**

១- ឈ្មោះ WU SONG ភេទប្រុស អាយុ ២៩ឆ្នាំ ជនជាតិ ចិន មុខរបរ បុគ្គលិកចែកចាយរូបភាពអាសអាភាស។

២- ឈ្មោះ LI CHAO ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិ ចិន មុខរបរ បុគ្គលិកចែកចាយរូបភាពអាសអាភាស។

៣- ឈ្មោះ LI HANG ភេទប្រុស កើតថ្ងៃទី ០២-០៣-១៩៩៣ ជនជាតិ ចិន មុខរបរ បុគ្គលិកចែកចាយរូបភាពអាសអាភាស។

៤- ឈ្មោះ LI SHAOJIE ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិ ចិន មុខរបរ បុគ្គលិកចែកចាយរូបភាពអាសអាភាស។

៥- ឈ្មោះ GONG LEI ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិ ចិន មុខរបរ បុគ្គលិកចែកចាយរូបភាពអាសអាភាស។

៦- ឈ្មោះ LI LONGJIE ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិ ចិន មុខរបរ បុគ្គលិកចែកចាយរូបភាពអាសអាភាស។

**វត្ថុតាងដកហូត ៖**

-កុំព្យូទ័រយួរដៃ ០៥គ្រឿង

-ទូរស័ព្ទដៃ ៣០គ្រឿង និងសម្ភារៈវត្ថុតាងមួយចំនួនទៀត។

ជនសង្ស័យទាំង ០៦នាក់ ត្រូវបានកម្លាំងនគរបាលកំពុងសាកសួរ នៅការិយាល័យស៊ើបអង្កេត និងអនុវត្តនីតិវិធី៕

# តំបន់សេដ្ឋកិច្ចពិសេសមេគង្គប្ដេជ្ញាផ្ដល់ការងារសមរម្យដល់ពលការិនីចំណាកស្រុក

https://www.rfa.org/khmer/ ដោយ ម៉ៅ សុជានី 2019-06-27

សិក្ខាសាលា ២ថ្ងៃ រៀបចំដោយបណ្ដាញទេសន្តរប្រវេសក៍តំបន់មេគង្គ ហៅកាត់ថា MMN (Mekong Migration Network) និងវិទ្យាស្ថានបច្ចេកទេសអាស៊ី (Asian Institute of Technology -AIT) នៅទីក្រុងបាងកក ប្ដេជ្ញាថា នឹងគិតគូរពីស្ថានភាពរស់នៅសមរម្យដល់ពលការិនីចំណាកស្រុក នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសមេគង្គ (Special Economic Zone-SEZ)។

សេចក្ដីថ្លែងការណ៍រួមរបស់អង្គការទាំងពីរ កាលពីថ្ងៃទី២៦ ខែមិថុនា ឱ្យដឹងថា ក្នុងអំឡុងសិក្ខាសាលា ២ថ្ងៃ ដែលបានចាប់ផ្ដើម ពីថ្ងៃទី២០ ដល់២១ ខែមិថុនា អ្នកចូលរួមមកពីប្រទេសកម្ពុជា មីយ៉ាន់ម៉ា ឬភូមា និងថៃ បាន ជជែកពិភាក្សាអំពីគម្រោងលើកស្ទួយជីវភាពរស់នៅរបស់ក្រុមគ្រួសារពលករ កម្រិតប្រាក់ខែអប្បបរិមា និងការផ្ដល់ កន្លែងមើលក្មេង ដល់ស្ត្រីជាមាតាជាដើម។ សេចក្ដីថ្លែងការណ៍បន្តថា គោលបំណងសំខាន់នៃសិក្ខាសាលានេះ គឺដើម្បី បង្ហាញពីការរកឃើញរបស់អង្គការបណ្ដាញទេសន្តរប្រវេសក៍តំបន់មេគង្គ (MMN) និងវិទ្យាស្ថានបច្ចេកទេសអាស៊ី (AIT) ស្ដីពីបញ្ហាមួយចំនួន ដែលពលការិនីចំណាកស្រុកជួបប្រទះ រួមមាន កង្វះខាតទទួលបានព័ត៌មាន ការលំបាក របស់សហជីពក្នុងការជួយដោះស្រាយបញ្ហាកម្មករ និងពលករ ការចុះសួរសុខទុក្ខកម្មករក្នុងរោងចក្រ ព្រមទាំងស្ថាន ភាពរស់នៅដ៏លំបាករបស់ពួកគេជាដើម។ អង្គការទាំងពីរនេះ នឹងចេញរបាយការណ៍ពិស្ដារ ស្ដីពីរបកគំហើញនេះ នៅ ខែកក្កដា ខាងមុខ។

កាលពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០១៩ ដោយមានជំនួយឧបត្ថម្ភ ពីមជ្ឈមណ្ឌលស្រាវជ្រាវ អភិវឌ្ឍន៍អន្តរជាតិកាណាដា (Canada's International Development Research Centre) អង្គការបណ្ដាញទេសន្តរប្រវេសក៍តំបន់មេគង្គ (MMN) និងវិទ្យាស្ថានបច្ចេកទេសអាស៊ី (AIT) បានចុះស្រាវជ្រាវ និងស៊ើបអង្កេតដោយផ្ទាល់បីបញ្ហារបស់កម្មករកម្មការិនី និងស្ថានភាពការងាររបស់ពួកគេ នៅតំបន់សេដ្ឋកិច្ចពិសេសមេគង្គ ៤ទីតាំង គឺនៅតំបន់ធីឡាវ៉ា (Thilawa) ក្នុងប្រទេសមីយ៉ាន់ម៉ា តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ និងនៅតំបន់ម៉ែនហាថាន (Manhattan) ក្នុងប្រទេសកម្ពុជា ព្រមទាំងនៅតំបន់សេដ្ឋកិច្ចពិសេស តាក់ (Tak) ក្នុងប្រទេសថៃ។ អ្នកស្រាវជ្រាវទាំងនោះ ក៏បាន សាកសួរ អំពីស្ថានភាពការងាររបស់ពួកគេ ថាតើ ស្របតាមស្តង់ដារ របស់អង្គការអន្តរជាតិផ្នែកការងារ (ILO) ដែរឬទេ ជាពិសេស គឺផ្ដោតទៅលើសិទ្ធិការងារ និងបញ្ហាបរិស្ថានជាដើម។

នៅទន្ទឹមនេះដែរ អ្នកចូលរួមសិក្ខាសាលា ក៏បានសំណូមពរសុំឱ្យគិតគូរ អំពីការផ្ដល់ប្រាក់ខែសមរម្យ ដល់កម្មករនិងកម្មការិនី ទៅតាមជំនាញដែលពួកគេមាន។ អ្នកចូលរួម ក៏បានបង្ហាញក្ដីបារម្ភថា បច្ចុប្បន្នពលករឬកម្មកររោងចក្រ ទទួលបានប្រាក់កម្រៃអប្បបរមា ប្រមាណ ១៧៥បាត ឬស្មើ ជិត៦ដុល្លារ ក្នុងមួយថ្ងៃ ហើយថា ប្រាក់កម្រៃនេះ គឺមានចំនួនតិចជាងប្រាក់កម្រៃអប្បបរិមា ដែលបានកំណត់ថា កម្មករ ឬពលករម្នាក់ៗ អាចទទួលបានប្រាក់កម្រៃយ៉ាងហោចណាស់ ជាង ៣១០បាត ឬស្មើ ១០ដុល្លារក្នុងមួយថ្ងៃ៕